ACLEDA Bank Plc.

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត




## របាយការណ៍ប្រចាំឆ្នាំ

## ២០១៦

# អេស៊ីលីដា យូនីធីទាន់ចិត្ត

ACLEDA Unity ToanChet

## គ្រប់ទីកន្លែង គ្រប់ពេលវេលា




**អេស៊ីលីដាយូនីធីទាន់ចិត្ត** ជាសេវាធនាគារអេឡិចត្រូនិកបច្ចេកវិទ្យាហិរញ្ញវត្ថុ ( FinTech ) ផ្តល់ជូនអតិថិជន ធ្វើប្រតិបត្តិការសេវាធនាគារ អេស៊ីលីដា តាមរយៈទូរស័ព្ទដៃ គ្រប់ពេលវេលា គ្រប់ទីកន្លែង ។

លោកអ្នកអាចទាញយកកម្មវិធីអេស៊ីលីដាយូនីធីទាន់ចិត្ត ដោយឥតគិតថ្លៃបានតាមរយៈ

ANDROID APP ON Google play

Available on the App Store

## ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

## បេសកកម្ម

បេសកកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។



របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយនាយកដ្ឋានទីផ្សារ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
SWIFT Code: ACLBKHPP
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
វេបសាយ ៖ www.acledabank.com.kh

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃ ក្នុងមួយសប្តាហ៍)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជាខ្ទង់ពាន់ដុល្លារអាមេរិក | ៣១/១២/១៦ បានធ្វើសវនកម្ម | ៣១/១២/១៥ បានធ្វើសវនកម្ម | ៣១/១២/១៤ បានធ្វើសវនកម្ម | ៣១/១២/១៣ បានធ្វើសវនកម្ម | ៣១/១២/១២ បានធ្វើសវនកម្ម | បម្រែបម្រួល (%)[១] |
|---|---|---|---|---|---|---|
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេបរួម** | | | | | | |
| ទ្រព្យសកម្ម | ៤.៦៦៤.៧២៦ | ៣.៨៨៥.៣១៧ | ៣.១៣៩.៧៧២ | ២.៤០៧.៧៩១ | ១.៩៨២.៧៤៣ | ២០,០៦% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ២.៨៤១.៣៩១ | ២.៥០៧.៨៨៧ | ២.០៤៣.៦៨៨ | ១.៥២៧.៦៨០ | ១.២៩៤.៧៨៩ | ១៣,៣០% |
| បំណុល | ៤.០០៣.៩៣៦ | ៣.៣៤០.៨២២ | ២.៦៩៨.៦២៤ | ២.០២១.៥៤៦ | ១.៧១៦.១១៩ | ១៩,៨៥% |
| ប្រាក់បញ្ញើ | ៣.១២៦.១៧១ | ២.៦៩៥.៦៤០ | ២.២៦៩.៨៩១ | ១.៧០៩.៥៩៦ | ១.៥០៧.៧៥១ | ១៥,៩៧% |
| ដើមទុន | ៣០៧.៧៦៤ | ២៦៥.៧២៦ | ២២៥.៥៣៦ | ១៨៥.៦៧២ | ១១៣.១៧០ | ១៥,៨២% |
| មូលនិធិម្ចាស់ហ៊ុន [២] | ៦៥៧.១៥៩ | ៥៤១.១៦៨ | ៤៣៧.៣៦៧ | ៣៧០.៦១១ | ២៥២.១៤៤ | ២១,៤៣% |
| ចំណូលដុល | ៤៧៥.៦០៤ | ៤០៣.៦៤៥ | ៣១៦.៩៤០ | ២៧១.១៧០ | ២២៦.៣៤៣ | ១៧,៨៣% |
| ប្រាក់ចំណេញមុនដកពន្ធ | ១៥៨.៣៨៣ | ១៣២.៥៩១ | ១០២.០០៥ | ១០១.៤៨៩ | ៨១.៨៦១ | ១៩,៤៥% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ១២៦.៨៨៧ | ១០៥.០៦៨ | ៨០.៣៦៩ | ៧៩.៧១៧ | ៦៥.០០៣ | ២០,៧៧% |
| ចំណេញក្នុងមួយភាគហ៊ុន | ០,៤១២៣$ | ០,៣៩៥៤$ | ០,៣៥៦៣$ | ០,៤២៩៣$ | ០,៥៧៤៤$ | ៤,២៧% |
| ភាគលាភ [៣] | ០,២០៦២$ | ០,១៩៧៧$ | ០,១៧៨២$ | ០,២១៤៧$ | ០,២៨៧២$ | ៤,៣០% |
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេបដាច់ដោយឡែក** | | | | | | |
| ទ្រព្យសកម្ម | ៤.៥៦១.០២៤ | ៣.៨០២.៤៦៣ | ៣.០៥១.៤៦០ | ២.២៩៧.៧៤៥ | ១.៩០៨.១៧៨ | ១៩,៩៥% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ២.៧១៣.៦៣៥ | ២.៤០៥.៤៦៥ | ១.៩៥៥.០៨៣ | ១.៤៣៩.៤៨៨ | ១.២៣១.២១០ | ១២,៨១% |
| បំណុល | ៣.៨៩០.៦៥០ | ៣.២៤៣.៨៩៨ | ២.៥៩៩.០៥៥ | ១.៩២៧.៥៦១ | ១.៦៥៥.៧៥៥ | ១៩,៩៤% |
| ប្រាក់បញ្ញើ | ៣.០៥១.៦៧៦ | ២.៦១៦.៣៦១ | ២.២០២.៣៨៤ | ១.៦៤៣.០៨២ | ១.៤៦០.៨៦៩ | ១៦,៦៤% |
| ដើមទុន | ៣០៧.៧៦៤ | ២៦៥.៧២៦ | ២២៥.៥៣៦ | ១៨៥.៦៧២ | ១១៣.១៧០ | ១៥,៨២% |
| មូលនិធិម្ចាស់ហ៊ុន | ៦៧០.៣៧៤ | ៥៥៨.៥៦៥ | ៤៥២.៤០៥ | ៣៧០.១៨៥ | ២៥២.៤២៣ | ២០,០២% |
| ចំណូលដុល | ៤៤៥.៧៤០ | ៣៨០.០១៨ | ២៩៦.៥១៩ | ២៥២.៦៧៧ | ២១៤.៨៦៧ | ១៧,២៩% |
| ប្រាក់ចំណេញមុនដកពន្ធ | ១៥២.៨២១ | ១៣២.៩៣៣ | ១០២.៩៥៣ | ៩៧.៧៣១ | ៧៩.២៧៤ | ១៤,៩៦% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ១២២.៣០៥ | ១០៦.១៥៩ | ៨២.២២០ | ៧៧.៧៦១ | ៦៣.៦៤៩ | ១៥,២១% |
| ចំណេញក្នុងមួយភាគហ៊ុន | ០,៣៩៧៤$ | ០,៣៩៩៥$ | ០,៣៦៤៦$ | ០,៤១៨៨$ | ០,៥៦២៤$ | -០,៥៣% |

## ចំណុចសំខាន់ៗក្នុងឆ្នាំ២០១៦[៤]

- ទ្រព្យសកម្ម កើនឡើង ១៩,៩៥% រហូតដល់ ៤.៥៦១ លានដុល្លារអាមេរិក ។
- សមតុល្យឥណទាន (សុទ្ធ) កើនឡើង ១២,៨១% រហូតដល់ ២.៧១៤ លានដុល្លារអាមេរិក ។
- ឥណទានមិនដំណើរការធៀបនឹងឥណទានសរុប មានចំនួន ០,៦៨% ។
- សេវាបញ្ញើ-សន្សំកើនឡើង ១៦,៦៤% រហូតដល់  ៣.០៥២ លានដុល្លារអាមេរិក ។
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ កើនឡើង ១៥,២១% រហូតដល់ ១២២,៣១ លានដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុន កើនឡើង ២០,០២% ពី ៥៥៨,៥៦ លានដុល្លារអាមេរិក ដល់ ៦៧០,៣៧ លានដុល្លារអាមេរិក ។
- ផលលើមូលធន មានចំនួន ១៨,២៤% ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបណ្តាញប្រតិបត្តិការចំនួន ២៥៩ សាខា គ្របដណ្តប់គ្រប់ខេត្ត និងរាជធានី ទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៥ គឺ អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, អេស៊ីលីដា ប្រូភើធី អិលធីឌី, ធនាគារ អេស៊ីលីដា ឡាវ (៤១ ការិយាល័យ), និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៦ ការិយាល័យ) ។

១ បម្រែបម្រួលពី ឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៦ ។

២ មិនគិតបញ្ចូលភាគហ៊ុនអប្បភាគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

៣ ភាគលាភឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ (បែងចែកជាភាគហ៊ុន) ស្មើនឹង ៥០% នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ។ សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ បែងចែកជាសាច់ប្រាក់ ស្មើនឹង១០% និង ៤០% បែងចែកជាភាគហ៊ុន នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ។

៤ តួលេខទាំងនេះ គិតតែប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ដូចនេះមានភាពខុសគ្នាពីរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងបុត្រសម្ព័ន្ធ ។

# របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារដែលមានតម្លាភាពមួយ យើងខ្ញុំសូមផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម ៖

| គិតជាដុល្លារអាមេរិក | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប * |
|---|---|---|---|---|---|---|
| ពន្ធប៉ាតង់ | ៦.៧៦៨ | ៦.៨៤៩ | ៦.៥៧១ | ៧.០២៥ | ១៩.០៣៦ | ១១២.១៧១ |
| ពន្ធលើស្លាកសញ្ញា | ៤៥.៣០០ | ៥៣.២១០ | ៦៥.៧៩៦ | ៧៣.៩៣១ | ៧៥.៨២៦ | ៥៩៧.៣១៥ |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន | ២៧.៧៩៧ | ៣៧.២៩៥ | ៤៧.០៤៩ | ៤០.៧៧៩ | ៤១.៨៦៤ | ២២១.០៤៧ |
| ពន្ធលើអចលនទ្រព្យ | ៦.៨៧២ | ៦.៧៧៣ | ៦.៨៧១ | ២៣.៣៩០ | ៧.៦៥១ | ៥៨.៣៦០ |
| អាករលើតម្លៃបន្ថែម | - | - | ១.២៤៨ | ៧.០៤២ | - | ៨.២៩០ |
| ប្រាក់រំលោះពន្ធលើប្រាក់ចំណេញ | ២.១៥៣.១៦៧ | ២.៥១៨.៦១២ | ២.៩១៣.៦៤៦ | ៣.៧៤៧.៩០៨ | ៤.៣៩៦.៦៦០ | ២២.៤៨៣.៥៧៤ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១២.៣៧២.៧៣០ | ១៧.៤៥៤.១៣០ | ១៥.១៣៧.៥១០ | ២០.៨៤៤.១៣៤ | ២៥.៩៩៣.២១៧ | ១១០.៧៣៥.៨២៩ |
| ពន្ធលើប្រាក់បៀវត្សរ៍ | ២.៩៥៥.១៩៧ | ៣.០៥៨.៧៥៤ | ៣.៥៨៣.៦១២ | ៣.៧៣៥.៩៦៦ | ៥.០៣៣.៥៥៧ | ២៧.៧៨០.១១៣ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើសន្សំ | ១២២.៩១២ | ១៣៩.០១៥ | ១៦១.០៥១ | ២០៩.៦២៥ | ២២៤.២៨៤ | ១.៥២៣.៥៨៩ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើមានកាលកំណត់ | ១.៣៨៤.១១៥ | ១.៩០២.៩៥៥ | ២.០៩៤.៧១៥ | ៤.៦៨៦.៨៨៩ | ៣.៩០៤.៨៦៥ | ១៧.៣៩១.៩៨៧ |
| ពន្ធកាត់ទុកលើថ្លៃជួលអចលនទ្រព្យ | ៥៤១.៩១០ | ៥៩៦.៩១៣ | ៧២២.៩៨២ | ៧៨៥.៩៦៤ | ៨៥៦.៤០០ | ៦.៣០៦.៧៩៧ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្នុងប្រទេស | ២៣៩.៤៩១ | ២២៤.៧២៥ | ២៤៥.៥០៦ | ២៤៦.៦៦៥ | ២៨៨.១៥៩ | ២.៧៧៣.២០២ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្រៅប្រទេស | ១.៤៦៥.៥២២ | ១.៧០៥.៦៥៥ | ២.១៩១.៨៦៣ | ៣.០១៥.២៩៩ | ៤.៧២៤.៥៤២ | ២០.៥១៩.៤២២ |
| សរុប | ២១.៣២១.៧៨១ | ២៧.៧០៤.៨៨៥ | ២៧.១៧៨.៤២០ | ៣៧.៤២៤.៦១៨ | ៤៥.៥៦៦.០៦១ | ២១០.៤៧១.៦៩៦ |
| សរុបយោង * | ៧២.៥៩៧.៧១២ | ១០០.៣០២.៥៩៧ | ១២៧.៤៨១.០១៧ | ១៦៤.៩០៥.៦៣៤ | ២១០.៤៧១.៦៩៦ | |

* សរុប និងសរុបយោង គិតចាប់ពីឆ្នាំ២០០០ មក ។

រូបភាពខាងក្រោមក្នុងទំព័រនេះ និងក្នុងទំព័រផ្សេងទៀត ជាសកម្មភាពអាជីវកម្មរបស់អតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងប្រទេសកម្ពុជា ។



ចំការត្រសក់ ក្នុងខេត្តកំពត



ចំការបិគក់ ក្នុងខេត្តបន្ទាយមានជ័យ

# លទ្ធផលសម្រេចបាន *




### ទ្រព្យសកម្មសរុប/មូលនិធិម្ចាស់ហ៊ុន និងផលលើមូលធន

- ផលលើមូលធន (គិតជាភាគរយ)
- មូលនិធិម្ចាស់ហ៊ុន (គិតជាលានដុល្លារអាមេរិក)
- ទ្រព្យសកម្មសរុប (គិតជាលានដុល្លារអាមេរិក)

### សមតុល្យឥណទាន និងចំនួនអតិថិជនឥណទាន

- ចំនួនអតិថិជនឥណទាន
- សមតុល្យឥណទាន (គិតជាលានដុល្លារអាមេរិក)







### ប្រាក់បញ្ញើ-សន្សំ និងចំនួនអតិថិជនដាក់ប្រាក់បញ្ញើ-សន្សំ

- ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ-សន្សំ
- ប្រាក់បញ្ញើ-សន្សំ (គិតជាលានដុល្លារអាមេរិក)

### សេវាផ្ទេរប្រាក់ក្នុងនិងក្រៅប្រទេស និង ចំនួនប្រតិបត្តិការ

- ចំនួនប្រតិបត្តិការផ្ទេរប្រាក់ក្រៅប្រទេស
- ចំនួនប្រតិបត្តិការផ្ទេរប្រាក់ក្នុងប្រទេស
- សេវាផ្ទេរប្រាក់ក្រៅប្រទេស (គិតជាលានដុល្លារអាមេរិក)
- សេវាផ្ទេរប្រាក់ក្នុងប្រទេស (គិតជាលានដុល្លារអាមេរិក)




* តួលេខទាំងនេះ គិតតែប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ដូចនេះមានភាពខុសគ្នាពីរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងបុត្រសម្ព័ន្ធ ។

# មាតិកា


៦ សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា
៧ របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល
១០ របាយការណ៍ប្រធាននាយកប្រតិបត្តិ
១៤ អង្គការលេខ
១៥ បណ្តាញប្រតិបត្តិការ

១៦ អភិបាលកិច្ចសាជីវកម្ម
១៦ កិច្ចប្រជុំភាគទុនិក
១៦ ភាគទុនិក

១៨ ក្រុមប្រឹក្សាភិបាល
២៣ គណៈកម្មាធិការប្រតិបត្តិ
៣០ សវនករផ្ទៃក្នុង
៣១ ក្រមសីលធម៌

៣២ របាយការណ៍ក្រុមប្រឹក្សាភិបាល
៣២ របាយការណ៍គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល
៣២ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
៣៣ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់
៣៤ គណៈកម្មាធិការឥណទាន
៣៤ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង
៣៥ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

៣៧ របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

៤១ របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក

៤២ របាយការណ៍ក្រុមប្រឹក្សាភិបាល
៤៥ របាយការណ៍សវនករឯករាជ្យ

*របាយការណ៍ហិរញ្ញវត្ថុរួម*
៤៧ តារាងតុល្យការរួម
៤៨ របាយការណ៍លទ្ធផលរួម
៤៩ របាយការណ៍បម្រែបម្រួលមូលធនរួម
៥០ របាយការណ៍លំហូរសាច់ប្រាក់រួម

*របាយការណ៍ហិរញ្ញវត្ថុដោយឡែក*
៥១ តារាងតុល្យការដោយឡែក
៥២ របាយការណ៍លទ្ធផលដោយឡែក
៥២ របាយការណ៍បម្រែបម្រួលមូលធនដោយឡែក
៥៣ របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក
៥៤ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

១១៥ ការផ្តល់ចំណាត់ថ្នាក់
១១៦ ឧបសម្ព័ន្ធគំនិតផ្តួចផ្តើមនៃរបាយការណ៍ពិភពលោក (GRI)
១១៧ សាខាធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ
១២៧ ធនាគារដៃគូ




កិច្ចប្រជុំនាយក-នាយិកាសាខា នៅការិយាល័យកណ្តាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

# សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦e | ២០១៧f |
|---|---|---|---|---|---|---|
| **១. ផលិតផលសរុបក្នុងស្រុក (GDP)** | | | | | | |
| បម្រែបម្រួលផលិតផលសរុបក្នុងស្រុក (គិតជាភាគរយ) | ៧,៣ | ៧,៤ | ៧,១ | ៧ | ៧ | ៧ |
| ចំណូលក្នុងម្នាក់ (គិតជាដុល្លារអាមេរិក) | ៩៧៣ | ១.០៤៣ | ១.១៣៨ | ១.២១៥ | ១.៣០០ | ១.៤២២ |
| **២. អតិផរណា** | | | | | | |
| អតិផរណា (មធ្យមប្រចាំឆ្នាំ) | ២,៩ | ៣ | ៣,៩ | ១,២ | ២,៨ | ៣,៧ |
| (ចុងឆ្នាំ) | ២,៥ | ៤,៦ | ១,១ | ២,៦ | - | - |
| **៣. ថវិការបស់រដ្ឋាភិបាល (គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក)** | | | | | | |
| ចំណូល | ១៦,៩ | ១៨,៤ | ១៧,៥ | ១៨,៩ | ១៧,៩ | ១៨,២ |
| ចំណាយ | ២០,៧ | ២០,៥ | ២១,៥៥ | ២០,៩ | ២២,៨ | ២៣,១ |
| **៤. រូបិយវត្ថុ និងឥណទាន (បម្រែបម្រួលជាភាគរយក្នុង ១២ខែ)** | | | | | | |
| រូបិយវត្ថុទូទៅ (M2) | ២០,៩ | ១៤,៦ | ២៩,៩ | ១៤,៧ | ២០,៨ | - |
| ប្រាក់បញ្ញើសរុបនៅក្នុងប្រព័ន្ធធនាគារ | ២៤,៩ | ១៣,៨ | ៣០,១ | ១៦,៤ | ២០ | - |
| ឥណទានសរុបនៅក្នុងប្រព័ន្ធធនាគារ | ៣៥,១ | ២៥,២ | ១៦,២ | ២៥,៧ | ១៨ | - |
| ឥណទានធៀបនឹងប្រាក់បញ្ញើ (គិតជាភាគរយ) | ៨៦,៨ | ៩៨ | ៩៤ | ១០២,៦ | ១០១,៧ | - |
| ឥណទានវិស័យឯកជន | ២៨,០ | ២៦,៧ | ៣១,៣ | ២៧,១ | ២១,៦ | - |
| ប្រាក់បញ្ញើធៀបនឹងផលិតផលសរុបក្នុងស្រុក | ៤៧,៣ | ៤៩ | ៥៣ | ៦១,៩ | ៦៧,៨ | - |
| ឥណទានធៀបនឹងផលិតផលសរុបក្នុងស្រុក | ៤១ | ៤៩,៨ | ៥០ | ៦៣,៥ | ៦៩ | - |
| **៥. ជញ្ជីងទូទាត់ (គិតជាលានដុល្លារអាមេរិក)** | | | | | | |
| ការនាំចេញ | ៦.០១៥,៧ | ៦.៥៣០ | ៧.៤០៨e | ៨.២០៨,៨ | ៩.០១៧,៧ | ៩.៩៣៦,៧ |
| ការនាំចូល | -៨.៤២៦ | -៩.៧៤៤ | -១០.៩៩១e | -១០.៥៤២ | -១១.៤៤៩,៦ | -១២.៥៥៩,៣ |
| ជញ្ជីងពាណិជ្ជកម្ម | -២.៩៦៧ | -៣.២១៤ | -៣.៥៨៣e | -២.៣៣៣,២ | -២.៤៣១,៩ | -២.៦២២,៦ |
| គណនីចរន្ត (មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ) | -១.៨៣៥ | -២.១៧១ | -២.៣៥៦e | -១.៩០៨,៤ | -២.០៣៩,១ | -២.២១៩,១ |
| ផលិតផលសរុបក្នុងស្រុកជាមធ្យម (គិតជាពាន់លានដុល្លារអាមេរិក) | ១៤,១ | ១៥,៣៥ | ១៦,៩១ | ១៨,០៨ | ២០,០៩ | ២២,២១ |
| អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារ នៅចុងគ្រា) | ៤.០៣៣ | ៤.០២៧ | ៤.០៣៨ | ៤.០៦០ | ៤.០៥០ | ៤.០៥០ |

ប្រភព ៖ សមាគមធនាគារនៅកម្ពុជា, ធនាគារជាតិនៃកម្ពុជា, មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

e: ប៉ាន់ប្រមាណ និង f: ព្យាករណ៍ ។



សិប្បកម្មធ្វើទូក ក្នុងខេត្តព្រះសីហនុ



សិប្បកម្មធ្វើវត្ថុប្រើប្រាស់ ក្នុងខេត្តសៀមរាប

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



លោក ឆាយ សឿន
ប្រធានក្រុមប្រឹក្សាភិបាល

"ជំនួសមុខឱ្យក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ២០១៦ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលរួមមានទិដ្ឋភាពទូទៅដ៏ទូលំទូលាយ និងការពន្យល់ក្បោះក្បាយអំពីលទ្ធផលដែលបានអនុវត្តន៍របស់យើងខ្ញុំក្នុងឆ្នាំ២០១៦ ដូចជារបាយការណ៍លម្អិតស្តីពីអភិបាលកិច្ចសាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរួមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។"

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៦ យើងខ្ញុំបានបន្តអនុវត្តគោលដៅចម្បងរបស់ធនាគារ ដែលបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រ៥ឆ្នាំរបស់ធនាគារ ២០១៦-២០២១ ដើម្បីក្លាយជាធនាគារពាណិជ្ជធំ និងឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត) ព្រមទាំងដើម្បីប្រកួតប្រជែងនៅក្នុងទីផ្សារធនាគារ ។ ការអនុវត្តប្រកបដោយតម្លាភាព គឺផ្តល់នូវទំនុកចិត្តដល់ភាគទុនិករបស់យើងខ្ញុំ ក្នុងការទទួលបានប្រាក់ចំណេញរយៈពេលវែង ពីព្រោះយើងបានបន្តគាំទ្រនូវរបៀបវារៈកំណើនសេដ្ឋកិច្ច និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅតែបន្តពង្រឹងគំរូអាជីវកម្មរបស់ខ្លួន ព្រមទាំងសម្រួលឱ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាធនាគារជូនដល់អតិថិជនទាំងវិស័យឯកជន និងសាធារណៈ ដែលអាចទទួលបានប្រាក់ចំណូលប្រកបដោយនិរន្តរភាពនាពេលអនាគត និងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ភាគទុនិករបស់ធនាគារ ។

នៅក្នុងឆ្នាំ២០១៦នេះ យើងខ្ញុំបានបន្តលើកកម្ពស់សេវាធនាគារអេឡិចត្រូនិកដើម្បីផ្តល់នូវសេវាដ៏ល្អឥតខ្ចោះ និងងាយស្រួលដល់អតិថិជនព្រមទាំងត្រៀមខ្លួនជាស្រេច ដើម្បីបម្រើអតិថិជនទូទាំងសកលលោកចាប់ពីឆ្នាំ២០១៧ នេះតទៅ ។

ស្ថាប័នផ្តល់ចំណាត់ថ្នាក់ Standard & Poor's បានរក្សាចំណាត់ថ្នាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅកម្រិត "B+" ដដែល ជាមួយចក្ខុវិស័យ "ស្ថិរភាព" ។ ចំណាត់ថ្នាក់នេះគឺជាការបញ្ជាក់ពីភាពជោគជ័យរបស់ធនាគារ ក្នុងការពង្រឹងអភិបាលកិច្ច ដើមទុន បណ្តាញប្រតិបត្តិការ និងផ្តល់នូវសេវាកម្មជាលក្ខណៈស្តង់ដារ ។

ឆ្នាំ២០១៦ គឺជាឆ្នាំដែលធនាគារ អេស៊ីលីដា ភីអិលស៊ី មានភាពរីកចម្រើនល្អលើសគ្រប់ផ្នែកទាំងអស់ គួរឱ្យកត់សម្គាល់ ។ ប្រាក់ចំណេញសុទ្ធដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានចំនួន ១២៦,៨៩ លានដុល្លារអាមេរិក ដែលកាលពីឆ្នាំ២០១៥ មានចំនួន ១០៥,០៧ លានដុល្លារអាមេរិកប៉ុណ្ណោះ ។ ប្រាក់ចំណេញមុនដកពន្ធប្រចាំឆ្នាំ២០១៦ បានកើនឡើងដល់ ១៥៨,៣៨ លានដុល្លារអាមេរិក ដែលនេះគឺជាប្រាក់ចំណេញដែលកើនឡើងខ្ពស់ជាងឆ្នាំ២០១៥ ចំនួន ១៩,៤៥% ។ កំណើននេះបានកើនឡើង ១១,៨៩% ជាចំណូលការប្រាក់សុទ្ធ ដែលមានចំនួន ២៨៧,២២ លានដុល្លារអាមេរិក និង ២៣,៨៥% ជាថ្លៃសេវា និងកម្រៃជើងសារដែលមានចំនួន ៤៨,១៣ លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០១៦ ។

តួលេខទាំងនេះបង្ហាញនូវភាពរីកចម្រើនដ៏រឹងមាំ នៅក្នុងវិស័យធនាគាររបស់យើង ព្រោះយើងបន្តឱ្យមានតុល្យភាពប្រាក់ចំណូលដែលបានមកពីការវិនិយោគពីអាជីវកម្មស្នូល ។ ប្រាក់ចំណូលមិនមែនការប្រាក់ បានមកពីប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ទាំងក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា មានចំនួន ៦៣,៦៨ លានដុល្លារអាមេរិក ដែលស្មើនឹងចំនួន ១៣,៣៩% នៃប្រាក់ចំណូលសរុប ។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានកំណើនដ៏រឹងមាំដែលបង្ហាញក្នុងតារាងតុល្យការឆ្នាំ២០១៦ របស់ខ្លួន ក្នុងនោះទ្រព្យសកម្មសរុបកើនឡើង ២០,០៦% មានចំនួន ៤,៦៦ ពាន់លានដុល្លារអាមេរិក បើធៀបទៅនឹងចុងឆ្នាំ២០១៥ មានចំនួន ៣,៨៩ ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ ។ ឥណទាន និងបុរេប្រទាន

បានកើនឡើង ១៣,៣០% មានចំនួន ២,៨៤ ពាន់លានដុល្លារអាមេរិក ។ ប្រាក់បញ្ញើរបស់អតិថិជន និងស្ថាប័នធនាគារ បានកើនឡើង ១៥,៩៧% មានចំនួន ៣,១៣ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ បើធៀបទៅនឹងចុងឆ្នាំ២០១៥ ដែលមានត្រឹមតែ ២,៧០ ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ ។ គុណភាពឥណទានត្រូវបានបង្ការ ធ្វើឱ្យអនុបាតឥណទានមិនដំណើរការមានចំនួន ០,៦៨% ។ ប្រាក់ចំណេញក្នុងមួយហ៊ុនមានចំនួន ០,៤១២៣% នៅចុងឆ្នាំ២០១៦ ដែលកាលពីឆ្នាំ២០១៥ មានត្រឹម ០,៣៩៥៤ ប៉ុណ្ណោះ ។ អនុបាតដើមទុនមានភាពគ្រប់គ្រាន់គឺ ២៣,១០% ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ។

អនុលោមតាមលក្ខខណ្ឌរបស់ធនាគារជាតិនៃកម្ពុជា ធនាគារ អេស៊ីលីដា ភីអិលសុី បានទប់ស្កាត់ពីការផ្តល់ប្រាក់កម្ចី ដែលមានហានិភ័យប៉ះពាល់ដល់មូលនិធិភាគទុនិក ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ យើងមានទុនបម្រុងចំនួន ៣៨១,០៤ លានដុល្លារអាមេរិក ដែលអាចបំពេញតាមលក្ខខណ្ឌតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។ ដោយមានគោលបំណងបង្កើនប្រាក់ចំណេញអតិបរមារយៈពេលវែងជូនដល់ភាគទុនិក ក្រុមប្រឹក្សាភិបាលបានផ្តល់អនុសាសន៍ក្នុងមហាសន្និបាតប្រចាំឆ្នាំ ក្នុងការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន ១០% និងបែងចែកភាគលាភជាភាគហ៊ុនចំនួន ៤០% នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ឆ្នាំ២០១៦ ដែលស្មើនឹង ០,២០៦២ ក្នុងមួយហ៊ុន ។

## អភិបាលកិច្ច

មានការផ្លាស់ប្តូរមួយចំនួនទាក់ទងនឹងអភិបាលកិច្ចរបស់ ធនាគារ អេស៊ីលីដា ភីអិលសុី និងក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងឆ្នាំ២០១៦នេះ ។ ចំណែកឯនៅក្នុងថ្នាក់គ្រប់គ្រងជាន់ខ្ពស់វិញ ការផ្លាស់ប្តូរមួយគួរឱ្យកត់សម្គាល់នៅក្នុងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ គឺការចូលនិវត្តន៍របស់លោក ចាន់ សេរី ដែលមានតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច ក្រោយពីលោកបានធ្វើការអស់រយៈពេលជាង ២២ឆ្នាំ ជាមួយនឹងអេស៊ីលីដា ដោយជំនួសដោយលោក លី ថៃ ជានាយកប្រតិបត្តិប្រតិបត្តិការក្នុងខែសីហា ឆ្នាំ២០១៦ ។

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំនៅរាជធានីភ្នំពេញ ចំនួនបីដង ក្នុងខែមីនា ខែកញ្ញា និងខែធ្នូ និងបានប្រជុំមួយដងទៀតនៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងខែមិថុនា ។ បន្ថែមពីនេះទៀត សេចក្តីសម្រេចចំនួន ១៣ បានអនុម័តតាមរយៈអ៊ីម៉ែល ។ កិច្ចប្រជុំនីមួយៗមានរយៈពេលមួយថ្ងៃកន្លះ រួមបញ្ចូលទាំងកិច្ចប្រជុំរបស់គណៈកម្មាធិការនីមួយៗ ។ មានការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាលមួយចំនួនផងដែរ ក្នុងឆ្នាំ២០១៦ នេះ ។ កញ្ញា HENG Su Yin មកពីធនាគារ SMBC បានតែងតាំងជាសមាជិកាក្រុមប្រឹក្សាភិបាល ជំនួសលោក Tetsuro YOSHINO ដែលបានលាឈប់ពីសមាជិកក្រុមប្រឹក្សាភិបាល ដោយសារតែតម្រូវការផ្លាស់ប្តូរការទទួលខុសត្រូវប្រចាំតំបន់របស់លោក ។ ចំណែកឯលោក Ian S. LYDALL បានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ឡាវ ជំនួសលោកស្រី គឹម សុធាវី គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង ។ មានសេចក្តីសម្រេចចម្បងៗជាច្រើន ក្នុងឆ្នាំ២០១៦ ដូចជា ៖ ទី១ អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួមបានធ្វើសវនកម្មសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសបានធ្វើសវនកម្មឆ្នាំ២០១៦ ។ ទី២ អនុម័តការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥ នៃប្រាក់ចំណេញក្រោយដកពន្ធ និងផ្ទេរប្រាក់ចំណេញក្រោយដកពន្ធដែលនៅសល់ទៅជាទុនបម្រុងរបស់ធនាគារ ។ ទី៣ អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ ទី៤ អនុម័ត និងផ្តល់អនុសាសន៍ដល់ភាគទុនិកក្នុងការជ្រើសរើសសវនករឯករាជ្យ សម្រាប់ឆ្នាំ២០១៧-២០១៨ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ ទី៥ អនុម័តផែនការយុទ្ធសាស្ត្រ



រោងចក្រផលិតទុយោជ័រ ក្នុងរាជធានីភ្នំពេញ



សិប្បកម្មកែច្នៃជ័រកៅស៊ូ ក្នុងខេត្តកំពង់ចាម

និងផែនការថវិកាឆ្នាំ២០១៧ របស់ធនាគារ ។ ទី៦ ពិនិត្យឡើងវិញ និងអនុម័តគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ។ ទី៧ តែងតាំង និងតែងតាំងឡើងវិញរបស់អភិបាលនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ ទី៨ អនុម័តការបន្ថែមដើមទុនសម្រាប់វិនិយោគបន្ថែមទៀត និងថវិកាសម្រាប់គម្រោងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា ។ ចុងក្រោយ អនុម័តប្រាក់កម្ចីពហុហិរញ្ញប្បទានអាទិភាព និងឥណទានបន្ទាប់បន្សំ ពីម្ចាស់ជំនួយជាតិ និងអន្តរជាតិ ។

## ទស្សនវិស័យ

ទិសដៅយុទ្ធសាស្រ្ត គឺជាចំណុចដែលក្រុមប្រឹក្សាភិបាល ក៏ដូចជាថ្នាក់ដឹកនាំតែងយកចិត្តទុកដាក់គិតគូរជានិច្ច ។ ការពង្រីកទីផ្សារក្នុងតំបន់ ការអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីៗ ការប្រែក្លាយខ្លួនទៅជាធនាគារឌីជីថល និងធនាគារអេឡិចត្រូនិក គឺជាយុទ្ធសាស្រ្តចម្បងបំផុតរបស់យើងដើម្បីប្រកួតប្រជែងក្នុងទីផ្សារសមាហរនកម្មអាស៊ាន និងដើម្បីទទួលបានកំណើនប្រាក់ចំណេញខ្ពស់ ។

យើងខ្ញុំសូមអគុណដល់អតិថិជន ភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ ព្រមទាំងបុគ្គលិកទាំងអស់ដែលបានគាំទ្រ និងខិតខំប្រឹងប្រែងអនុវត្តតាមយុទ្ធសាស្រ្តរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ក៏ដូចជាសម្រេចជោគជ័យតាមគោលដៅ និងវត្ថុបំណងរបស់ខ្លួន ។ ខ្ញុំសូមសំដែងនូវការដឹងគុណដល់រដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា និយ័តករ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលតែងតែជួយគាំទ្រ និងប្រឹងប្រែងអភិវឌ្ឍឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ជាពិសេសវិស័យធនាគារតែម្តង ។

យើងខ្ញុំសូមធានាចំពោះអតិថិជន ព្រមទាំងភាគទុនិកទាំងអស់ថានៅឆ្នាំ២០១៧ នេះ យើងខ្ញុំនឹងបន្តពិចារណាទៅលើតំបន់ទាំងឡាយណាដែលផ្តល់ឱកាសល្អដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងខិតខំប្រឹងប្រែងអស់ពីលទ្ធភាពរបស់យើងខ្ញុំក្នុងការសម្រេចឱ្យបាននូវភាពជោគជ័យ រីកចម្រើន និងមាននិរន្តរភាព ព្រមទាំងដើម្បីផ្តល់នូវគោលដៅយុទ្ធសាស្រ្ត ក្នុងការបង្កើនប្រាក់ចំណេញនាពេលអនាគត ក៏ដូចជាពង្រឹងជំហររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងតំបន់ ។



លោក ឆាយ សឿន

*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧



សិប្បកម្មកែច្នៃឈើ ក្នុងខេត្តកំពង់ធំ



សិប្បកម្មកាត់កញ្ចក់ ក្នុងរាជធានីភ្នំពេញ

# របាយការណ៍ប្រធាននាយកប្រតិបត្តិ



**បណ្ឌិត អ៊ិន ចាន់នី**
ប្រធាននាយកប្រតិបត្តិ

"តម្លៃទំនិញបានធ្លាក់ចុះ ចំណែកឯទីផ្សារអាជីវកម្មលក់គ្រឿងសំណង់បានថយចុះ ធ្វើឱ្យតម្រូវការសេវាឥណទានអចលនទ្រព្យក៏បានថយចុះផងដែរក្នុងឆ្នាំ២០១៦នេះ ។ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរនេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបន្ថយកំណើនឥណទានខ្នាតមធ្យម និងឥណទានសាជីវកម្ម ដើម្បីស្រូបយកអតិថិជនឥណទានខ្នាតតូច និងក្រោមមធ្យម ព្រមទាំងបន្តធ្វើពិពិធកម្មកំណើនផលិតផលនិងសេវាហិរញ្ញវត្ថុរបស់ខ្លួន ។ ជាលទ្ធផល ធនាគារទទួលបានជោគជ័យល្អប្រសើរសម្រាប់ឆ្នាំ២០១៦នេះ ។ នៅចុងឆ្នាំ២០១៦ ធនាគារបានពង្រីកហេដ្ឋារចនាសម្ព័ន្ធសេវាធនាគារឌីជីថល និងបានបង្កើតសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត ដែលអនុញ្ញាតឱ្យ អតិថិជនគ្រប់ស្រទាប់នៅក្នុងប្រទេសអាចប្រើសេវាធនាគារបាន ជាពិសេសគឺការទូទាត់ផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃបានគ្រប់ពេលវេលា ។ ឥឡូវនេះ អតិថិជនរបស់ធនាគារអេស៊ីលីដាទាំងអស់ អាចប្រើប្រាស់គណនីបញ្ញើសំចៃរបស់ពួកគាត់ និងអាចគាំទ្រការទូទាត់ក្នុងមុខជំនួញរបស់ពួកគាត់ទូទាំងប្រទេស ។"

## សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៦

### ស្ថានភាពប្រកួតប្រជែង

ទីផ្សារហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាដោយមានច្បាប់បើកចំហសេរី នាំឱ្យមានការប្រកួតប្រជែងខ្លាំង ក្នុងនោះមានស្ថាប័នធនាគារឯកទេស និងធនាគារពាណិជ្ជចំនួនជាង ៥០ ស្ថាប័ន ព្រមទាំងមានស្ថាប័នមីក្រូហិរញ្ញវត្ថុបានកើនឡើងជាច្រើនទៀត ។ ទោះបីជាមានការប្រកួតប្រជែងខ្លាំងក្នុងចំណោមធនាគារឯកទេស និងធនាគារពាណិជ្ជទាំងនោះក៏ដោយ ក៏ធនាគារអេស៊ីលីដានៅតែរក្សាបាននូវតំណែងជាធនាគារឈានមុខគេលើ ទ្រព្យសកម្ម, ឥណទាន, ប្រាក់បញ្ញើ, ប្រាក់ចំណេញ ក៏ដូចជាចំនួនសាខា, ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាតទូទាំងប្រទេសកម្ពុជា ។ ហេដ្ឋារចនាសម្ព័ន្ធសេវាអេឡិចត្រូនិករួមបញ្ចូលគ្នា ត្រូវបានដាក់ឱ្យប្រើប្រាស់បម្រើសេវាជូនដល់អតិថិជន សាធារណជននៅក្នុងសហគមន៍ពាណិជ្ជកម្មពីគ្រប់មជ្ឈដ្ឋាន ដែលពួកគាត់ធ្វើប្រតិបត្តិការមុខជំនួញ ដោយពុំចាំបាច់មកសាខារបស់ ធនាគារ អេស៊ីលីដា ដែលមាននៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជាឡើយ ។

### ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០១៦

- សមតុល្យឥណទានសុទ្ធសរុបមានចំនួន ២.៧៧១ លានដុល្លារអាមេរិក ក្នុងនោះចំនួន ៥៥០ លានដុល្លារអាមេរិក ស្មើនឹង ១៩,៨៣% ត្រូវបានផ្តល់លើវិស័យកសិកម្មក្នុងចំណោមការ វិនិយោគលើវិស័យជាច្រើនផ្សេងៗទៀត ។ បើប្រៀបធៀបកាលពីខែធ្នូ ឆ្នាំ២០១៥ ដែលសមតុល្យឥណទានសុទ្ធសរុបចំនួន ២.៤៥៤ លានដុល្លារអាមេរិក ដែលក្នុងនោះចំនួន ៥១១លានដុល្លារអាមេរិក ស្មើនឹង ២០,៨១% ត្រូវបានវិនិយោគលើវិស័យកសិកម្ម ។
- ក្នុងឆ្នាំ២០១៦ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានប្រកាសនូវរបាយការណ៍ប្រាក់ចំណេញក្រោយបង់ពន្ធ កើនឡើងខ្ពស់ស្ទើរតែស្មើនឹងថវិកាប្រចាំឆ្នាំ ដែលលទ្ធផលនេះទទួលបានពីកម្ចីសម្រាប់អាជីវកម្មខ្នាតតូច ព្រមទាំងសហគ្រាសខ្នាតតូច និងខ្នាតមធ្យមរបស់យើងក៏ដូចជាកំណើនលើវិស័យប្រាក់កម្ចី ពាណិជ្ជកម្មខ្នាតតូចបំផុត និងខ្នាតតូច ។ នៅឆ្នាំ២០១៥ យើងមានអតិថិជនឥណទានខ្នាតតូចបំផុតចំនួន ២១៣.១៥៨ នាក់ ។ នៅចុងឆ្នាំ២០១៦ យើងមានអតិថិជនឥណទានខ្នាតតូចបំផុតចំនួន ២០៨.០៨៩ នាក់ ។
- ធនាគារ អេស៊ីលីដា បន្តកាត់បន្ថយចំណាយ និងត្រួតពិនិត្យហានិភ័យ ដើម្បីទទួលបានចំណូលខ្ពស់បំផុត ។ ឥណទានមិនដំណើរការក្នុងឆ្នាំ២០១៦ មានចំនួន ០,៦៨% ដែលអនុបាតប្រសិទ្ធភាពប្រតិបត្តិការមាន ៣៦,៣៨% បើប្រៀបធៀបកាលពីឆ្នាំ២០១៥ មានចំនួន ៣៨,៩១% ។
- ធនាគារ អេស៊ីលីដា បានដាក់ឱ្យដំណើរការនូវសេវាប័ណ្ណអន្តរជាតិថ្មីមួយទៀត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ដែលបានស្រូបយកចំណែកទីផ្សាររបស់ប័ណ្ណអន្តរជាតិ បន្ថែមពីលើប័ណ្ណឥណទានអន្តរជាតិ របស់ធនាគារដែលបានដាក់ឱ្យប្រើប្រាស់កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ ។
- ធនាគារ អេស៊ីលីដា បានដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសេវាធនាគារអេឡិចត្រូនិករួម បញ្ចូលគ្នា ដើម្បីអតិថិជនអាចធ្វើប្រតិបត្តិការទូទាំងពិភពលោកយ៉ាងងាយស្រួល និងប្រកបដោយសុវត្ថិភាពខ្ពស់ ។

- បានពង្រីកបណ្តាញម៉ាស៊ីនឆូតកាតដោយគ្មានខ្សែ ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពខ្ពស់ជូនដល់អតិថិជន ។
- បម្រើសេវាកម្មជាមួយវិស័យសាធារណៈ និងឯកជន តាមរយៈការផ្តល់សេវាបើកប្រាក់របបសន្តិសុខសង្គម ដោយផ្តល់ភាពងាយស្រួលជូនដល់អតិថិជន និងអាចបង្កើនទុនបម្រុងរូបិយវត្ថុក្នុងស្រុក ។
- សេវាបើកប្រាក់បៀវត្សរ៍របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានអតិថិជនជាមន្ត្រីរាជការ និងក្រុមហ៊ុនថ្មីៗជាច្រើន និងទទួលបានឱកាសផ្តល់សេវាផ្សេងៗជាច្រើនទៀតដល់បុគ្គលិករបស់ ក្រុមហ៊ុនទាំងនោះ ។

## សេវាឥណទាន និងសេវាបញ្ញើ-សន្សំ

ឥណទានខ្នាតតូចបំផុតបានកើនឡើង ៧,៩៧% ឥណទានខ្នាតតូចកើនឡើង ១៣,៦៥% និងឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនកើនឡើង ១៤,00% ។ ឥណទានគេហដ្ឋានមានចំនួន ៧,៦៣% នៃទំហំឥណទានសរុប ។ ប្រាក់បញ្ញើ-សន្សំបានកើនឡើង ១៦,៦៤% រហូតដល់ ៣.០៥១,៦៨ លានដុល្លារអាមេរិក ដែលភាគច្រើនបានមកពីអតិថិជនខ្នាតតូចដាក់ប្រាក់បញ្ញើដំបូង ដូចជាកម្មករនិយោជិតតាមរយៈសេវាបើកប្រាក់បៀវត្សរ៍ និងអតិថិជននៅតាមជនបទ ដែលយើងបានបើកការិយាល័យប្រតិបត្តិការថ្មីៗ ព្រមទាំងការពង្រីកសេវាធនាគារតាមរយៈទូរស័ព្ទដៃ និងសេវាធនាគារតាមរយៈអ៊ីនធើណែត ។ គួរកត់សម្គាល់ផងដែរថា សមតុល្យប្រាក់បញ្ញើទាំងនោះអាចគ្របដណ្តប់លើសមតុល្យឥណទានដែលមានចំនួនជាង២.៧៧១លានដុល្លារអាមេរិក ។

ចំណុចសំខាន់ដែលធ្វើឱ្យមានកំណើនប្រាក់បញ្ញើ ដោយសារការបន្តអភិវឌ្ឍ និងពង្រីកប្រព័ន្ធបច្ចេកវិទ្យារបស់យើង ដែលនៅដំណាច់ឆ្នាំ២០១៦ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិអេធីអឹមចំនួន ៣00គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន ៣.១៣៧គ្រឿងទូទាំងប្រទេស ដោយបានបញ្ចេញឱ្យប្រើប្រាស់ប័ណ្ណឥណពន្ធ ចំនួន ៧៧៩.៨៩៤ ប័ណ្ណ ។

## ឥណទានខ្នាតមធ្យម និងសាជីវកម្ម

នៅឆ្នាំ២០១៦ ចំនួននៃប្រាក់កម្ចីក្នុងវិស័យនេះបានកើនឡើង ១៤,៧៥% ខណៈពេលដែលចំនួននៃអតិថិជនសហគ្រាសខ្នាតមធ្យម បានកើនឡើង ១៥,៥0% ។ លទ្ធផលទទួលបានជោគជ័យនេះ ដោយសារប្រជាប្រិយភាពនៃសេវាឥណទានវិបារូប៍ និងសេវាហិរញ្ញប្បទានពាណិជ្ជកម្មរបស់យើងខ្ញុំ ។

សេវាគ្រប់គ្រងសាច់ប្រាក់បានកើនឡើងយ៉ាងខ្លាំង តាមរយៈការរៀបចំរបស់យើងជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាល បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន សេវាបើកប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរដ្ឋាភិបាល និងសេវាប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។ ក្នុងនាមជាអ្នកគ្រប់គ្រងមូលនិធិរបស់បេឡាជាតិសន្តិសុខសង្គម ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអ្នកគ្រប់គ្រងទទួលរាល់ប្រាក់វិភាគទានរបស់រដ្ឋាភិបាល និងនិយោជក ទាំង២៥រាជធានី-ខេត្ត ។ លើសពីនេះទៀតគណនីថ្មីៗជាច្រើន ត្រូវបានបើកចាប់ពីឆ្នាំ២០១៤មក ដោយសារការបន្ថែមម៉ាស៊ីនអេធីអឹម និងការទូទាត់វិក្កយបត្រតាមរយៈសេវាអេស៊ីលីដាយូនីធី សម្រាប់ក្រុមហ៊ុនឯកជន និងបម្រើសេវាសាធារណៈទៅតាមបណ្តាខេត្តផ្សេងៗបន្ថែមទៀត ព្រមទាំងសេវាអេស៊ីលីដាអ៊ីនធើណែតផងដែរ ។ ការទទួលទូទាត់វិក្កយបត្ររបស់រតនាគារជាតិ ដែលដើមឡើយគ្របដណ្តប់តែតាមបណ្តាខេត្តមួយចំនួន ឥឡូវបានពង្រីកនៅទូទាំងប្រទេស ។ ទាំងនេះនាំឱ្យមានលទ្ធផលវិជ្ជមាន ទៅលើលំហូរសាច់ប្រាក់ជារូបិយប័ណ្ណក្នុងស្រុករបស់យើង និងអាចឱ្យយើងផ្តល់ឥណទានជាប្រាក់រៀលរបស់យើងទាំងស្រុងពីប្រាក់បញ្ញើ ។ តម្រូវការប្រើប្រាស់សេវាបើកប្រាក់បៀវត្សរ៍កើនឡើងខ្លាំង នៅក្នុងឆ្នាំ២០១៦ នេះដោយមានស្ថាប័នរដ្ឋាភិបាល និងមន្ត្រីរាជការ ព្រមទាំងក្រុមហ៊ុនក្រៅប្រទេសនិងក្នុងប្រទេសធំៗ និងស្ថាប័ននានាបានចូលរួមប្រើប្រាស់ ដែលជាឱកាសដ៏ល្អសម្រាប់ការលក់ផលិតផលផ្សេងៗទៀត ។

កិច្ចព្រមព្រៀងចែកចាយសេវាធានារ៉ាប់រងអាយុជីវិតរបស់យើង ជាមួយក្រុមហ៊ុនព្រូដិនសល បានរួមចំណែកយ៉ាងសំខាន់ក្នុងការធានាការផ្តល់មូលនិធិរយៈពេលវែងរបស់យើងខ្ញុំ និងគម្រោងការខ្លួនឯងបានផ្តល់នូវប្រភពដ៏មានសារប្រយោជន៍នៃប្រាក់ចំណូលតារាងតុល្យការ ។


សិប្បកម្មផលិតផើងផ្កា ក្នុងខេត្តបាត់ដំបង


សិប្បកម្មចម្លាក់ខ្មែរ ក្នុងរាជធានីភ្នំពេញ

សេវាហិរញ្ញប្បទានពាណិជ្ជកម្ម បានកើនឡើងយ៉ាងខ្លាំងមិនតែប៉ុណ្ណោះ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានទទួលពានរង្វាន់ជាធនាគារដៃគូឈានមុខគេ នៅក្នុងប្រទេសកម្ពុជា លើសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

## រតនាភិបាល និងអន្តរជាតិ

ចំណូលពីសេវាប្តូរប្រាក់បន្តកើនឡើង និងចូលរួមបង្កើនចំណូលលើកម្រៃជើងសារ និងចំណូលសុទ្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ដោយសារសេវាប្តូរប្រាក់របស់យើងគឺសម្រាប់តែគាំទ្រដល់អាជីវកម្ម របស់អតិថិជនប៉ុណ្ណោះ ធនាគារមិនបានធ្វើអាជីវកម្មក្នុងគោលបំណងបង្កើនប្រាក់ចំណូលទេ ប៉ុន្តែក្នុងគោលបំណងចាត់ចែងស្ថានភាពរូបិយប័ណ្ណចំហរបស់ធនាគារ ដែលជាប្រភពចំណូលមានហានិភ័យទាប និងមានស្ថិរភាព ហើយមានកំណើនជាលំដាប់ បង្កើតប្រាក់ចំណូលល្អប្រសើរ និងរក្សាទំនាក់ទំនងយូរអង្វែងជាមួយអតិថិជន និងអាជីវករប្តូរប្រាក់ ។

តារាងតុល្យការរបស់ធនាគារកាន់តែរឹងមាំថែមទៀត តាមរយៈកំណើនអតិថិជនបញ្ញើ-សន្សំយ៉ាងខ្លាំង ធ្វើឱ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើមានភាពល្អប្រសើរ និងជួយទ្រទ្រង់ដល់ការរីកចម្រើននៅលើទីផ្សារ ។

យើងនៅតែបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងបានបន្ថែមធនាគារដៃគូក្រៅប្រទេសថ្មីៗជាច្រើនថែមទៀត ដើម្បីបង្កើនបណ្តាញប្រតិបត្តិការរបស់យើងខ្ញុំ ។ នាដំណាច់ឆ្នាំ២០១៦ យើងមានធនាគារដៃគូចំនួន ៤០១ នៅក្នុង ៥៤ប្រទេស ។ បន្ថែមពីនេះទៀត យើងមានចំណែកទីផ្សារលើសលុបសម្រាប់គណនីរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងផ្តល់សេវាផ្ទេរប្រាក់ដល់អតិថិជនទូទាំងប្រទេស ។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៧

១. រក្សាមូលដ្ឋានដើមទុនរឹងមាំដោយមានដើមទុនបម្រុងគ្រប់គ្រាន់លើសពីបញ្ញត្តិតម្រូវ ។

២. ខិតខំយកចិត្តទុកដាក់អភិវឌ្ឍន៍ "វប្បធម៌បម្រើសេវា" របស់យើងឱ្យមានភាពងាយស្រួល និងឆាប់រហ័សដល់អតិថិជន និងបង្កើនសេវាកម្មរបស់យើងក្នុងពេលដែលទីផ្សារពង្រីកកាន់តែធំ ។

៣. បំពេញតាមតម្រូវការអតិថិជន ដោយផ្តល់ជូននូវនវានុវត្តន៍ហិរញ្ញវត្ថុយ៉ាងសំបូរបែប ក្នុងពេលដែលសេដ្ឋកិច្ចពួកគាត់ឈានឡើងជាលំដាប់ ។

៤. បង្កើនជម្រើសដៃគូដែលមានជំនាញ/ឯកទេសដើម្បីផ្តល់ហិរញ្ញវត្ថុមទៅដល់អតិថិជនធំៗ ។

៥. ផ្តោតលើការពង្រីកគុណភាពសេវាបន្ថែម ដើម្បីឱ្យមានចំណូលចម្រុះ និងបន្ថយការពឹងផ្អែកលើដើមទុន ដែលរួមបញ្ចូលទាំងកម្រៃបានពីការផ្តល់សេវាហិរញ្ញវត្ថុរដ្ឋាភិបាល ។

៦. បន្តវិនិយោគយ៉ាងខ្លាំងលើការស្រាវជ្រាវ និងការអភិវឌ្ឍ ដើម្បីរក្សានូវភាពឈានមុខគេនៃផលិតផលនិងសេវាកម្មស្នូលរបស់យើង ។

៧. វិនិយោគទៅលើប្រព័ន្ធពហុបណ្តាញ ។

៨. រៀបចំយុទ្ធសាស្ត្រ និងចាប់ដៃគូជាមួយនឹងស្ថាប័នធំៗនិងល្បីឈ្មោះទាំងក្នុងនិងក្រៅប្រទេស ក្នុងតំបន់សក្តានុពល ដើម្បីអភិវឌ្ឍ និងពង្រីកសេវាកម្មរបស់ធនាគារ ។

៩. បន្តអភិវឌ្ឍក្រុមហ៊ុនបុត្រសម្ព័ន្ធ ដើម្បីឱ្យមានជំហររឹងមាំប្រកបដោយលក្ខណសម្បត្តិក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារទាំងអស់ ដែលពួកគេកំពុងធ្វើប្រតិបត្តិការ ព្រមទាំងស្រាវជ្រាវ និងបង្កើតកាលានុវត្តភាពដើម្បីពង្រីកអាជីវកម្មនៅក្នុងតំបន់បន្ថែមទៀត នៅពេលដែលឱកាសផ្តល់ឱ្យ ។



រោងចក្រកាត់សំលៀកបំពាក់ ក្នុងរាជធានីភ្នំពេញ



សិប្បកម្មចម្លាក់ឈើដោយដៃ ក្នុងខេត្តត្បូងឃ្មុំ

១០. បង្កើតតួនាទីឈានមុខគេលើសេវាទូទាត់និងផាត់ទាត់ ដើម្បីពង្រីកទីផ្សារមូលធន ។

១១. បង្កើត និងអភិវឌ្ឍសេវាពហុហិរញ្ញប្បទាន និងសេវាហិរញ្ញប្បទានគម្រោងសម្រាប់ផ្តល់ជូនអតិថិជនធំៗ ព្រមទាំងសហការជាមួយស្ថាប័នដែលមានសក្តានុពល ដៃគូឯកទេស/ជំនាញ ដើម្បីរួមគ្នាអភិវឌ្ឍផលិតផលសម្រាប់បម្រើជូនដល់អតិថិជន ដើម្បីទទួលបានប្រាក់ចំណូលខ្ពស់ ។

១២. អភិវឌ្ឍសេវាធនាគារអេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិជ្ជា ហិរញ្ញវត្ថុ (FinTech) និងស្វ័យប្រតិបត្តិការ (Branchless) ដោយមានគោលដៅ ដើម្បីពង្រីកបណ្តាញប្រតិបត្តិការ បង្កើនប្រសិទ្ធភាពប្រាក់ចំណូល បង្កើនកាលានុវត្តភាពនៃការលក់ផលិតផលជាកញ្ចប់ បម្រើអតិថិជនគោលប្រកបដោយភាពងាយស្រួល និងមានឧត្តមភាពក្នុងការប្រកួតប្រជែង ។

១៣. អភិវឌ្ឍសេវាឌីជីថលប៉ែង (Digital Banking-Mobile App) សេវាអេស៊ីលីដាយូនីធីទាន់ចិត្ត, ប្រតិបត្តិការជាសកល តាមរយៈ ប្រព័ន្ធ Biometric និងប្រព័ន្ធគ្រប់គ្រងព័ត៌មានអតិថិជន រួមផ្សំជាមួយសេវាកម្មហិរញ្ញវត្ថុថ្មីៗ ដោយមានគោលដៅលើកស្ទួយ និងគាំទ្រសេវាស្វ័យប្រតិបត្តិការ (Self-service) ប្រើប្រាស់នូវបច្ចេកវិជ្ជាទំនើប ប្រសិទ្ធភាពចំណាយ ពង្រីកធុរកិច្ចជាសកល និងជួយគាំទ្រដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធ បង្កើនចំណូល បង្កើនកាលានុវត្តភាពនៃការលក់ផលិតផលជាកញ្ចប់ បម្រើអតិថិជនដោយភាពងាយស្រួល មានឧត្តមភាពក្នុងការប្រកួតប្រជែង ។

## បញ្ហាចម្បងក្នុងឆ្នាំ២០១៧

ការផ្លាស់ប្តូរបញ្ញត្តិពីការមិនកំណត់អត្រាការប្រាក់កម្ចីខ្នាតតូចបំផុត មកកំណត់នៅត្រឹម ១៨% ក្នុងមួយឆ្នាំ ។ សេចក្តីសម្រេចនេះនឹងអាចមានផលប៉ះពាល់ដល់ប្រាក់ចំណូលសម្រាប់ឆ្នាំ២០១៧ ដែលតម្រូវឱ្យធនាគារបង្កើនការផ្តល់ឥណទាន សម្រាប់សហគ្រាសខ្នាតតូច និងខ្នាតមធ្យមបន្ថែមទៀត ។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនដ៏វៃឆ្លាត ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ក្រុមប្រឹក្សាយោបល់ព្រមទាំងរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា ដែលបានគាំទ្រដល់ធនាគារអេស៊ីលីដា ភីអិលស៊ី ។ យើងខ្ញុំសូមជូនពរដល់លោកអ្នក និងក្រុមគ្រួសារទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ជោគជ័យក្នុងនាទីការងារនិងមុខជំនួញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តមកុំបីឃ្លៀងឃ្លាតឡើយ ។



បណ្ឌិត អ៊ិន ចាន់នី

*ប្រធាននាយកប្រតិបត្តិ*

ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧



ចំការសណ្តែកគួ ក្នុងខេត្តបាត់ដំបង



កសិដ្ឋានចិញ្ចឹមមាន់ ក្នុងខេត្តកណ្តាល

# អង្គការលេខ



ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំងនៃក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មនៃក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការឥណទាននៃក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល
ប្រធាននាយកប្រតិបត្តិ
គណៈកម្មាធិការប្រតិបត្តិ
អេស៊ីលីដា ការិយាល័យតំណាង
ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា
ធនាគារ អេស៊ីលីដា ឡាវ
អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
អេស៊ីលីដា ប្រូភើធី អិលធីឌី
គណៈកម្មាធិការឥណទាន
គណៈកម្មាធិការធនធានមនុស្ស ទទួលខុសត្រូវបញ្ហាអេដស៍
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
គណៈកម្មាធិការ Implementation & Conversion of IFRS
គណៈកម្មាធិការគាំទ្រអាជីវកម្ម និងអនុគណៈកម្មាធិការគាំទ្រអាជីវកម្ម
គណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម
គណៈកម្មាធិការគម្រោងប្រព័ន្ធធនាគារអេឡិចត្រូនិក
គណៈកម្មាធិការ Information Security Management System
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង
នាយកប្រតិបត្តិឥណទាន
នាយកប្រតិបត្តិប្រតិបត្តិការ
នាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្ម
នាយកប្រតិបត្តិសេវាឥណទាន
នាយិកាប្រតិបត្តិទីផ្សារ
នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុ
នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
នាយកប្រតិបត្តិបច្ចេកវិជ្ជាព័ត៌មាន
នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា
នាយកការិយាល័យគ្រប់គ្រងហានិភ័យ
នាយិកាប្រតិបត្តិប្រតិបត្តិការហិរញ្ញវត្ថុ
នាយកការិយាល័យរតនាភិបាល
នាយកការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ
នាយកការិយាល័យរតនពាណិជ្ជកម្ម
នាយកប្រតិបត្តិនីតិកម្ម
នាយកការិយាល័យប្រឹក្សាបុគ្គលសម្ព័ន្ធ
នាយកការិយាល័យលេខាធិការក្រុមហ៊ុន
នាយិកាការិយាល័យគ្រប់គ្រងវិវាទ
នាយកប្រតិបត្តិធនធានមនុស្ស
នាយកប្រតិបត្តិរដ្ឋបាល
នាយិកាការិយាល័យគ្រប់គ្រងប្រព័ន្ធ SWIFT
នាយកប្រតិបត្តិអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
នាយកការិយាល័យរបាយការណ៍សវនកម្ម
នាយកការិយាល័យសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា
នាយកការិយាល័យសវនកម្មឥណទាន
នាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ
នាយកការិយាល័យ សវនកម្មប្រាក់បញ្ញើ និងផ្ទេរប្រាក់
នាយកការិយាល័យប្រតិបត្តិ
២៥៩ សាខា គ្របដណ្តប់ទូទាំងប្រទេស
(មានបង្ហាញជូននៅទំព័រទី ១១៧)

# បណ្ដាញប្រតិបត្តិការ

ធនាគារអេស៊ីលីដា មានសាខា
ចំនួន ២៥៩ គ្របដណ្ដប់គ្រប់ខេត្ត និងរាជធានី នៅព្រះរាជាណាចក្រកម្ពុជា
និងចំនួន ៤១ សាខា នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រមទាំង
៦ សាខា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។



# អភិបាលកិច្ចសាជីវកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលស្គាល់នូវលក្ខណៈដ៏សំខាន់នៃអភិបាលកិច្ចសាជីវកម្ម ដើម្បីគាំទ្រពីស្ថិរភាពនៃការរីកចម្រើនរបស់ធនាគារ បង្កើនប្រសិទ្ធភាព ការងារ និងប្រាក់ចំណេញ បង្កើនតម្លៃរបស់ភាគទុនិក និងជំនឿទុកចិត្តដល់ភាគទុនិក អតិថិជន បុគ្គលិក ព្រមទាំងសាធារណជនទូទៅ ។ ក្រុមប្រឹក្សាភិបាលគាំទ្រ និងលើកទឹកចិត្តឱ្យអនុវត្តគោលនយោបាយអភិបាលកិច្ចសាជីវកម្ម រួមទាំងក្រមសីលធម៌ ។

## កិច្ចប្រជុំភាគទុនិក

ធនាគារ អេស៊ីលីដា ភីអិលស៊ី បើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគទុនិក ដោយអនុលោមទៅតាមច្បាប់ លក្ខន្តិកៈ និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទង ។ ក្នុងឆ្នាំ២០១៦ កិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគទុនិកបានប្រព្រឹត្តិទៅនៅការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ និងបានប្រជុំសម្រេចតាមអ៊ីម៉ែល ចំនួន៥ដងបន្ថែមទៀតនៅក្នុងឆ្នាំនោះ ។ ធនាគារបានប្រតិបត្តិដូចខាងក្រោម ៖

### មុនបើកកិច្ចប្រជុំ

ធនាគារបានរៀបចំឯកសារមួយចំនួន ជាភាសាអង់គ្លេស និងបានផ្ញើជូនភាគទុនិកទាំងអស់ មុនពេលបើកកិច្ចប្រជុំ ។ ឯកសារទាំងនោះមានដូចជា ៖ កំណត់សម្គាល់ក្នុងកិច្ចប្រជុំ របៀបវារៈលម្អិត តួលេខសំខាន់ៗ សេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល ឯកសារគាំទ្រ របាយការណ៍ប្រចាំឆ្នាំ២០១៥ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សវនករខាងក្រៅ ។

### អំឡុងពេលប្រជុំ

កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ២០១៦ បានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ។ ភាគទុនិកទាំងអស់មានឱកាសគ្រប់គ្រាន់ដើម្បីសាកសួរ និងផ្តល់អនុសាសន៍ព្រមទាំងអាចស្នើសុំពន្យល់ ឬបញ្ជាក់បញ្ហាផ្សេងៗពីប្រធានក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង ។ កំណត់ហេតុប្រជុំ និងមតិអនុម័ត ត្រូវបានកត់ត្រាដោយលេខាធិការក្រុមហ៊ុន របស់ធនាគារ ។

ចំណុចចម្បងៗដែលបានអនុម័ត ក្នុងឆ្នាំ២០១៦ មាន ៖

- អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួមបានធ្វើសវនកម្ម សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសបានធ្វើសវនកម្មឆ្នាំ២០១៦ ។
- អនុម័តការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥ នៃប្រាក់ចំណេញក្រោយដកពន្ធ និងផ្ទេរប្រាក់ចំណេញក្រោយដកពន្ធដែលនៅសល់ទៅជាទុនបម្រុងរបស់ធនាគារ ។
- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- តែងតាំងសវនករខាងក្រៅ សម្រាប់ឆ្នាំ២០១៧-២០១៨ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តផែនការយុទ្ធសាស្ត្រ និងផែនការថវិការបស់ធនាគារ ។
- ពិនិត្យឡើងវិញ និងអនុម័តគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ។
- តែងតាំង និងតែងតាំងឡើងវិញរបស់អភិបាលនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តការបន្ថែមដើមទុនសម្រាប់វិនិយោគបន្ថែមទៀត និងថវិកាសម្រាប់គម្រោងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- អនុម័តប្រាក់កម្ចីពហុហិរញ្ញប្បទានអាទិភាព និងឥណទានបន្ទាប់បន្សំ ពីម្ចាស់ជំនួយជាតិនិងអន្តរជាតិ ។

### បន្ទាប់ពីប្រជុំ

កំណត់ហេតុកិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ២០១៦ ត្រូវបានផ្ញើជូនគ្រប់ភាគទុនិកទាំងអស់ ដើម្បីជ្រាបជាព័ត៌មាន និងសម្រាប់កិច្ចប្រជុំបន្ទាប់ ។

## ភាគទុនិក

ភាគទុនិក គឺជាម្ចាស់របស់ធនាគារ ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្ត្រនានា ប៉ុន្តែភាគទុនិកពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីយ៉ាងណាក៏ដោយ ភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះទៅឱ្យក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារ ។

### អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ជាអ្នកបន្តវេនពី អង្គការ អេស៊ីលីដា ដោយអនុលោមតាមអនុក្រឹត្យលេខ: ៤៧៦ អនក្រ-បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងប្រកាសលេខ: ១០៤១ សហវ-ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ បានទទួលវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ លេខ: ២៦៩ សហវ.អឧហ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យចុះបញ្ជីនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ មានគោលបំណង និងតួនាទីដូចខាងក្រោម៖

- បង្កើតនូវកាលានុវត្តភាពការងារ និងផ្តល់ប្រភពចំណូល ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ។
- ជួយលើកស្ទួយ និងជួយគាំទ្រដល់ការរីកចម្រើន នៃវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច រួមមាន វិស័យធនាគារ និងហិរញ្ញវត្ថុ និងផ្តោតសំខាន់ ទៅលើចំណេះដឹងផ្នែកហិរញ្ញវត្ថុ ។
- លើកស្ទួយកាលានុវត្តភាពសេដ្ឋកិច្ច និងអប់រំដល់យុវជន និងប្រជាពលរដ្ឋដែលមានចំណូលទាប ។
- ចូលរួមចំណែកការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មហិរញ្ញវត្ថុ តាមរយៈធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ។

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ជាភាគទុនិកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានបង្កើតឡើង អនុលោមតាមច្បាប់នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានគោលដៅលើកទឹកចិត្តដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ឱ្យប្រកាន់ខ្ជាប់នូវគោលបំណង ដើម្បីគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម និងរក្សានូវសញ្ជាតិជាក្រុមហ៊ុនខ្មែរ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ត្រូវបន្តអនុវត្តដោយផ្ទាល់ និងដាច់ដោយឡែកនូវគោលបំណងមិនរកប្រាក់ចំណេញ ដូចបានរៀបរាប់ខាងលើ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ធ្វើសកម្មភាពជាប្រយោជន៍ដល់ជនទូទៅ និងមិនអនុវត្តគោលបំណងចម្បង ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មឯកជនផ្ទាល់ខ្លួនឡើយ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ មិនមែនជាស្ថាប័ននយោបាយ និងមិនចំណុះឱ្យគណៈបក្សនយោបាយណាមួយឡើយ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ អាចប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុដូចបានកំណត់ក្នុងអនុស្សរណៈ និងលក្ខន្តិកៈ នេះតែប៉ុណ្ណោះ ។ គ្មានបុគ្គល

ណាមួយទទួលបានអត្ថប្រយោជន៍ពីការផ្តល់តម្លៃការខ្ពស់ដោយវិសមាមាត្រ ឬទទួលបានពីការចំណាយ ដែលផ្ទុយទៅនឹងគោលបំណងនៃ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ឡើយ ។

## ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី ( ASA, Plc. )

សមាគមបុគ្គលិកអេស៊ីលីដា ( ASA, Plc. ) បានបង្កើតឡើងក្នុងលក្ខណៈជាក្រុមហ៊ុនកាន់កាប់ភាគហ៊ុនមួយ និងជាយន្តការមួយដែលបុគ្គលិកអាចចូលរួមនៅក្នុងការរីកចម្រើនរយៈពេលវែង និងការបង្កើនតម្លៃភាគហ៊ុននៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការធ្វើជាម្ចាស់ផលប្រយោជន៍នៅក្នុងភាគហ៊ុនរបស់ធនាគារ និងដើម្បីចូលរួមក្នុងសកម្មភាពផ្សេងទៀតដែលមានសារៈសំខាន់ និងមានហេតុផលសមរម្យ, ការវិនិច្ឆ័យនៃក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ, និងការសម្រេចគោលបំណងខាងមុខនេះ ។

## COFIBRED – Compagnie Financière de la BRED ( BRED's financial company )

COFIBRED គឺជាបុត្រសម្ព័ន្ធពេញលេញរបស់ BRED BanquePopulaire ។ ដោយសារសកម្មភាព BRED អភិវឌ្ឍន៍ខ្លាំងលើឆាកអន្តរជាតិ នៅឆ្នាំ២០០៨ ក៏សម្រេចឱ្យមានការរៀបចំបុត្រសម្ព័ន្ធ និងផ្នែកដែលពាក់ព័ន្ធទាំងអស់ស្ថិតនៅក្នុងស្ថាប័នតែមួយ ដោយមានឈ្មោះថា Cofibred ។ ភាគហ៊ុនរបស់ Cofibred បានមកពីបុត្រសម្ព័ន្ធ និងស្ថាប័នដែលពាក់ព័ន្ធចំនួនជាង ៤៥ ដែលមានទឹកប្រាក់សរុបប្រហែល ១៣ាន់លានអឺរ៉ូ ក្នុងវិស័យធនាគារ ធានារ៉ាប់រងអ៊ីខុមមើស និង/ឬក្រុមហ៊ុនហិរញ្ញវត្ថុ ( ប្រាក់ចំណេញសុទ្ធឆ្នាំ២០១៦ មានចំនួន ១៣,២លានអឺរ៉ូ ) ។ បុត្រសម្ព័ន្ធ និងស្ថាប័នដែលពាក់ព័ន្ធទាំងនេះស្ថិតនៅក្នុងទ្វីបចំនួន៥ ទូទាំងពិភពលោក ។

## Sumitomo Mitsui Banking Corporation ( SMBC )

SMBC គឺជាធនាគារជប៉ុនធំមួយដែលប្រតិបត្តិការទូទាំងពិភពលោក និងមានទ្រព្យសកម្មចំនួន ១៥៨.៣៩៦,៦ ពាន់លានយេន អនុបាតដើមទុនថ្នាក់ទី១ គឺ ១៤,០២%, ព្រមទាំងទទួលបានចំណាត់ថ្នាក់ A ( ពីS&P's ) និង A1 ( ពីMoody's ) ត្រឹមខែធ្នូ ឆ្នាំ២០១៦ ។ តាមរយៈសាខាក្នុងស្រុកចំនួន ៤៤០ ( មិនរាប់បញ្ចូលអនុសាខា និងភ្នាក់ងារធនាគារ ) ក្នុងប្រទេសជប៉ុន និងមានសាខាក្រៅប្រទេសចំនួន ៧៣ ( រាប់បញ្ចូលទាំងបុត្រសម្ព័ន្ធ អនុសាខា និងការិយាល័យតំណាង ) នៅទូទាំងពិភពលោក ។ SMBC ផ្តល់សេវាកម្មយ៉ាងសម្បូរបែបមានដូចជាប្រាក់បញ្ញើ, សាជីវកម្មហិរញ្ញវត្ថុ, ការវិនិយោគមូលបត្រ, ផ្ទេរប្រាក់, ប្តូរប្រាក់, សេវាអាជ្ញាប័ណ្ណបំណុលសាជីវកម្ម និងសេវាកម្មប្រអប់បញ្ញើសុវត្ថិភាព, ធានាទិញមូលបត្រហិរញ្ញវត្ថុនាពេលអនាគត និងសេវា Investment Trust Sales ។

"ដើម្បីក្លាយជាស្ថាប័នផ្តោតលើតំបន់អាស៊ីយ៉ាងពិតប្រាកដ" ដែលជាទិសដៅមួយក្នុងចំណោមទិសដៅទាំងអស់នៃទស្សនៈចម្បងៗ របស់ SMBC សម្រាប់ទសវត្សរ៍បន្ទាប់ ។ SMBC បានវិនិយោគធនធានរបស់ខ្លួនយ៉ាងសកម្មក្នុងប្រទេសជាច្រើននៅតំបន់អាស៊ី ដែលមានសក្តានុពលរីកចម្រើនខ្លាំង ។ ដើម្បីផ្តល់ជូនអតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបាននូវសេវាកម្មហិរញ្ញវត្ថុសមាហ័រណកម្មបានល្អប្រសើរ SMBC បានផ្តល់អ្នកជំនាញជាន់ខ្ពស់មកបម្រើការជាទីប្រឹក្សា នៅក្នុងផ្នែកសាជីវកម្មអន្តរជាតិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីឆ្នាំ២០១៣ មក ។

ក្រុមហ៊ុនមេរបស់ SMBC គឺ Sumitomo Mitsui Financial Group, Inc. ( SMFG ) បានចុះបញ្ជីនៅផ្សារភាគហ៊ុនតូក្យូ, Nagoya និង New York និងមានមូលធនប្រហែល ៥៥ពាន់លានដុល្លារអាមេរិក គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០១៧ ។ សម្រាប់ព័ត៌មានបន្ថែមអំពី SMBC សូមទស្សនាវេបសាយ ៖ www.smfg.co.jp/english ។

## ORIX Corporation

ក្រុមហ៊ុន ORIX ( TSE: 8591; NYSE: IX ) ជាក្រុមហ៊ុនកាលានុវត្ត, វិនិយោគចម្រុះ, ការបង្កើតថ្មីទូទាំងពិភពលោក ដែលបង្ហាញឱ្យឃើញ កំណត់ត្រានៃការទទួលបានប្រាក់ចំណេញ ។ ORIX បានបង្កើតឡើងនៅឆ្នាំ១៩៦៤ ហើយបច្ចុប្បន្នកំពុងធ្វើប្រតិបត្តិការអាជីវកម្មផលបត្រចម្រុះ, សេវាហិរញ្ញវត្ថុ និងការវិនិយោគផ្សេងៗ ។ សកម្មភាពអាជីវកម្មក្នុងវិស័យជាច្រើនរបស់ក្រុមហ៊ុន Orix មានដូចជា ៖ ថាមពល, មូលធនឯកជន, ហេដ្ឋារចនាសម្ព័ន្ធ, រថយន្ត, នាវា និងយន្តហោះ, អចលនទ្រព្យ និងសេវាកម្មហិរញ្ញវត្ថុលក់រាយផ្សេងៗទៀត ។ ក្រុមហ៊ុន Orix បានពង្រីកអាជីវកម្មរបស់ខ្លួននៅទូទាំងពិភពលោក ដោយបង្កើតទីតាំងជាច្រើននៅក្នុង ៣៧ ប្រទេស និងតំបន់ផ្សេងៗនៅទូទាំងពិភពលោក ។ តាមរយៈសកម្មភាពអាជីវកម្មទាំងនេះ ធ្វើឱ្យក្រុមហ៊ុន Orix បាន ប្តេជ្ញាធ្វើជាក្រុមហ៊ុនសម្រាប់ប្រជាជន និងចីរភាពបរិស្ថាន ។ សម្រាប់ព័ត៌មានបន្ថែម សូមទស្សនាវេបសាយ ៖ www.orix.co.jp/grp/en/ ។

## Triodos Sustainable Finance Foundation, Triodos Fair Share Fund និង Triodos Microfinance Fund

Triodos Sustainable Finance Foundation ( បង្កើតឡើងពី Triodos-Doen Foundation ), Triodos Fair Share Fund និង Triodos Microfinance Fund គឺជាមូលនិធិវិនិយោគបី គ្រប់គ្រងដោយ Triodos Investment Management ។ Triodos Investment Management គឺជាបុត្រសម្ព័ន្ធពេញលេញ និងកាន់កាប់ភាគហ៊ុនចំនួន ១០០% ដោយធនាគារ Triodos ដែលជាធនាគារមួយ មាននិរន្តរភាពឈានមុខគេនៅលើពិភពលោក ។ មូលនិធិនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាហិរញ្ញវត្ថុជូន ប្រជាជន និងសហគ្រាសខ្នាតតូច និងមធ្យមដែលមានចំណូលទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដើម្បីរួមចំណែកក្នុងវិស័យហិរញ្ញវត្ថុមួយប្រកបដោយនិរន្តរភាព ។

## Triodos Sustainable Finance Foundation

Triodos Sustainable Finance Foundation មានគំនិតផ្តួចផ្តើមផ្តល់ហិរញ្ញវត្ថុដែលជួយពន្លឿនស្ថិរភាពនៃ ការអភិវឌ្ឍទូទាំងពិភពលោក ដោយផ្តោតលើសេវាហិរញ្ញវត្ថុគ្រប់ប្រភេទ ។

## Triodos Fair Share Fund

Triodos Fair Share Fund បានបង្កើតឡើងនាឆ្នាំ២០០២ ក្នុងប្រទេសហុល្លង់ដ៍ គឺជាមូលនិធិដំបូងគេបង្អស់ និងដ៏កម្រនៅក្នុងពិភពលោក ដែលផ្តល់ឱកាសដល់សាធារណជនទូទៅក្នុងការវិនិយោគក្នុងស្ថាប័ន មីក្រូហិរញ្ញវត្ថុ និងធនាគារ ។ នៅចុងឆ្នាំ២០១៦ ទ្រព្យសកម្មសរុបរបស់មូលនិធិនេះមានចំនួន ៣២៥លានអឺរ៉ូ ។

## Triodos Microfinance Fund

Triodos Microfinance Fund បានបង្កើតឡើងនៅក្នុង ឆ្នាំ២០០៩ និងជាមូលនិធិបើកដោយមានភាគហ៊ុន របស់អ្នកវិនិយោគ អ្នកមានទ្រព្យសម្បត្តិច្រើន និងអតិថិជនធនាគារឯកជននៅពាសពេញទ្វីបអឺរ៉ុប ។ សកម្មភាពចម្បងរបស់មូលនិធិនេះ ផ្តោតលើការបង្កើតស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារដែលមានឯកសារបញ្ជាក់ត្រឹមត្រូវ ។ នៅចុងឆ្នាំ២០១៦ ទ្រព្យសកម្មសរុបរបស់មូលនិធិនេះ មានចំនួន ៣៥៧ លានអឺរ៉ូ ។

# ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគទុនិក សម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យពួកគេផ្ទាល់ ។ តាមលក្ខន្តិកៈបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមាន ១០រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ របស់ធនាគារ និងគ្រប់គ្រងរាល់ប្រតិបត្តិការអាជីវកម្ម ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវធ្វើកិច្ចការដើម្បីជាប្រយោជន៍ខ្ពស់បំផុតសម្រាប់ធនាគារ ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាណាម្នាក់មានអំណាចក្នុងការផ្តល់ការណែនាំ ឬបង្គាប់បញ្ជាតែឯកឯងលើថ្នាក់ដឹកនាំ ឬបុគ្គលិកណាម្នាក់របស់ធនាគារ ឬចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែមានការផ្ទេរអំណាចជាក់លាក់ឱ្យអនុវត្ត តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាម្នាក់ៗ អាចពិនិត្យដោយគ្មានកំណត់ ចំពោះឯកសារ និងកំណត់ត្រាផ្សេងៗរបស់ធនាគារ គ្រប់ពេលម៉ោងធ្វើការ ។

ក្រុមប្រឹក្សាភិបាល ធ្វើការជ្រើសតាំងនូវសមាជិកម្នាក់ ឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត ដោយយកតាមសំឡេងភាគច្រើន ហើយបុគ្គលនោះជាអ្នកដឹកនាំ នូវរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាមហាសន្និបាតប្រចាំឆ្នាំ ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ ។ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្សដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើតយុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រង ដើម្បីដាក់ឱ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការ ចំនួន៥ ដូចជា គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់, គណៈកម្មាធិការឥណទាន, គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង, និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ព្រមទាំងបង្កើតនូវគណៈកម្មាធិការផ្សេងទៀត អាស្រ័យទៅតាមតម្រូវការចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ។ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងអាស្រ័យទៅនឹងក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៅក្នុងគណៈកម្មាធិការ នឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការទាំងនេះ មិនអនុវត្តអំណាចរបស់ក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចជាផ្លូវការ តែត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ចំពោះសកម្មភាពរួមរបស់ពួកគេ ។ គួរបញ្ជាក់ផងដែរថា សមាជិកភាពនៃគណៈកម្មាធិការមិនកំណត់ថា ត្រូវតែជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលនោះទេ ពោលគឺអាចជាអ្នកគ្រប់គ្រង ឬបុគ្គលណាផ្សេងទៀត ដែលសមស្របក្នុងតួនាទីរបស់គណៈកម្មាធិការនីមួយៗ ។ ប៉ុន្តែប្រធាននៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺចាំបាច់ត្រូវតែជាសមាជិក-សមាជិការបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់, និងគណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង អាចដឹកនាំអភិបាលឯករាជ្យ ។

ចំពោះអត្ថបទពេញលេញស្តីពី គណៈកម្មាធិការក្រុមប្រឹក្សាភិបាល សមាជិកភាព និងសកម្មភាពប្រចាំឆ្នាំ២០១៦ មានបង្ហាញជូននៅក្នុងទំព័រទី៣២ ដល់ ៣៥ ក្នុងរបាយការណ៍នេះ ។



(ពីឆ្វេងទៅស្តាំ) លោកស្រី Femke BOS, លោក Yoshiaki MATSUOKA, លោក រ័ត្ន យូម៉េង, កញ្ញា Heng Su Yin,
លោក ឆាយ សឿន, លោក Marc ROBERT, បណ្ឌិត អ៊ិន ចាន់នី, បណ្ឌិត Pieter KOOI, លោក Cornelius OBERT, លោក Ian S. LYDALL



## លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់, គណៈកម្មាធិការឥណទាន

ជនជាតិខ្មែរ កើតក្នុងខែមេសា ឆ្នាំ១៩៥៤ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែកញ្ញា ឆ្នាំ២០១៤ ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក ។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ ។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោកនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ ។ លោកធ្លាប់ធ្វើជាគណនេយ្យករ និងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពត ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២ ។

បច្ចុប្បន្នលោកជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី, សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ឡាវ, និងសមាជិកក្រុមប្រឹក្សាភិបាលនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ។



## បណ្ឌិត អ៊ិន ចាន់នី អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ គ្រាស់ ។

ក្រៅពីមុខងារ និងតួនាទីនៅក្នុងអេស៊ីលីដា លោកបណ្ឌិតគឺជាប្រធានសមាគមពាណិជ្ជកម្មនិងវិនិយោគកម្ពុជា-ជប៉ុន (ស.ព.វ.ក.ជ) និងសមាជិកអនុគណៈកម្មាធិការរាជរដ្ឋាភិបាលសម្រាប់អភិបាលកិច្ចសាជីវកម្ម ។ លោកបណ្ឌិតជាអ្នកតំណាងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រងស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។



**លោក វ័ត្ត យូម៉េង** អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២ ។ លោក វ័ត្ត យូម៉េង បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែកញ្ញា ឆ្នាំ២០១៤ ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ ។ ចាប់ពីឆ្នាំ១៩៩២ រហូតមកដល់ខែមីនា ឆ្នាំ១៩៩៦ លោកបានបម្រើការជាជំនួយការហិរញ្ញវត្ថុរបស់គម្រោងពីរក្នុងប្រទេសកម្ពុជា គឺគម្រោង CMB/92/010 (ជាគម្រោងសម្រាប់លើកកម្ពស់សហគ្រាសខ្នាតតូច) និងគម្រោង CBM/95/010 (ជាគម្រោងសម្រាប់កាត់បន្ថយភាពក្រីក្រតាមរយៈសេវាហិរញ្ញវត្ថុអេស៊ីលីដា) ។ គម្រោងទាំងពីរត្រូវបានគ្រប់គ្រងដោយអង្គការពលកម្មអន្តរជាតិ (ILO) និងបានទទួលមូលនិធិពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ។ ចាប់ពីខែមេសា ឆ្នាំ១៩៩៦ រហូតដល់ ឆ្នាំ១៩៩៨ លោកបានបម្រើការជាជំនួយការហិរញ្ញវត្ថុឱ្យស្ថានទូតសហរដ្ឋអាមេរិក ប្រចាំទីក្រុងភ្នំពេញ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ រហូតដល់បច្ចុប្បន្ន លោកបានបម្រើការឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងតំណែងជាច្រើនដូចជា ជាប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែឧសភា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧), ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។ ចាប់ពីឆ្នាំ២០០១ រហូតដល់ខែកញ្ញា ឆ្នាំ២០១៤ លោកក៏ជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី ដែលជាភាគទុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។



**បណ្ឌិត** Pieter KOOI អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (ប្រធាន), គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ (ប្រធាន), គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម

ជនជាតិហុល្លង់ដ៍ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០ ។ លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហុល្លង់ដ៍ ។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ ។ ចាប់ពីឆ្នាំ១៩៩៩ បណ្ឌិត Pieter KOOI បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ប្រទេសដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូយ៉ក ។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារអេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេនីង សេនធ័រ, និងអេស៊ីលីដា ស៊ីយូរិធី ភីអិលស៊ី ។ បច្ចុប្បន្នលោកធ្វើជាក្រុមប្រឹក្សាភិបាលនៅក្នុងស្ថាប័នជាច្រើន និងផ្តល់ការប្រឹក្សារយៈពេលខ្លី ហើយថែមទាំងបង្ហាត់បង្រៀនអំពីមីក្រូហិរញ្ញវត្ថុ អភិបាលកិច្ច និងយុទ្ធសាស្ត្រគ្រប់គ្រង ។ លោកបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន ។



**កញ្ញា** HENG Su Yin **អភិបាល**

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង

ជនជាតិសិង្ហបុរី បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែធ្នូ ឆ្នាំ២០១៦ ។ កញ្ញា Heng Su Yin បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យ Nanyang Technological នៅក្នុងឆ្នាំ២០០១ និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MIT-Tsinghua) ពីសាកលវិទ្យាល័យ Tsinghua (សាលាសេដ្ឋកិច្ច និងគ្រប់គ្រង) នៅក្នុងឆ្នាំ២០១៣ ។ កញ្ញាបានចាប់ផ្តើមបម្រើការងារជាមួយអាជ្ញាធរគ្រប់គ្រងរូបិយវត្ថុសិង្ហបុរី បន្ទាប់មកក៏បានកាន់កាប់តំណែងជាច្រើន នៅក្នុងទីផ្សារមូលធនរបស់ធនាគារ Sumitomo Mitsui Banking Corporation (SMBC) និង Standard Chartered Bank ។ បច្ចុប្បន្នកញ្ញាមានតួនាទីជានាយិកាទីមួយ នៅក្នុងនាយកដ្ឋានកំណើនទីផ្សារអាស៊ី ដោយទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្រ របស់ធនាគារ SMBC ។



## លោកស្រី Femke BOS អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការឥណទាន (ប្រធាន), គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ជនជាតិហុល្លង់ដ៍ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែសីហា ឆ្នាំ២០០២ ។ លោកស្រី Femke BOS គឺជានាយិកាគ្រប់គ្រងមូលនិធិវិនិយោគសំខាន់ៗពីរ នៅក្នុង Triodos Investment Management ដែលជាបុត្រសម្ព័ន្ធពេញលេញរបស់ធនាគារ Triodos នៅក្នុងប្រទេសហុល្លង់ដ៍ ។ លោកស្រីបានបម្រើការងារនៅក្នុង Triodos Investment Management ក្នុងឆ្នាំ២០០២ ក្នុងតួនាទីជាមន្ត្រីវិនិយោគជាន់ខ្ពស់សម្រាប់អាស៊ី ។ លោកស្រី Femke BOS មានបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងវិស័យហិរញ្ញវត្ថុ ទាំងនៅទ្វីបអឺរ៉ុប និងក្នុងទីផ្សារទើបតែចាប់ផ្តើមរីកចម្រើននិងទីផ្សារដែលមានព្រំដែន ។ លោកស្រីធ្លាប់ធ្វើជាសមាជិកាក្រុមប្រឹក្សាភិបាលរបស់ស្ថាប័នហិរញ្ញវត្ថុជាច្រើនទូទាំងតំបន់អាស៊ី ហើយបច្ចុប្បន្នលោកស្រីជាសមាជិកាក្រុមប្រឹក្សាភិបាលរបស់ Dawn Microfinance ក្នុងប្រទេសមីយ៉ាន់ម៉ា ។ មុនពេលចូលបម្រើការក្នុង Triodos Investment Management លោកស្រីបានបម្រើការងារ ក្នុងតំណែងថ្នាក់គ្រប់គ្រងជាច្រើននៅធនាគារ ABN AMRO ក្នុងប្រទេសហុល្លង់ដ៍ ។ លោកស្រីបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកនីតិសាស្រ្ត ពីសាកលវិទ្យាល័យ Amsterdam ក្នុងឆ្នាំ១៩៩៤ ។ នៅឆ្នាំ២០០៦ លោកស្រីបានចូលរួមវគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុនអន្តរជាតិរបស់វិទ្យាស្ថានអូស្រ្តាលីសម្រាប់អភិបាលក្រុមហ៊ុន នៅទីក្រុង Perth ប្រទេសអូស្រ្តាលី ។



## លោក Cornelius OBERT អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (ប្រធាន), គណៈកម្មាធិការឥណទាន, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ជនជាតិអាល្លឺម៉ង់ កើតក្នុងឆ្នាំ១៩៥០ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកបានបញ្ចប់ការសិក្សានៅឆ្នាំ១៩៧៦ ដោយទទួលបានសញ្ញាបត្រផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងពីសាកលវិទ្យាល័យ Hamburg ។ លោកធ្លាប់ធ្វើជានាយកគ្រប់គ្រង និងសមាជិកប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលរបស់ Commerzbank International SA Luxembourg និងធ្លាប់ធ្វើជាអគ្គនាយក Commerzbank AG, សាខា Johannesburg ។ ទទួលខុសត្រូវលើជំនួញសាជីវកម្ម រតនាគារ ជំនួញលោហៈមានតម្លៃ និងហិរញ្ញប្បទានពាណិជ្ជកម្ម ។



## លោក Ian S. LYDALL អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង (ប្រធាន), គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់

ជនជាតិអង់គ្លេស កើតក្នុងឆ្នាំ១៩៥៥ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកធ្លាប់ធ្វើជានាយកប្រតិបត្តិ និងបន្ទាប់មកជាប្រធានក្រុមហ៊ុន PwC នៅប្រទេសវៀតណាម ។ លោកបានចូលនិវត្តន៍ពីក្រុមហ៊ុននេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ។ លោកមានបំណងរួមចំណែកជាមួយធនាគារអេស៊ីលីដា ដោយប្រើប្រាស់បទពិសោធន៍របស់លោកខាងផ្នែករបាយការណ៍ហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ យុទ្ធសាស្រ្ត និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ និងស៊ីជម្រៅទាក់ទងនឹងសេវាហិរញ្ញវត្ថុ ។



## **លោក** Marc ROBERT អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង, គណៈកម្មាធិការតណាទាន

ជនជាតិបារាំង កើតក្នុងឆ្នាំ១៩៧៣ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកបានបញ្ចប់ការសិក្សាពី ESSEC និង Science Po Paris ព្រមទាំងទទួលបានសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ California Davis និងសាកលវិទ្យាល័យ Toulouse ក្នុងឆ្នាំ២០០៣ ។ លោកបានចាប់ផ្តើមការងារខាងផ្នែកមូលនិធិរូបិយវត្ថុអន្តរជាតិ និងក្រោយមកទៀតធ្វើជាក្រុមប្រឹក្សាភិបាលគ្រប់គ្រងធនាគារអឺរ៉ុបមួយចំនួន ។ បច្ចុប្បន្នលោកបម្រើការនៅ BRED Banque Populaire ក្នុងតួនាទីជាសមាជិកនៃថ្នាក់គ្រប់គ្រងក្រុមប្រឹក្សាភិបាល និងជាប្រធានអន្តរជាតិ ដោយទទួលបន្ទុកគ្រប់គ្រងបុត្រសម្ព័ន្ធក្រៅប្រទេស ចំនួន ១២ នៅជុំវិញពិភពលោក ។



## **លោក** Yoshiaki MATSUOKA អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង

ជនជាតិជប៉ុន កើតក្នុងឆ្នាំ១៩៦៨ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ និងបានចូលជាសមាជិកគណៈកម្មាធិការផ្តល់តម្លៃការនិងជ្រើសតាំង នៅខែធ្នូ ឆ្នាំ២០១៥ ។

បច្ចុប្បន្នលោកមានតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាអនុប្រធានផ្នែកវិនិយោគនិងប្រតិបត្តិការក្នុងការិយាល័យកណ្តាលរបស់សម្ព័ន្ធវិនិយោគនិងអភិវឌ្ឍន៍ពាណិជ្ជកម្មសកលនៃ ORIX Corporation ព្រមទាំងទទួលបន្ទុកដឹកនាំយុទ្ធសាស្ត្រការវិនិយោគទុននៅអាស៊ាន អាស៊ីខាងត្បូង មជ្ឈិមប្រទេស អាហ្វ្រិកខាងជើង និងអឺរ៉ុប ។ លោកជាអ្នកតំណាងឱ្យ ORIX Corporation នៅក្នុងក្រុមហ៊ុនវិនិយោគសំខាន់ៗជាច្រើន ដូចជា Tenger Financial Group (ជាធនាគារធំមួយក្នុងចំណោមធនាគារពាណិជ្ជធំៗជាច្រើននៅម៉ុងហ្គោលី) និង Medgulf Insurance and Reinsurance (ជាក្រុមហ៊ុនធានារ៉ាប់រងទូទៅដ៏ធំទីពីរនៅក្នុងមជ្ឈិមប្រទេស) និង PT Sinar Mitra Sepadan Finance (ជាក្រុមហ៊ុនហិរញ្ញវត្ថុលក់រាយដ៏ធំមួយ នៅប្រទេសឥណ្ឌូនេស៊ី) ។

លោកបានបញ្ចប់បរិញ្ញាបត្រផ្នែករូបវិទ្យា ពីសាកលវិទ្យាល័យ Kwansei Gakuin នៅក្នុងប្រទេសជប៉ុន ។ លោកបានបម្រើការឱ្យ ORIX Corporation ក្នុងឆ្នាំ១៩៩១ និងបានចាប់ផ្តើមការងារក្នុងនាយកដ្ឋានទំនាក់ទំនងលក់អូសាកា ។ ចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៤ លោកបានចូលរួមការងារក្នុងនាយកដ្ឋានកុំព្យូទ័រនិងទំនាក់ទំនង ព្រមទាំងគ្រប់គ្រងកម្មវិធីវិនិយោគរួមគ្នា ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានសហរដ្ឋអាមេរិកដ៏ធំមួយ ក្នុងតួនាទីជានាយកគ្រប់គ្រង ។ នៅឆ្នាំ២០០៤ លោកបានចូលរួមការងារនៅ ORIX U.S.A Corporation ដែលផ្តល់សេវាហិរញ្ញវត្ថុ និងសេវាប្រឹក្សាយោបល់ដល់ក្រុមហ៊ុនដែលចង់ទិញ-លក់ ឬបញ្ចូលគ្នា ។ ក្នុងឆ្នាំ២០០៧ លោកបានក្លាយជានាយកប្រតិបត្តិផ្នែកវិនិយោគនិងពាណិជ្ជកម្មសកល ព្រមទាំងគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសជាច្រើនទៀត ក្នុងតួនាទីជានាយក ឬប្រធានតំណាងឱ្យ ORIX Corporation ក្នុងក្រុមហ៊ុន PT ORIX Indonesia Finance, ORIX Leasing Pakistan, ORIX Leasing Egypt ។ នៅឆ្នាំ២០១២ លោកបានបម្រើការក្នុងតួនាទីជាអគ្គនាយកផ្នែកវិនិយោគ និងប្រតិបត្តិការក្នុងការិយាល័យកណ្តាលរបស់សម្ព័ន្ធវិនិយោគ និងអភិវឌ្ឍន៍ពាណិជ្ជកម្មសកល ។

# គណៈកម្មាធិការប្រតិបត្តិ

ប្រធាននាយកប្រតិបត្តិត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ និងមានសិទ្ធិពេញលេញ ក្នុងការចាត់ចែងការងារប្រចាំថ្ងៃរបស់ធនាគារ នៅក្នុងរង្វង់គោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ទោះជាយ៉ាងណា ភាពច្បាស់លាស់នៃសិទ្ធិអំណាចអាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងការកត់ត្រាទុកជាផ្លូវការនៅក្នុង "Letters of Reserved Matters" ។

ប្រធាននាយកប្រតិបត្តិ ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមាន សមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលវេលា) ។ ប្រធាននាយកប្រតិបត្តិជាអ្នក កំណត់ពេលវេលាប្រជុំ និងកិច្ចដំណើរការនៃគណៈកម្មាធិការប្រតិបត្តិ ក្រោមការដឹកនាំផ្ទាល់ ប្រកបដោយភាពមធ្យ័តទៅលើ ៖

- យុទ្ធសាស្ត្រផ្ទាល់ ៖ អភិវឌ្ឍគោលការណ៍, កំណត់គោលដៅ, យុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តទៅតាមយុទ្ធសាស្ត្រដែលបានព្រមព្រៀង និងប្រតិបត្តិទៅតាមគោលដៅ ដែលបានកំណត់ ។
- ហានិភ័យ ៖ កំណត់ និងវាយតម្លៃទៅលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ធនាគារ និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថាធនាគារប្រតិបត្តិស្របតាមតម្រូវការ របស់សាជីវកម្ម, ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។

ពិធីទទួលវិញ្ញាបនបត្រជាធនាគារដែលមានសុវត្ថិភាពទិន្នន័យស្តង់ដារឧស្សាហកម្មប័ណ្ណទូទាត់ ( PCI Data Security Standard ) ពីក្រុមហ៊ុន ControlCase នាថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧





## បណ្ឌិត អ៊ិន ចាន់នី

ប្រធាននាយកប្រតិបត្តិ

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិតរួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ផងដែរ ។

ក្រៅពីមុខងារ និងតួនាទីនៅក្នុងអេស៊ីលីដា លោកបណ្ឌិតគឺជាប្រធានសមាគមពាណិជ្ជកម្មនិងវិនិយោគកម្ពុជា-ជប៉ុន (ស.ព.វ.ក.ជ) និងសមាជិកអនុគណៈកម្មាធិការរាជរដ្ឋាភិបាលសម្រាប់អភិបាលកិច្ចសាជីវកម្ម ។ លោកបណ្ឌិតជាអ្នកតំណាងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រងស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

(ពីឆ្វេងទៅស្តាំ)

- លោក លី ថៃ
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោក ព្រំ វិសុទ្ធ
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
- បណ្ឌិត សូ ផនណារី
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- បណ្ឌិត អ៊ិន ចាន់នី
  ប្រធាននាយកប្រតិបត្តិ
- លោកស្រី ម៉ារ អមរា
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉េង
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល





## បណ្ឌិត សូ ផនណារី

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច និងបានចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ លោកស្រីបណ្ឌិតក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និងគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានឥណទាន, នាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម, នាយកដ្ឋានសេវាឥណទាន និងនាយកដ្ឋានសេវាហិរញ្ញវត្ថុ ។ លោកស្រីបណ្ឌិតទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយផ្តោតទៅលើផែនការយុទ្ធសាស្ត្រលក់ផលិតផលនិងសេវាកម្ម ដែលមានស្រាប់ និងថ្មីៗ ។ លោកស្រីបណ្ឌិតទទួលខុសត្រូវទៅលើការដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លើសពីនេះលោកស្រីបណ្ឌិតក៏ជាសមាជិកាគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការកំណត់ថ្លៃផលិតផល និងសេវាកម្ម, និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីបណ្ឌិត ជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

( ពីឆ្វេងទៅស្តាំ )

- បណ្ឌិត ឡឹង សុភាព
  នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- បណ្ឌិត អ៊ុង សំអុល
  នាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្ម
- លោកស្រី សុខ សោភា
  នាយិកាប្រតិបត្តិទីផ្សារ
- បណ្ឌិត សូ ផនណារី
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- លោក អ៊ឹន ស៊ីផាន់
  នាយកប្រតិបត្តិឥណទាន
- លោក សុត សារ៉ន
  នាយកប្រតិបត្តិសេវាឥណទាន
- លោក សុខ សុវត្ថឌី
  នាយកប្រតិបត្តិប្រតិបត្តិការ
- លោក នេត ពិសិដ្ឋ
  នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុ





## លោកស្រី ម៉ារ អមរា

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ

ជនជាតិខ្មែរ កើតក្នុងខែកញ្ញា ឆ្នាំ១៩៦៧ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ លោកស្រីក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកស្រីជាប្រធានគណៈកម្មាធិការ Implementation & Conversion of IFRS ( International Financial Reporting Standards ), ជាប្រធានគណៈកម្មាធិការស្វ័យប្រវត្តិកម្ម និងការធ្វើទំនើបកម្ម, ជាសមាជិកាគណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម, និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីក៏ជាអ្នកដឹកនាំការងារ Basel Team ផងដែរ ។ លោកស្រីគ្រប់គ្រងលើនាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាន ការិយាល័យគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានសន្តិសុខព័ត៌មានវិទ្យា ។ លោកស្រីទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីរួមមាន ៖ ជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និងជាអនុប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ។

លោកស្រីបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០៣ ។ ក្រៅពីនោះលោកស្រីបានចូលរួមវគ្គសិក្សាជាច្រើន ដូចជា គណនេយ្យគ្រប់គ្រង គណនេយ្យហិរញ្ញវត្ថុ និងសវនកម្ម ជាដើម នៅសាកលវិទ្យាល័យ Regent ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ នៅក្នុងទីក្រុងភ្នំពេញ ។

( ពីឆ្វេងទៅស្តាំ )

- លោក ទេព ប៊ុនធឿន
  នាយកការិយាល័យគ្រប់គ្រងហានិភ័យ
- លោក ស៊ុន សុខារីនោ
  នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា
- លោកស្រី ម៉ារ អមរា
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោកស្រី ម៉េង ម៉ារីយ៉ាន
  នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក ម៉ាច ផៃរី
  នាយកប្រតិបត្តិបច្ចេកវិជ្ជាព័ត៌មាន





## លោក រ័ត្ន យូម៉េង

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២ ។ លោក រ័ត្ន យូម៉េង បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែកញ្ញា ឆ្នាំ២០១៤ ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ ។ ចាប់ពីឆ្នាំ១៩៩២ រហូតមកដល់ខែមីនា ឆ្នាំ១៩៩៦ លោកបានបម្រើការជាជំនួយការហិរញ្ញវត្ថុរបស់គម្រោងពីរក្នុងប្រទេស កម្ពុជា គឺគម្រោង CMB/92/010 ( ជាគម្រោងសម្រាប់លើកកម្ពស់សហគ្រាសខ្នាតតូច ) និងគម្រោង CBM/95/010 ( ជាគម្រោងសម្រាប់កាត់បន្ថយភាពក្រីក្រ តាមរយៈសេវាហិរញ្ញវត្ថុ អេស៊ីលីដា ) ។ គម្រោងទាំងពីរត្រូវបានគ្រប់គ្រងដោយអង្គការពលកម្មអន្តរជាតិ ( ILO ) និងបានទទួលមូលនិធិពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ( UNDP ) ។ ចាប់ពីខែមេសា ឆ្នាំ១៩៩៦ រហូតដល់ ឆ្នាំ១៩៩៨ លោកបានបម្រើការជាជំនួយការហិរញ្ញវត្ថុឱ្យស្ថានទូតសហរដ្ឋអាមេរិក ប្រចាំទីក្រុងភ្នំពេញ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ រហូតដល់បច្ចុប្បន្ន លោកបានបម្រើការឱ្យធនាគារអេស៊ីលីដា ក្នុងតំណែងជាច្រើនដូចជា ជាប្រធានគណនេយ្យករ និងអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ (ខែឧសភា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧), ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។ ចាប់ពីឆ្នាំ២០០១ រហូតដល់ខែកញ្ញា ឆ្នាំ២០១៤ លោកក៏ជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន អេ អេស អេ ដែលជាភាគទុនិកក្នុងស្រុកមួយរបស់ ធនាគារអេស៊ីលីដា ភីអិលស៊ី ។

( ពីឆ្វេងទៅស្តាំ )

- លោក ធុល សុធា
  នាយកការិយាល័យរតនពាណិជ្ជកម្ម
- លោកស្រី សុវណ្ណ បុប្ផា
  នាយិកាប្រតិបត្តិប្រតិបត្តិការហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉េង
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក វុធ ហេង
  នាយកការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ
- លោក ថាន់ សារុន
  នាយកការិយាល័យរតនាភិបាល





## លោក ព្រំ វិសុទ្ធ

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន

ជនជាតិខ្មែរ កើតក្នុងខែមករា ឆ្នាំ១៩៧៥ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន លោកក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្ររួម និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ព្រមទាំងទំនាក់ទំនងជាមួយភាគទុនិក និងក្រុមប្រឹក្សាភិបាល ។ លោកជាសមាជិកគណៈកម្មាធិការផលទាននៃថ្នាក់គ្រប់គ្រង ។ លោកទទួលបន្ទុកគ្រប់គ្រងលើនាយកដ្ឋាននីតិកម្ម, ការិយាល័យគ្រប់គ្រងវិវាទ, ការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ និង, ការិយាល័យលេខាធិការក្រុមហ៊ុន ។ លោកទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោក រួមមាន ៖ ជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ប្រូភើធី អិលធីឌី ។

លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី ។

(ពីឆ្វេងទៅស្តាំ)

- លោក សួស ឧសភា
  នាយកការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ
- លោក ចាន់ កុសល
  នាយកប្រតិបត្តិនីតិកម្ម
- លោក ព្រំ វិសុទ្ធ
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
- លោកស្រី ប៊ុត ប៊ុនសីហា
  នាយិកាការិយាល័យគ្រប់គ្រងវិវាទ
- លោក សាវ័ណ្ណ ម៉ាលីកា
  នាយកការិយាល័យលេខាធិការក្រុមហ៊ុន





## លោក លី ថៃ

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៧៥ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៧ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច លោកក៏ជាសមាជិក គណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និង ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លោកទទួលបន្ទុកគ្រប់គ្រង នាយកដ្ឋានធនធានមនុស្ស, នាយកដ្ឋានរដ្ឋបាល, និងការិយាល័យគ្រប់គ្រង ប្រព័ន្ធ SWIFT ។ លោកទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយក ប្រតិបត្តិ ។

លោក លី ថៃ បានចូលបម្រើការជាមួយអេស៊ីលីដាក្នុងតួនាទីជា ៖ គណនេយ្យករ (១៩៩៧-១៩៩៩), សវនករផ្ទៃក្នុង (១៩៩៩-២០០០) បេឡាធិការ, នាយកសាខា, នាយកការិយាល័យប្រតិបត្តិការ (២០០០-២០០៤) នាយកនាយកដ្ឋានប្រតិបត្តិការ (២០០៤-២០០៦) និងនាយក ប្រតិបត្តិប្រតិបត្តិការ (២០០៦-២០១៦) ។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុ ពីសាកល វិទ្យាល័យបញ្ញាសាស្ត្រ ក្នុងឆ្នាំ២០០៨ ។

(ពីឆ្វេងទៅស្តាំ)

- លោកស្រី ខាត់ ដានីន
  នាយិកាការិយាល័យគ្រប់គ្រងប្រព័ន្ធ SWIFT
- លោក លី ថៃ
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោក ណៃ សុខសំណាង
  នាយកប្រតិបត្តិរដ្ឋបាល
- លោក ហូរ រតនៈ
  នាយកប្រតិបត្តិធនធានមនុស្ស



# សវនករផ្ទៃក្នុង



## លោកស្រី គឹម សុធាវី

គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៦៥ ។ លោកស្រីបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៩៤ ។ ក្នុងមុខតំណែងជាគណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង លោកស្រីទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងសវនកម្មផ្ទៃក្នុងប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការសវនកម្មផ្ទៃក្នុង ។ ដើម្បីធានាឱ្យបានឯករាជ្យភាពនៃមុខងារជាសវនកម្មផ្ទៃក្នុង លោកស្រីជាអ្នករាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល ព្រមទាំងគណៈកម្មាធិការប្រតិបត្តិ ។ លោកស្រីត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ជាញឹកញាប់ ដើម្បីផ្តល់ព័ត៌មាននិងពន្យល់ពីបញ្ហានានាទាក់ទងនឹងវិសាលភាពនិងគោលបំណងរបស់គណៈកម្មាធិការ ។ លោកស្រីគ្រប់គ្រង និងដឹកនាំក្រុមសវនកម្មផ្ទៃក្នុង ដែលមាន ១ នាយកដ្ឋាន និង ៥ការិយាល័យ ដូចជានាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង, ការិយាល័យរបាយការណ៍សវនកម្ម, ការិយាល័យសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា, ការិយាល័យសវនកម្មឥណទាន, ការិយាល័យសវនកម្មហិរញ្ញវត្ថុ, និងការិយាល័យសវនកម្មប្រាក់បញ្ញើ និងផ្ទេរប្រាក់ ។

តួនាទីផ្សេងៗរបស់លោកស្រីនៅធនាគារអេស៊ីលីដា រួមមានជាសមាជិកាក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ឡាវ និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។

លោកស្រីទទួលបានអនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ។

(ពីឆ្វេងទៅស្តាំ)

- លោក សូ សីហា
  នាយកការិយាល័យសវនកម្មឥណទាន
- លោក ទុំ សុខចំរើន
  នាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ
- លោកស្រី ង៉ែត ណារី
  នាយិកាការិយាល័យសវនកម្មប្រាក់បញ្ញើ និងផ្ទេរប្រាក់
- លោកស្រី គឹម សុធាវី
  គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង
- លោក ថាត ឌីណុត
  នាយកប្រតិបត្តិអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
- លោក សុខ ពិសិដ្ឋ
  នាយកការិយាល័យសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា
- លោក សុក ហៃ
  នាយកការិយាល័យរបាយការណ៍សវនកម្ម



# ក្រមសីលធម៌

ក្នុងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ១. អនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារ ២. កិច្ចព្រមព្រៀងភាគទុនិក និង ៣. ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ។ ការវិវឌ្ឍឥតឈប់ឈររបស់ធនាគារ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងខែមីនា ឆ្នាំ២០០៥ ក្រុមប្រឹក្សាភិបាលបានផ្តល់អនុសាសន៍មួយលើការកំណត់ និងវាយតម្លៃលើបញ្ហាទាំងមូលនៃអភិបាលកិច្ចសាជីវកម្ម ដើម្បីកំណត់ពីតម្រូវការនៃការរីកលូតលាស់ទៅមុខរបស់ធនាគារ ។ ក្នុងចំណោមបញ្ហាផ្សេងៗ រួមមាន កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាលតួនាទី មុខងាររបស់ក្រុមប្រឹក្សាភិបាលបញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឱ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល បានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។ សមាជិកសមាជិកាក្រុមប្រឹក្សាភិបាល បានចូលរួមវគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុនអន្តរជាតិ ដែលរៀបចំដោយវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល ដើម្បីបន្តអភិវឌ្ឍនូវជំនាញវិជ្ជាជីវៈ និងសមត្ថភាពរបស់ខ្លួន ។

កម្មករនិយោជិតគ្រប់រូបរបស់ធនាគារអេស៊ីលីដា ស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរឹងនៃក្រមសីលធម៌ ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជា ចរិតលក្ខណៈបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជននិងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។ ឯកសារទាំងនេះ បានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ ដោយគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ដើម្បីធានាថា វានៅតែមានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។



សិប្បកម្មផលិតឥដ្ឋប្រហោង ក្នុងខេត្តបន្ទាយមានជ័យ



សិប្បកម្មចម្លាក់ស្ពាន់ ក្នុងខេត្តកំពង់ស្ពឺ

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំគ្នាផ្ទាល់ចំនួន៣ដង ក្នុងរាជធានីភ្នំពេញ នៅខែមីនា កញ្ញា និងធ្នូ និងបានធ្វើដំណើរទៅប្រជុំមួយទៀតនៅទីក្រុងយ៉ាងហ្គូន ប្រទេសមីយ៉ាន់ម៉ា នៅខែមិថុនា ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាភិបាលក៏បានអនុម័តតាមរយៈអ៊ីម៉ែលចំនួន១៣ចំណុច ។ កិច្ចប្រជុំនីមួយៗជាធម្មតាមានរយៈពេលមួយថ្ងៃកន្លះ ដោយរួមបញ្ចូលទាំងកិច្ចប្រជុំគណៈកម្មាធិការផងដែរ ។

## សកម្មភាពចម្បងៗ ក្នុងឆ្នាំ២០១៦

- អនុម័តរបាយការណ៍ហិរញ្ញវត្ថុមានបានធ្វើសវនកម្ម សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាបានធ្វើសវនកម្មឆ្នាំ២០១៦ ។
- អនុម័តការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥ នៃប្រាក់ចំណេញក្រោយដកពន្ធ និងផ្ទេរប្រាក់ចំណេញក្រោយដកពន្ធដែលនៅសល់ទៅជាទុនបម្រុងរបស់ធនាគារ ។
- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័ត និងផ្តល់អនុសាសន៍ដល់ភាគទុនិកក្នុងការជ្រើសរើសសវនករខាងក្រៅ សម្រាប់ឆ្នាំ២០១៧-២០១៨ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តផែនការយុទ្ធសាស្រ្ត និងផែនការថវិការបស់ធនាគារ ។
- ពិនិត្យឡើងវិញ និងអនុម័តគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ។
- តែងតាំង និងតែងតាំងឡើងវិញរបស់អភិបាលនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តការបន្ថែមដើមទុនសម្រាប់វិនិយោគបន្ថែមទៀត និងថវិកាសម្រាប់គម្រោងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា ។
- អនុម័តប្រាក់កម្ចីពហុហិរញ្ញប្បទានអាទិភាព និងឥណទានបន្ទាប់បន្សំពីម្ចាស់ជំនួយជាតិនិងអន្តរជាតិ ។

## របាយការណ៍របស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
- គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់
- គណៈកម្មាធិការឥណទាន
- គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

## គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានបង្កើតឡើងគាំទ្រដល់ក្រុមប្រឹក្សាភិបាលដោយផ្តល់យុទ្ធសាស្រ្តក្នុងការគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ ។

### សមាជិក

១. លោក Cornelius OBERT ( ប្រធាន )
អភិបាលឯករាជ

២. លោក ឆាយ សឿន
អភិបាលមិនប្រតិបត្តិ

៣. បណ្ឌិត Pieter KOOI
អភិបាលឯករាជ

៤. បណ្ឌិត អ៊ិន ចាន់នី
អភិបាលប្រតិបត្តិ

### កិច្ចប្រជុំ

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មបានជួបប្រជុំ៤ដងក្នុងឆ្នាំ២០១៦ នៅខែមីនា មិថុនា កញ្ញា និងវិច្ឆិកា ។ លើសពីនេះទៅទៀត មានកិច្ចប្រជុំ៥លើកបានធ្វើឡើងតាមរយៈអ៊ីម៉ែលនៅខែមករា ឧសភា កក្កដា សីហា និងខែតុលា ដើម្បីអនុម័តសំណើមូលនិធិរបស់ថ្នាក់គ្រប់គ្រង ។

### បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៦

- នៅដើមឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជា បានបង្ហាញ "អនុបាតក្របខ័ណ្ឌសន្ទនីយភាព" ជំនួសឱ្យអនុបាតសន្ទនីភាព ។ បញ្ហានេះគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានទទួលព័ត៌មានទាំងស្រុងពីថ្នាក់គ្រប់គ្រង ហើយគណៈកម្មការក៏បានពិភាក្សាពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព និងធនាបានថា ធនាគារអេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធបានបំពេញតាមតម្រូវការរបស់ធនាគារជាតិទាំងអស់ ។
- ដើម្បីផ្តល់មូលនិធិធ្វើឱ្យធនាគារទទួលបានភាពរីកលូតលាស់ ជាបន្តបន្ទាប់ក្នុងឆ្នាំ២០១៦ និងដើម្បីរៀបចំយុទ្ធសាស្រ្តសម្រាប់ឆ្នាំ២០១៧ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានអនុម័តសំណើរបស់ថ្នាក់គ្រប់គ្រង ដើម្បីបង្កើន/បន្ត កម្ចីរបស់ធនាគារចំនួន ៦២៤,៤ លានដុល្លារអាមេរិក ដែលក្នុងនោះមូលនិធិចំនួន ២៣៦លានដុល្លារអាមេរិកបានបង្វែរទៅជាបំណុលអាទិភាព និង ២៣,៤ លានដុល្លារអាមេរិកជាបំណុលបន្ទាប់បន្សំ ។ ការដកប្រាក់ដែលអាចដកបានរយៈពេលវែងនាំឱ្យយើងត្រូវត្រៀមដោះស្រាយ ដើម្បីប៉ះប៉ូវការប្រែប្រួលនៃលំហូរប្រាក់បញ្ញើ ។
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មបានផ្តល់នូវអនុសាសន៍ស្តីពីផែនការ ផ្លាស់ប្តូរគោលនយោបាយគ្រប់គ្រងហានិភ័យ ដើម្បីធានាឱ្យមានភាពច្បាស់លាស់នៅក្នុងគោលនយោបាយ ជាពិសេសនៅក្នុងលក្ខខណ្ឌដែលអាចប្រែប្រួលកម្រិតសិទ្ធិអំណាច និងការប្រុងប្រយ័ត្ន ។
- បន្ទាប់ពីការពិនិត្យមើលឡើងវិញនៃរចនាសម្ព័ន្ធអត្រាការប្រាក់ របស់ធនាគារ និងការអភិវឌ្ឍនៃអត្រាការប្រាក់អន្តរជាតិ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានអនុម័តសំណើរបស់ថ្នាក់គ្រប់គ្រង ដើម្បីចូលទៅក្នុងអត្រាការប្រាក់ស្វប ក្នុងគោលបំណងដើម្បីការពារអត្រាការប្រាក់របស់ធនាគារ ។ លើសពីនេះទៀតដើម្បីផ្តល់ឱ្យថ្នាក់គ្រប់គ្រងមានភាពបត់បែនកាន់តែច្រើន ក្នុងការការពារហានិភ័យអត្រាការប្រាក់របស់ធនាគារ ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានផ្ទេរការ

សម្រេចចិត្តចុងក្រោយ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មនៃថ្នាក់គ្រប់គ្រង ដើម្បីអនុម័តលើប្រតិបត្តិការបែបនេះ ។

- គណៈកម្មាធិការបានពិនិត្យឡើងវិញនូវសាច់ប្រាក់ងាយស្រួល និងគោលនយោបាយគ្រប់គ្រងការផ្តល់មូលនិធិ ដែលពីមុនហៅថាគោលនយោបាយផ្តល់មូលនិធិ និងបានផ្តល់យោបល់ដើម្បីធ្វើឱ្យផ្លាស់ប្តូរពាក្យដើម្បីធានាភាពច្បាស់លាស់នៅក្នុងគោលនយោបាយនេះ និងដើម្បីធានាដល់សាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងមូនិធិ មានសុវត្ថិភាព ។
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានត្រួតពិនិត្យយ៉ាងដិតដល់ពេញមួយឆ្នាំ ពីសោធនភាពរបស់ធនាគារ ។ ដោយបន្ថែមចំណូលប្រចាំត្រីមាស ដែលបានធ្វើសវនកម្មទៅក្នុងទ្រព្យសម្បត្តិសរុបរបស់ធនាគារតាមរយៈមូលធននៃប្រាក់ចំណេញរក្សាទុកពីឆ្នាំ២០១៥ ហើយការបែងចែកបំណុលបន្ទាប់បន្សំជាដើមទុនលំដាប់ថ្នាក់លេខ ២ ។ ធនាគារមានដើមទុនគ្រប់គ្រាន់ដើម្បីគាំទ្រកំណើនរបស់ខ្លួនក្នុងអំឡុងពេលឆ្នាំ២០១៦ និងបានរក្សានូវអនុបាតសាធនភាពបានរឹងមាំគ្រប់ពេល ។
- គណៈកម្មាធិការបានទទួល និងពិនិត្យឡើងវិញយ៉ាងទៀងទាត់នូវរបាយការណ៍ប្រចាំខែរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មរបស់ថ្នាក់គ្រប់គ្រងព្រមទាំងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួល, ការកំណត់ពេលវេលាមិនត្រូវគ្នានូវលំហូសាច់ប្រាក់ចេញចូល និងស្ថានភាពចំហរនៃការប្តូររូបិយប័ណ្ណបរទេស ដើម្បីអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារ ។
- គណៈកម្មាធិការបានធ្វើការជាមួយថ្នាក់គ្រប់គ្រង លើការបន្តពិនិត្យឡើងវិញនៃផែនការអាជីវកម្មប្រាំឆ្នាំ (២០១៧ - ២០២១) ជាមួយនឹងគោលបំណងនៃការសម្រេចបាននូវកំណើន ប្រកបដោយនិរន្តរភាពរបស់ធនាគារព្រមទាំងធានាឱ្យបាន អនុបាតសន្ទនីយភាព និងអនុបាតសាធនភាពនៅតែបន្តខ្លាំងរហូត ។ ធនាគារជាតិនៃកម្ពុជាបានផ្សព្វផ្សាយពីពង្រាងប្រកាសថ្មីមួយ ដែលហៅថា "ក្របខណ្ឌការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល សម្រាប់ស្ថាប័នធនាគារនិងហិរញ្ញវត្ថុ" ។ បើតាមផែនការក្របខណ្ឌនេះនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ២០១៧ ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម បានពិភាក្សាយ៉ាងល្អិតល្អន់ពីប្រកាសថ្មីនេះ និងផលប៉ះពាល់ ព្រមទាំងការផ្លាស់ប្តូរផ្សេងៗដល់ធនាគារ ។ លើសពីនេះទៅទៀត គណៈកម្មាធិការ ក៏បានមើលទៅនៅការអនុវត្តជាអន្តរជាតិដើម្បីធ្វើឱ្យប្រាកដថាធនាគារនឹងប្រតិបត្តិបានយ៉ាងល្អនៅពេលដែលប្រកាសចូលជាធរមាន ។

## គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង, សវនកម្មផ្ទៃក្នុងនិងមុខងារខាងកិច្ចការច្បាប់ ព្រមទាំងសេវាកម្មរបស់សវនករខាងក្រៅ ។

គណៈកម្មាធិការនេះមានអភិបាលឯករាជ្យចំនួនពីររូប ដែលមួយរូបត្រូវបានតែងតាំងជាប្រធាន ។ តាមសំណើរបស់គណៈកម្មាធិការ, គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង, នាយកការិយាល័យប្រតិបត្តិ និងអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន ព្រមទាំងសមាជិក-សមាជិកាផ្សេងទៀតនៃគណៈកម្មាធិការប្រតិបត្តិរបស់ធនាគារអាចត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំម្តងហើយម្តងទៀត ដើម្បីផ្តល់ព័ត៌មាន និងពន្យល់លើបញ្ហានានាដែលទាក់ទងទៅនឹងវិសាលភាពនិងគោលបំណងនៃគណៈកម្មាធិការនេះ ។

### សមាជិក

១. បណ្ឌិត Pieter KOOI (ប្រធាន)
   អភិបាលឯករាជ
២. លោក ឆាយ សឿន
   អភិបាលមិនប្រតិបត្តិ
៣. លោក Ian S. LYDALL
   អភិបាលឯករាជ

### កិច្ចប្រជុំក្នុងឆ្នាំ២០១៦

គណៈកម្មាធិការបានជួបគ្នាក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញចំនួនប្រាំបីដងក្នុងឆ្នាំ២០១៦ នៅខែមករា មីនា មេសា មិថុនា កក្កដា កញ្ញា តុលា និងខែវិច្ឆិកា ។

ក្រុមហ៊ុន ខេភីអឹមជី ដែលជាសវនករខាងក្រៅ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ក្នុងខែមករា ដើម្បីធ្វើបទបង្ហាញរបាយការណ៍សវនកម្មឆ្នាំ២០១៥រីឯក្រុមហ៊ុន ប្រាយវ៉ែតធ័រហោវខូភើស៍ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ក្នុងខែកញ្ញា និងខែវិច្ឆិកា ផងដែរ ដើម្បីធ្វើបទបង្ហាញពីដំណើរការនៃការធ្វើរបាយការណ៍សវនកម្មបណ្តោះអាសន្ន របស់ធនាគារឆ្នាំ២០១៦ ។

### បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៦

- ពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំសារពើពន្ធ២០១៥ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី៣១ ខែមីនា, ថ្ងៃទី៣០ ខែមិថុនា, និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ដើម្បីស្នើសុំទៅក្រុមប្រឹក្សាភិបាលអនុម័តចុងក្រោយ ។
- បានពិនិត្យឡើងវិញនូវរបាយការណ៍ថ្នាក់គ្រប់គ្រងរបស់ ក្រុមហ៊ុនខេភីអឹមជី សម្រាប់ឆ្នាំ២០១៥, របាយការណ៍ថ្នាក់គ្រប់គ្រងរបស់ក្រុមហ៊ុនប្រាយវ៉តធ័រហោវខូភើស៍ សម្រាប់ខែមីនា ខែមិថុនា និងខែកញ្ញា ឆ្នាំ២០១៦ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងផងដែរ ។
- បានផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល និងភាគទុនិកដើម្បីតែងតាំងក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (PwC) ដែលជាក្រុមហ៊ុនសវនកម្មក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាស និងប្រចាំឆ្នាំ២០១៧ និងឆ្នាំ២០១៨ ។
- បានពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងឆ្នាំ២០១៥ ដើម្បីដាក់ជូនធនាគារជាតិនៃកម្ពុជា ។
- បានពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង និងទទួលបានការបកស្រាយពីបញ្ហាផ្សេងៗ ។
- បានធ្វើការវាយតម្លៃប្រចាំឆ្នាំ ចំពោះគណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង ។
- អនុម័តផែនការសវនកម្មផ្ទៃក្នុងសារពើពន្ធឆ្នាំ២០១៧ ។
- បានត្រួតពិនិត្យនូវរបាយការណ៍របស់ការិយាល័យប្រតិបត្តិ និងទទួលបានការពន្យល់បកស្រាយពីអតិថិជន ឬប្រតិបត្តិការមិនប្រក្រតីណាមួយ ។

- បានធ្វើការវាយតម្លៃប្រចាំឆ្នាំ ចំពោះនាយកការិយាល័យប្រតិបត្តិ ។
- ត្រួតពិនិត្យដំណើរការគ្រប់គ្រងក្នុងការអនុវត្តស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងការអភិវឌ្ឍ ។
- ពិនិត្យ និងអនុម័ត គោលនយោបាយសវនកម្មដែលបានធ្វើបច្ចុប្បន្នកម្ម, លក្ខខណ្ឌរបស់គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់, គោលនយោបាយប្រតិបត្តិ និងគោលនយោបាយការពារការទម្លាយការសម្ងាត់ ដាក់ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត ។

### របាយការណ៍ និងអនុសាសន៍

វាជាយោបល់របស់គណៈកម្មាធិការដែលនីតិវិធីសវនកម្ម និងត្រួតពិនិត្យផ្ទៃក្នុង មានភាពគ្រប់គ្រាន់ដើម្បីការពារធនាគារនិងដើម្បីផ្តល់នូវការធានាគ្រប់គ្រាន់ពីសុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុ ។

គណៈកម្មាធិការពេញចិត្តទាំងក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (PwC) និងទាំងក្រុមហ៊ុន ខេភីអឹមជី ដែលបានបង្ហាញឯករាជ្យភាពនិងជំនាញវិជ្ជាជីវៈនៅក្នុងឆ្នាំសារពើពន្ធ២០១៥ និងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នរបស់ធនាគារអេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធឆ្នាំ២០១៦ ។

## គណៈកម្មាធិការឥណទាន

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការឥណទាន បានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលស្តីពីគោលនយោបាយឥណទាន សំណើសុំធ្វើវិសោធនកម្មផ្សេងៗ និងត្រួតពិនិត្យគុណភាពឥណទាន ដើម្បីធានាថាសកម្មភាពបង្កាផ្សេងៗត្រូវបានអនុវត្ត និងគោរពតាមច្បាប់និងបទប្បញ្ញត្តិយ៉ាងពេញលេញ ។

### សមាជិក-សមាជិកា

១. លោកស្រី Femke BOS (ប្រធាន)
អភិបាលមិនប្រតិបត្តិ

២. លោក ឆាយ សឿន
អភិបាលមិនប្រតិបត្តិ

៣. លោក Tetsuro YOSHINO
អភិបាលមិនប្រតិបត្តិ (បានលាលែងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦)

៤. លោក Cornelius OBERT
អភិបាលឯករាជ

៥. លោក Marc ROBERT
អភិបាលមិនប្រតិបត្តិ (បានតែងតាំងជាសមាជិកនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦)

### បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៦

គណៈកម្មាធិការឥណទានបានជួបប្រជុំ៤ដង នៅខែមីនា មិថុនា កញ្ញា និងធ្នូ ក្នុងឆ្នាំសារពើពន្ធ២០១៦ ។

ក្នុងកិច្ចប្រជុំម្តងៗ គណៈកម្មាធិការផ្តោតសមតុល្យឥណទាន ពិភាក្សាលើវិស័យសំខាន់ៗនៅក្នុងប្រទេសកម្ពុជា និងផ្តោតលើការធ្វើពិពិធកម្ម, ហានិភ័យ និងសំវិធានធនលើឥណទានបាត់បង់, បញ្ហាការជំពាក់បំណុលវិណ្ឌែក និន្នាការនៃទីផ្សារ, គុណភាពនិងការប្រតិបត្តិតាមគោលនយោបាយផ្តល់ប្រាក់កម្ចីរបស់ធនាគារ, នីតិវិធីនិងបទប្បញ្ញត្តិផ្សេងទៀត ។

ទោះបីជាឆ្នាំនេះជាឆ្នាំមានការលំបាកក្តី ជាពិសេសការធ្លាក់ចុះនេះតម្លៃទំនិញ ប៉ុន្តែគុណភាពសមតុល្យឥណទាននៅតែរក្សាបានយ៉ាងរឹងមាំ ជាមួយនឹងអនុបាតឥណទានមិនដំណើរការ មានចំនួនតែ ០,៦៨% នៃតម្លៃឥណទានសរុប និងប្រាក់កម្ចីរបស់ធនាគារបានកើនឡើង ១២,៩៣% ត្រឹមចុងឆ្នាំនេះ ។

គោលការណ៍ឥណទានរបស់ធនាគារត្រូវបានត្រួតពិនិត្យឡើងវិញ និងបានធ្វើវិសោធនកម្មដើម្បីសម្របទៅតាមការអភិវឌ្ឍទីផ្សារបច្ចុប្បន្ន និងការអនុវត្តល្អបំផុត ។ ធនាគារបានអនុវត្តតាមច្បាប់គោលនយោបាយឥណទានពេញលេញទាំងអស់ពេញមួយឆ្នាំ ។

## គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល របស់ធនាគារអេស៊ីលីដា ភីអិលស៊ី ដើម្បីផ្តល់អនុសាសន៍ឯករាជ្យដល់ក្រុមប្រឹក្សាភិបាលនូវការងារដូចខាងក្រោម ៖

- ផ្តល់តម្លៃការដល់អភិបាល និងគណៈប្រតិបត្តិ និង
- ការជ្រើសរើសសមាសភាព ដែលសមរម្យសម្រាប់ក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ សម្រាប់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

### សមាជិក-សមាជិកា

សមាជិកដែលបានចូលរួមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រួមមាន:

១. លោក Ian S. LYDALL (ប្រធាន)
អភិបាលឯករាជ

២. លោក Marc ROBERT
អភិបាលមិនប្រតិបត្តិ

៣. កញ្ញា Heng Su Yin
អភិបាលមិនប្រតិបត្តិ

៤. លោក Yoshiaki MATSUOKA
អភិបាលមិនប្រតិបត្តិ

សមាជិកដែលបានចូលរួមកាលពីដើមឆ្នាំ២០១៦ ប៉ុន្តែមិនបានបន្តដល់ចុងឆ្នាំ២០១៦ រួមមាន:

១. លោកស្រី Femke BOS (រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦)
អភិបាលមិនប្រតិបត្តិ

២. លោក Tetsuro YOSHINO (រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦)
អភិបាលមិនប្រតិបត្តិ

គណៈកម្មាធិការអាចអញ្ជើញសមាជិកនៃថ្នាក់គ្រប់គ្រង និងទីប្រឹក្សាដែលមានជំនាញវិជ្ជាជីវៈនៅខាងក្រៅដើម្បីចូលរួមកិច្ចប្រជុំទាំងមូល ឬមួយផ្នែកដើម្បីផ្តល់ព័ត៌មានបន្ថែម និងការពន្យល់បកស្រាយតាមការដែលពួកគាត់គិតថាជាការចាំបាច់ ។

### បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៦

គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង ជួបប្រជុំគ្នា៤ដង ខែមីនា, ខែមិថុនា, ខែកញ្ញា និងខែធ្នូ ។ កិច្ចដំណើរការសំខាន់ៗរួមមាន ៖

- ត្រួតពិនិត្យសំណើរបស់ថ្នាក់គ្រប់គ្រងក្នុងការកែតម្រូវអតិផរណា និងការបង្កើនប្រាក់ខែគោលសម្រាប់ឆ្នាំ២០១៦ ។
- បានវាយតម្លៃពីលទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ និងប្រាក់រង្វាន់សម្រាប់ឆ្នាំ២០១៥ និងបានដាក់សំណើជូនទៅក្រុមប្រឹក្សាភិបាលពីយន្តការលើកទឹកចិត្តសម្រាប់ ឆ្នាំ២០១៦ ។

- ពិនិត្យឡើងវិញនូវប្រាក់កម្រៃ និងការចំណាយផ្សេងៗសម្រាប់ឆ្នាំ២០១៦ របស់ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលមិនប្រតិបត្តិ និងដាក់សំណើជូនទៅក្រុមប្រឹក្សាភិបាល និងភាគទុនិក ។ ប្រាក់កម្រៃសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលមិនប្រតិបត្តិត្រូវបានកំណត់ដោយភាគទុនិកដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងរបស់ភាគទុនិក ។ ពួកគាត់មិនមានប្រាក់សោធននិវត្តន៍ទេ ។ ក្នុងអំឡុងឆ្នាំ ២០១៦ ប្រាក់កម្រៃរបស់អភិបាលសរុបចំនួន ៤៣០.៣០៣ ដុល្លារអាមេរិកត្រូវបានធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ផ្តល់ជូនដោយសារការចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយគ្រប់គ្រងសាជីវកម្ម និងដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត ។ បានផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។
- យោងតាមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលកាលពីខែធ្នូ ឆ្នាំ២០១៥ តួនាទីរបស់គណៈកម្មាធិការត្រូវបានពង្រីកដោយក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យតម្លៃការរបស់អភិបាលមិនប្រតិបត្តិ និងនាយកប្រតិបត្តិ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ និងការជ្រើសរើសបេក្ខជនសមរម្យសម្រាប់ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ ក្នុងឆ្នាំ២០១៦ គណៈកម្មាធិការបានពិនិត្យសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើន ព្រមទាំងផ្តល់អនុសាសន៍ផ្លាស់ប្តូរមួយចំនួន ដែលបានអនុម័តជាបន្តបន្ទាប់ដោយក្រុមប្រឹក្សាភិបាល ។

# គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

## វិសាលភាព និងគោលបំណង

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវបានបង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការបដិបត្តិតួនាទីប្រកបដោយប្រសិទ្ធភាពទៅលើទំនួលខុសត្រូវ ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យមើលយ៉ាងទៀងទាត់នូវសមត្ថភាពរបស់ថ្នាក់គ្រប់គ្រងដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យរបស់ធនាគារ ។

## សមាជិក-សមាជិកា

១. បណ្ឌិត Pieter KOOI ( ប្រធាន )
អភិបាលឯករាជ

២. លោកស្រី Femke BOS
អភិបាលមិនប្រតិបត្តិ

៣. លោក Cornelius OBERT
អភិបាលឯករាជ

៤. លោក Ian S. LYDALL
អភិបាលឯករាជ

## បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៦

គណៈកម្មាធិការគ្រប់គ្រងហានិភ័យបានជួបប្រជុំគ្នា ចំនួនបួនដងក្នុងឆ្នាំ២០១៦ គឺនៅខែមីនា មិថុនា កញ្ញា និងធ្នូ ។

រាល់កិច្ចប្រជុំស្តីពីហានិភ័យទាំងមូល ត្រូវបានបង្ហាញដោយការិយាល័យគ្រប់គ្រងហានិភ័យ និងពិភាក្សាជាមួយសមាជិក-សមាជិកា និងអ្នកចូលរួមដើម្បីធានាថាសូចនាករហានិភ័យសំខាន់ត្រូវបានអនុវត្តទៅតាមច្បាប់ ដែលបានកំណត់ដូចការអនុម័តដោយក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការបានវាយតម្លៃ និងបានពិភាក្សាអំពីហានិភ័យចម្បងៗនាពេលអនាគតរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ហើយបានដំណើរការវិភាគហានិភ័យ និងអភិវឌ្ឍព្រមទាំងការពិសោធន៍ទៅលើដំណើរការដោះស្រាយវិបត្តិហិរញ្ញវត្ថុ ជាបញ្ហាដែលអាចកើតឡើងបាន ដោយធ្វើឱ្យមានហានិភ័យកើតឡើងតំណាលគ្នាដូចជាប្រសិទ្ធភាព នៃការរីករាលដាលដែលមានសក្តានុពល ដើម្បីពិសោធន៍ទៅលើផលប៉ះពាល់នៃតារាងតុល្យការ របាយការណ៍ប្រាក់ចំណូល និងអនុបាតប្រុងប្រយ័ត្នផ្សេងៗទៀត ។ គណៈកម្មាធិការបានពិភាក្សាពីបញ្ហាយុទ្ធសាស្ត្រគ្រប់គ្រងរបស់ធនាគារ ដើម្បីដោះស្រាយជាមួយគម្រោងទាំងនេះនិងលទ្ធផលរបស់ពួកគេ ។ គណៈកម្មាធិការបានពិនិត្យឡើងវិញ និងវិភាគលើការអភិវឌ្ឍនៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃទៅលើឱកាស និងហានិភ័យ ។ លើសពីនេះទៀតគោលនយោបាយគ្រប់គ្រងហានិភ័យធនាគារត្រូវបានពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពដោយគណៈកម្មាធិការ ដើម្បីឱ្យធនាគារអេស៊ីលីដា គ្រប់គ្រងហានិភ័យសំខាន់ឱ្យមានប្រសិទ្ធិភាព ក៏ដូចជាដើម្បីធានាបាននូវការអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ។



ចំការធូរេន ក្នុងខេត្តកំពត



ចំការមៀន ក្នុងខេត្តបាត់ដំបង

# តួលេខបរិស្ថាន និងសង្គម

បរិមាណជាក់លាក់ធៀបនឹង FTE [១]

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| **សូចនាករលើការអនុវត្តផ្នែកបរិស្ថាន** | | | | | |
| **សម្ភារ** | | | | | |
| ក្រដាស ប្រើគិតជាគីឡូក្រាម /FTE | ១០,៦៥ | ១១,៤៥ | ១៣,១៦ | ១៥,១៨ | ១៦,១០ |
| **សំណល់** | | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម /FTE | ១,៩២ | ១,៨០ | ១,៥២ | ១,៤២ | ១,៨៥ |
| **ថាមពល** | | | | | |
| ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE | ១.៦៦០,១៩ | ១.៣៩០,៥១ | ១.២៣០,៨០ | ១.២៣០,៣៣ | ១.២៦៨,៧៨ |
| ប្រេងសាំង ប្រើគិតជាលីត្រ /FTE | ៨០.០៨ | ៨០,៨៧ | ៨១,៣០ | ៨៧,១៧ | ៨៨,១៧ |
| ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE | ៥១.៧០ | ៤៩,១១ | ៥៣,៨៩ | ៥៩,៦៩ | ៥៩,៨២ |
| ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE | ១.៧៥ | ១,៣១ | ១,៥៥ | ១,៧៩ | ១,៨៩ |
| **ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)[២]** | | | | | |
| ចរន្តអគ្គិសនី | ១១.១៣៨ | ៨.៩២៩ | ៧.០៥០ | ៥.៨៧០ | ៥.១៦០ |
| ប្រេងសាំង | ១.១៦៥ | ១.១៣៧ | ១.០២៥ | ៩៧៨ | ៨៤៨ |
| ប្រេងម៉ាស៊ូត | ១.៧៣២ | ១.៥៧៤ | ១.៥៤១ | ១.៤២២ | ១.២១៤ |
| **ទឹក** | | | | | |
| ទឹក ប្រើគិតជាម៉ែត្រគូប /FTE | ១៦,១៤ | ១៥,៨៤ | ១៩,១៦ | ៣០,៣២ | ២១,៧៤ |
| **ការធ្វើដំណើរ** | | | | | |
| ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE | ២៣០,៣៥ | ២២៣,៩៦ | ៣៤៣,៤០ | ៣១៥,៥៤ | ៣២៨,៩៦ |
| ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE | ១.៨២៤,៨៩ | ១.៧៩១,៨៧ | ២.២១៦,៨៤ | ២.៤២៦,៦៣ | ២.២៧២,៣១ |
| **សូចនាករលើការអនុវត្តផ្នែកសង្គម** | | | | | |
| **ការបម្រើការងារ** | | | | | |
| ចំនួនបុគ្គលិក | ១២.៣២៥ | ១១.៩២៦ | ១១.១៨២ | ៩.៤៥១ | ៧.៧២១ |
| ប្រុស | ៧.២៣៦ | ៧.០៥៩ | ៦.៦៦៤ | ៥.៨២០ | ៥.០៦៨ |
| ស្រី | ៥.០៨៩ | ៤.៨៦៧ | ៤.៥១៨ | ៣.៦៣១ | ២.៦៥៣ |
| ចំនួនបុគ្គលិក (FTE) | ១២.១៩៧ | ១១.៦៧៥ | ១០.៤១៥ | ៨.៦៧៥ | ៧.៣៩៤ |
| **ការបណ្តុះបណ្តាល និងការអប់រំ** | | | | | |
| ការបណ្តុះបណ្តាល (កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ) | ៤.៦៨៧ | ៥.៦២១ | ៣.៩២៩ | ៤.៥២១ | ៤.២១៨ |
| ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី (កម្មវិធីដំបូង) | ១.៣៧៤ | ១.៧១៧ | ២.៣៦៨ | ២.៧១១ | ១.៣៧៥ |
| ការបណ្តុះបណ្តាលនិស្សិតនៅក្នុងស្រុក | ១.៤៣៣ | ១.២៤១ | ៩៦៩ | ១.២២០ | ១.២៨០ |
| ការបណ្តុះបណ្តាលនិស្សិតនៅក្រៅប្រទេស | ១ | ៥ | ២ | ៣ | ២ |
| **ការផ្តល់ឥណទានខ្នាតតូចបំផុត** | | | | | |
| ចំនួនអតិថិជនឥណទានជំនួញខ្នាតតូចបំផុត | ២០៨.០៨៩ | ២១១.៤៩០ | ២០៣.៩៦៥ | ២១០.៧១១ | ២០៨.៩២០ |
| ទំហំជាមធ្យមនៃឥណទានជំនួញខ្នាតតូចបំផុត (គិតជាដុល្លារអាមេរិក) | ១.២១៤ | ១.១០៦ | ៩៣២ | ៨៤៦ | ៧៩៨ |

[១] FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ ។

[២] សមមូលឧស្ម័នកាបូនិក ត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol ។

# របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

## បេសកកម្មស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

*ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តរភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារ អេស៊ីលីដា ក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅ ដោយអនុវត្តតាមទស្សនៈគ្រឹះសំខាន់ទាំងបី "មនុស្ស ផែនដី និងប្រាក់ចំណេញ" ហើយធ្វើការកំណត់ជានិច្ចនូវសូចនាករ សម្រាប់វាស់វែង និងរាយការណ៍អំពីសកម្មភាព និងផលប៉ះពាល់ទៅលើសង្គមនិងបរិស្ថាន ព្រមទាំងដើម្បីអនុវត្តនូវវចនាសម្ព័ន្ធរបាយការណ៍ ដោយផ្អែកជាចម្បងទៅលើការណែនាំក្នុងគំនិតផ្តួចផ្តើមនៃរបាយការណ៍ ពិភពលោក (GRI) ។ សូមមើលឧបសម្ព័ន្ធ GRI នៅទំព័រ ១១៦ ។*

## សមាសធាតុសំខាន់ៗនៃបេសកកម្មរបស់ ធនាគារ អេស៊ីលីដា ទាក់ទងនឹងនិរន្តរភាពបរិស្ថាន និងសង្គម

១. ផ្តល់ជាក្របខណ្ឌសំខាន់នៅក្នុងគោលការណ៍ណែនាំ ដែលក្នុងនោះ ធនាគារ អេស៊ីលីដា អាចអនុវត្តតាមវិធីមួយដែលយើងអាចគ្រប់គ្រងរាល់ប្រតិបត្តិការ ដែល មានផលប៉ះពាល់ដល់បរិស្ថាន សង្គម និងសហគមន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

២. បន្តការបំពាក់ប្រព័ន្ធប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ក្នុងអគារការិយាល័យ ហើយគ្រប់គ្រងលើការប្រើប្រាស់ថាមពលឱ្យបានហ្មត់ចត់ នៅគ្រប់ទីកន្លែងដែលយើងមានប្រតិបត្តិការ ។

៣. អនុលោមទៅតាមច្បាប់សង្គមដែលយើងរស់នៅ និងធ្វើការយ៉ាងសកម្ម ដើម្បីផ្សព្វផ្សាយវប្បធម៌ដ៏ស្និទ្ធស្នាល ដែលមិនមែនតែចំពោះភាគទុនិក កម្មករ និយោជិត អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ គឺថែមទាំងគោរពចំពោះឯកត្តបុគ្គល នៅក្នុងសហគមន៍របស់យើងទៀតផង ។

៤. ទទួលស្គាល់ថា ការគាំទ្រចំពោះសហគមន៍មិនមែនគ្រាន់តែជាសីលធម៌ល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអាជីវកម្មមានលក្ខណៈល្អប្រសើរផងដែរ ពោលគឺមានភាពរឹងមាំ និងភាពរុងរឿង គឺត្រូវបំពេញឱ្យគ្នាទៅវិញទៅមក ។

## បរិស្ថាន

ធនាគារអេស៊ីលីដា បានចូលរួមអនុវត្តយ៉ាងពេញលេញ ស្របតាមសន្ធិសញ្ញាអន្តរជាតិ ដែលហាមឃាត់លើការផ្តល់ឥណទាន ឬគាំទ្រចំពោះសកម្មភាពផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ទាំងសកម្មភាពដែលប្រាសចាកពីសីលធម៌ ឬសកម្មភាពដែលធ្វើឱ្យមានការអន្តរាយចំពោះសិទ្ធិមនុស្ស ។ ដោយឡែក ធនាគារបានដាក់នូវគោលនយោបាយមួយចំនួន ដែលហាមដាច់ខាតរាល់សកម្មភាព ដែលពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំ ឬការរំលោភបំពានលើកំលាំងពលកម្មកុមារ ការធ្វើពាណិជ្ជកម្មខាងសព្វាវុធនិងរំសេវ ល្បែងស៊ីសង បនល្បែង ផ្ទះបន ការជួញដូរឬផលិតផលសត្វព្រៃ (អនុសញ្ញាស្តីពីការជួញដូរជាអន្តរជាតិលើព្រៃឈើ និងសត្វព្រៃដែលជិតផុតពូជ) ដែលច្បាប់បានបញ្ញត្តិ ព្រមទាំងការផលិត ឬការធ្វើពាណិជ្ជកម្មលើវត្ថុធាតុដើមដែលមានជាតិវិទ្យុសកម្ម ឬជាតិគីមី ដែលមានគ្រោះថ្នាក់ក្នុងកម្រិតខ្ពស់ ។ ដំណើរការគ្រប់គ្រងយ៉ាងតឹងរឹង កំពុងត្រូវបានអនុវត្ត ដែលតម្រូវឱ្យអតិថិជនទាក់ទងមកកាន់បុគ្គលិកដើម្បីបញ្ជាក់ថា អាជីវកម្មរបស់ពួកគាត់អនុលោមទៅតាមគោលការណ៍ទាំងនេះ ។

ធនាគារ អេស៊ីលីដា បានតែងតាំងមន្ត្រីទទួលបន្ទុកផ្នែកបរិស្ថានចំនួន ៥រូប ដែលទទួលខុសត្រូវទាំងស្រុងលើការងារហ្វឹកហ្វឺន និងវគ្គបំពាក់បំប៉ន ដើម្បីសម្របសម្រួលសកម្មភាពបរិស្ថាន និងត្រួតពិនិត្យលើប្រតិបត្តិការរបស់ធនាគារអេស៊ីលីដា ។

## សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

ក្នុងគោលបំណងបង្កើតខ្សែមូលដ្ឋានសម្រាប់វាស់វែង កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាន នៅក្នុងឆ្នាំ២០០៥ យើងបានបង្កើតប្រព័ន្ធឃ្លាំមើល ចំពោះការប្រើប្រាស់ធនធាន ។ លទ្ធផលត្រូវបានបង្ហាញជាចំណុចចម្បងតាមលំដាប់លំដោយដូចខាងក្រោម ដើម្បីប្រើប្រាស់ជាគំរូសម្រាប់អនុវត្តនាពេលអនាគត ។

## ការប្រើប្រាស់ក្រដាស

នៅក្នុងឆ្នាំ២០១៦ ការប្រើប្រាស់ក្រដាសបានថយចុះ ៦,៩៩% សម្រាប់កម្មករនិយោជិតម្នាក់ៗបើប្រៀបធៀបនឹងឆ្នាំ២០១៥ ដោយសារធនាគារជំរុញឱ្យបុគ្គលិកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្ទុកឯកសារនិងព័ត៌មានផ្សេងៗ និងបច្ចុប្បន្នធនាគារកំពុងប្រើប្រាស់កម្មវិធី AutoOffice ដែលបានបង្កើតឡើងដោយធនាគារអេស៊ីលីដា និងបានដាក់ឱ្យប្រើប្រាស់កាលពីចុងឆ្នាំ២០១៤ សម្រាប់ឱ្យបុគ្គលិកប្រើក្នុងការទទួល/ផ្ញើព័ត៌មានផ្ទៃក្នុង និងដាក់សំណើសុំផ្សេងៗដូចជា ស្នើសុំឥណទានបុគ្គលិក ស្នើសុំសម្ភារប្រើប្រាស់ការិយាល័យ ប្រវត្តិរូបបុគ្គលិក ទូទាត់ថ្លៃជំងឺ ។ល។

សំណល់ក្រដាសបានកើន ៦,៦៧% បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដោយសារធនាគារបានកម្ទេចឯកសារដែលហួសសុពលភាពចោល ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| សម្ភារ | | | | | |
| ក្រដាស ប្រើគិតជាគីឡូក្រាម /FTE | ១០,៦៥ | ១១,៤៥ | ១៣,១៦ | ១៥,១៤ | ១៦,១០ |
| សំណល់ | | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម /FTE | ១,៩២ | ១,៨០ | ១,៥២ | ១,៤២ | ១,៨៥ |

## ការប្រើប្រាស់ថាមពល

ការប្រើប្រាស់អគ្គិសនីសម្រាប់បុគ្គលិកម្នាក់ៗ បានកើនឡើងបន្តិចគឺ ១៩,៣៩% ក្នុងឆ្នាំ២០១៦ បើប្រៀបធៀបឆ្នាំ២០១៥ ដោយសារ សាខាស្ដង់ដាររបស់ធនាគារជាច្រើនបានបំពាក់ឧបករណ៍អគ្គិសនី និងម៉ាស៊ីនត្រជាក់ ព្រមទាំងប្រើប្រាស់ចរន្តអគ្គិសនីជំនួសឱ្យការប្រើប្រាស់ម៉ាស៊ីនភ្លើង ។

ការប្រើប្រាស់ប្រេងសាំងសម្រាប់បុគ្គលិកម្នាក់ៗ បានកើនឡើង ១,៩៣% និងប្រេងម៉ាស៊ូតក៏បានកើនឡើង ៥,២៧% ផងដែរ បើធៀបនឹងឆ្នាំ២០១៥ ដោយសារធនាគារបានបង្កើនការធ្វើដំណើរចុះជួបអតិថិជននៅតាមជនបទ ។ ការប្រើប្រាស់ប្រេងម៉ាស៊ីននៅឆ្នាំ២០១៦ ក៏បានកើនចំនួន ៣៣,៥៩% បើប្រៀបធៀបនឹងឆ្នាំ២០១៥ ។

ទោះបីជាយ៉ាងណាក៏ដោយ ការរីកចម្រើនរបស់ធនាគារទាំងមូល បានធ្វើឱ្យការបញ្ចេញចោលនូវឧស្ម័នកាបូនិកមានកំណើនយ៉ាងប្រាកដ ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| ថាមពល | | | | | |
| ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE | ១.៦៦០,១៩ | ១.៣៩០,៥១ | ១.២៣០,៨០ | ១.២៣០,៣៣ | ១.២៦៨,៧៨ |
| ប្រេងសាំង ប្រើគិតជាលីត្រ /FTE | ៤០.០៨ | ៤០.៨៧ | ៤១,៣០ | ៤៧,១៧ | ៤៨,១៧ |
| ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE | ៥១.៧០ | ៤៩.១១ | ៥៣,៨៩ | ៥៩,៦៩ | ៥៩,៨២ |
| ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE | ១.៧៥ | ១.៣១ | ១,៥៥ | ១,៧៩ | ១,៨៩ |
| ការបញ្ចេញចោលនូវឧស្ម័នកាបូនិក ( សមមូល គិតជាពាន់គីឡូក្រាម ) | | | | | |
| ចរន្តអគ្គិសនី | ១១.១៣៨ | ៨.៩២៩ | ៧.០៥០ | ៥.៨៧០ | ៥.១៦០ |
| ប្រេងសាំង | ១.១៦៥ | ១.១៣៧ | ១.០២៥ | ៩៧៨ | ៨៤៨ |
| ប្រេងម៉ាស៊ូត | ១.៧៣២ | ១.៥៧៤ | ១.៥៤១ | ១.៤២២ | ១.២១៤ |

## ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹកបានកើនឡើងបន្តិចបន្តួច ១,៨៩% ក្នុងឆ្នាំ២០១៦ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| ទឹក | | | | | |
| ទឹក ប្រើគិតជាម៉ែត្រគូប /FTE | ១៦,១៤ | ១៥,៨៤ | ១៩,១៦ | ៣០,៣២ | ២១,៧៤ |

## ការធ្វើដំណើរ

នៅក្នុងឆ្នាំ២០១៦ ចម្ងាយផ្លូវសរុបក្នុងការធ្វើដំណើរដោយរថយន្ត កើនឡើង ២,៨៥% និងទោចក្រយានយន្ត បានកើនឡើងចំនួន ១,៨៤% បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដោយសារធនាគារបានបង្កើនការធ្វើដំណើរចុះជួបជាមួយអតិជននៅតាមជនបទ និងផ្សព្វផ្សាយពីសេវាកម្មរបស់ធនាគារ ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| ការធ្វើដំណើរ | | | | | |
| ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE | ២៣០,៣៥ | ២២៣,៩៦ | ៣៤៣,៤០ | ៣១៥,៥៤ | ៣២៨,៩៦ |
| ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE | ១.៨២៤,៨៩ | ១.៧៩១,៨៧ | ២.២១៦,៨៤ | ២.៤២៦,៦៣ | ២.២៧២,៣១ |

## និរន្តរភាពសង្គម

វប្បធម៌ការងាររួមរបស់ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងដោយគោរពតាមសង្គម ដែលធនាគារធ្វើប្រតិបត្តិការ រួមទាំងទស្សនវិស័យលើអ្នកចូលរួមជាមួយយើងទាំងអស់ ដែលក្នុងនោះមិនមែនផ្ដោតតែទៅលើភាគទុនិក បុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែផ្ដោតលើ សហគមន៍ទាំងមូល ។ បន្ថែមពីលើនេះទៀតកម្មវិធីបរិស្ថានដូចដែលបានបង្ហាញខាងលើ ធនាគារបានប្រកាន់ខ្ជាប់នូវគោលការណ៍មួយ គឺគោលការណ៍ស្មើភាពគ្នាចំពោះទំនាក់ទំនងជាមួយសាធារណជនទូទៅ អតិថិជន និងបុគ្គលិក ។ ចំណុចទាំងអស់ខាងលើនេះ ធនាគារ អេស៊ីលីដាបានអនុវត្តដោយចាប់ផ្ដើមចេញពីចំណុចសូន្យនៃភាពពុករលួយទាំងខាងក្នុង និងខាងក្រៅ និងការប្រព្រឹត្តបំពានទាំងឡាយ ។

ខាងក្រោមនេះ គឺជាគោលការណ៍សំខាន់ៗនៅក្នុងគោលនយោបាយទទួលខុសត្រូវ ក្នុងសង្គមរួមរបស់ធនាគារ អេស៊ីលីដា ៖

## បុគ្គលិក

- ធនាគារអេស៊ីលីដា ផ្តល់ឱកាសស្មើគ្នាចំពោះកម្មករនិយោជិតទាំងអស់ ។ លើកលែងតែការងារណាដែលមានហានិភ័យខ្ពស់ (ដូចជាអ្នកយាម និងអ្នកបញ្ជូនសារ) ការតែងតាំងរាល់មុខតំណែង នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ គឺផ្អែកទាំងស្រុងលើគុណវុឌ្ឍិដោយមិនរើសអើងចំពោះភេទ ឬកាយពិការភាពឡើយ ។
- ធនាគារអេស៊ីលីដា មានបំណងក្លាយជានិយោជក ដែលមានការអភិវឌ្ឍបំផុតនៅកម្ពុជា ក្នុងការខុបត្ថម្ភលើការពិនិត្យ និងព្យាបាលជំងឺ ប្រាក់សោធននិវត្តន៍ និងអត្ថប្រយោជន៍ដទៃទៀត ដូចជាផ្តល់ ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឥណទានគេហដ្ឋាន និងផ្តល់លទ្ធភាពឱ្យកម្មករនិយោជិតក្លាយជាម្ចាស់ភាគហ៊ុន នៅពេលដែលកម្មករនិយោជិតនោះឆ្លងផុតការសាកល្បងការងារ ។ ធនាគារអេស៊ីលីដា ផ្តល់ការហ្វឹកហ្វឺនជូនទាំងបុគ្គលិកដែលទើបចូលបម្រើការងារថ្មី និងបុគ្គលិកដែលមានបទពិសោធន៍ស្រាប់ ព្រមទាំងលើកទឹកចិត្តបុគ្គលិកដែលមានបំណងអភិវឌ្ឍខ្លួនគេបន្ថែម ទៀត ឱ្យទៅសិក្សានៅខាងក្រៅ ។
- គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាល មានតួនាទីទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការកំណត់ និងត្រួតពិនិត្យ អំពីបទដ្ឋានក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ធនាគារ និងការគោរពសិទ្ធិមនុស្ស ។
- ដោយបានធ្វើការពិភាក្សាជាមួយបុគ្គលិក ធនាគារ អេស៊ីលីដាបានរៀបចំនូវគោលនយោបាយសង្គមនានា ដែលគ្របដណ្តប់លើ ៖ ១. ក្រមសីលធម៌ ២. ការគ្រប់គ្រងធនធានមនុស្ស ៣. សុខភាព និងសុវត្ថិភាព ៤. ទំនាក់ទំនងខាងក្រៅ ៥. សេរីភាពបង្កើតសមាគម និងសិទ្ធិក្នុងការចរចាជារួម ។ ឥឡូវអ្វីទាំងអស់នេះត្រូវបានផ្សព្វផ្សាយក្នុងប្រព័ន្ធ Lotus Notes ដូច្នេះបុគ្គលិកម្នាក់ៗអាចទទួលនូវអ្វីដែលជាការកែប្រែថ្មី និងទាន់សម័យដោយសេរី (ចៃមទាំងមិនចាំបាច់ប្រើក្រដាសផង) ។
- បុគ្គលិកទាំងអស់មានប្រតិភូបុគ្គលិក ដែលពួកគេធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយមិនរាប់បញ្ចូល ថ្នាក់ដឹកនាំ និងគណៈកម្មាធិការកីឡាសម្រាប់បុគ្គលិក ដើម្បីលើកកម្ពស់សុខភាព និងបង្កើននូវចំណងមិត្តភាព ។ នៅការិយាល័យកណ្តាល របស់ធនាគារអេស៊ីលីដាមានគិលានដ្ឋានមួយដែលមានលោកវេជ្ជបណ្ឌិតម្នាក់ និងគិលានុបដ្ឋាយិកា២នាក់ បម្រើការពេញម៉ោង ។ ការអនុវត្តការងារប្រកបដោយសុវត្ថិភាពលើបញ្ហាសុខភាព គឺជាផ្នែកមួយនៃការហ្វឹកហ្វឺនដែលផ្តល់ជូនគ្រប់កម្មករនិយោជិត ក្រោមការត្រួតពិនិត្យរបស់លោកវេជ្ជបណ្ឌិត ។ គោលការណ៍សុខុមាលភាព និងសុវត្ថិភាព ដែលស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច បានដាក់ឱ្យអនុវត្ត នៅក្នុងនោះក៏រួមមានគោលការណ៍ដែលគ្រប់គ្រងដោយគណៈកម្មាធិការមួយ សម្រាប់ជួយគាំទ្រដល់បុគ្គលិកដែលមានជំងឺអេដស៍ ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| **ការបម្រើការងារ** | | | | | |
| ចំនួនបុគ្គលិក | ១២.៣២៥ | ១១.៩២៦ | ១១.១៨២ | ៩.៤៥១ | ៧.៧២១ |
| ប្រុស | ៧.២៣៦ | ៧.០៥៩ | ៦.៦៦៤ | ៥.៨២០ | ៥.០៦៨ |
| ស្រី | ៥.០៨៩ | ៤.៨៦៧ | ៤.៥១៨ | ៣.៦៣១ | ២.៦៥៣ |
| ចំនួនបុគ្គលិក (FTE) | ១២.១៩៧ | ១១.៦៧៥ | ១០.៤១៥ | ៨.៦៧៥ | ៧.៣៩៤ |
| **ការបណ្តុះបណ្តាល និងការអប់រំ** | | | | | |
| ការបណ្តុះបណ្តាល (កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ) | ៤.៦៨៧ | ៥.៦២១ | ៣.៩២៩ | ៤.៥២១ | ៤.២១៨ |
| ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី (កម្មវិធីដំបូង) | ១.៣៧៤ | ១.៧១៧ | ២.៣៦៨ | ២.៧១១ | ១.៣៧៥ |
| ការបណ្តុះបណ្តាលនិស្សិតនៅក្នុងស្រុក | ១.៤៣៣ | ១.២៤១ | ៩៦៩ | ១.២២០ | ១.២៨០ |
| ការបណ្តុះបណ្តាលនិស្សិតនៅក្រៅប្រទេស | ១ | ៥ | ២ | ៣ | ២ |

## សហគមន៍

ធនាគារអេស៊ីលីដា ទទួលស្គាល់ថា ការចូលរួមបំពេញនូវតួនាទីជាប្រជាពលរដ្ឋដ៏ល្អក្នុងសហគមន៍របស់យើង ជាបច្ច័យមួយដ៏ល្អសម្រាប់ផលប្រយោជន៍ និងភាពរុងរឿងរបស់យើងទាំងអស់គ្នា ។ គំនិតផ្តួចផ្តើមសំខាន់ៗដែលយើងកំពុងអនុវត្ត គឺ ៖

- អភិវឌ្ឍ និងផ្តល់ជូននូវផលិតផលនិងសេវាកម្ម ឱ្យបានសមស្របប្រកបដោយការសម្រិតសម្រាំងយ៉ាងប្រុងប្រយ័ត្ន និងអភិវឌ្ឍឱ្យសមស្របទៅនឹងតម្រូវការពិសេសក្នុងសង្គមកម្ពុជាយើង ។ ក្នុងឆ្នាំ២០០៦ ធនាគារអេស៊ីលីដា បានបង្កើតនូវសេវាឥណទានគេហដ្ឋានដែល មានអត្រាការប្រាក់ថេររយៈពេល ១០ឆ្នាំ ដែលអាចធ្វើឱ្យប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់អ្នកដែលមានទ្រព្យសម្បត្តិតិចតួច អាចមានលទ្ធភាពទិញលំនៅដ្ឋានផ្ទាល់ខ្លួនបាន ។
- ពង្រីកបណ្តាញប្រតិបត្តិការ ដោយផ្តល់សេវាកម្មធនាគារដល់សហគមន៍ថ្មីៗ ដែលមានទីតាំងនៅកន្លែងផ្សេងៗ ដោយពង្រីកបណ្តាញប្រតិបត្តិការនៅតាមបណ្តាខេត្ត-រាជធានី និងពង្រីកសេវាកម្មធនាគារតាមរយៈប្រព័ន្ធអនឡាញ ដើម្បីប្រមូលនូវប្រាក់សន្សំឱ្យបានកាន់តែច្រើន ។ ការពង្រីកបណ្តាញប្រតិបត្តិការ អេធីអឹម ដែលបម្រើសេវាកម្ម ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ នៅគ្រប់បណ្តាខេត្ត-រាជធានីក្នុងឆ្នាំ២០១០ បានបង្កនូវភាពងាយស្រួលដល់

អតិថិជន អាចធ្វើប្រតិបត្តិការបានគ្រប់ពេលវេលា តាមតម្រូវការរបស់ខ្លួនដោយមិនគិតពីម៉ោងបម្រើការងារ ឬថ្ងៃឈប់សម្រាកសាធារណៈឡើយ ។ ក្នុងឆ្នាំ២០១០ ធនាគារបានដាក់ឱ្យប្រើប្រាស់នូវ "សេវាអេស៊ីលីដាយូនីធី" ដែលជាសេវាកម្មធនាគារតាមរយៈប្រព័ន្ធទូរស័ព្ទចល័ត ដែលនឹងពង្រីកការធ្វើប្រតិបត្តិការ លើសេវាកម្មហិរញ្ញវត្ថុ ព្រមទាំងអាចប្រើបានជាភាសាខ្មែរ និងអង់គ្លេស នៅគ្រប់តំបន់ភូមិ-ឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

- អំឡុងខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០១៦ ធនាគារបានសិក្សាស្រាវជ្រាវពីកម្រិតជីវភាពរស់នៅរបស់អតិថិជន ដែលប្រើប្រាស់ឥណទានខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ដើម្បីធ្វើការវាស់ស្ទង់ពីផលប៉ះពាល់នៃសេវាកម្មឥណទានរបស់ធនាគារ អេស៊ីលីដា ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងចំពោះអតិថិជនចំនួន ២.៥០៣នាក់ (អតិថិជនស្ត្រីមានចំនួន ៥៣%) ដែលជ្រើសរើសដោយចៃដន្យចេញពីអតិថិជនឥណទានចំនួន ៣៥១.០៦១ ដែលក្នុងនោះមាន ៤៣,៩៥% ជាអ្នកជំនួញ, ៤៥,៦២% ជាកសិករ/កម្មករ និង ១០,៤៣% ជាក្រុមហ៊ុនឯកជន/អង្គការក្រៅរដ្ឋាភិបាល/មន្ត្រីរាជការ ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា លើគ្រប់វិស័យអតិថិជនចំនួន ៩៤,១៣% មានកម្រិតជីវភាពល្អប្រសើរឡើងក្រោយពីបានទទួលឥណទានពីធនាគារ អេស៊ីលីដា ហើយ ៣,២៧% មិនមានការប្រែប្រួល និង ២,៦០% ធ្លាក់ចុះ ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| កម្រិតជីវភាព | | | | | |
| កើនឡើង | ៩៤,១៣% | ៩១,៩៦% | ៩០,៥៨% | ៩២,៩២% | ៨៩,៧% |
| នៅថេរ | ៣,២៧% | ៥,៤៤% | ៦,១៦% | ៥,១៤% | ៨,២% |
| ធ្លាក់ចុះ | ២,៦០% | ២,៦០% | ៣,០៥% | ១,៩៤% | ២,១% |

- ក្នុងឆ្នាំ២០១៦ ធនាគារអេស៊ីលីដា បានផ្តល់ឥណទានជំនួញខ្នាតតូចបំផុត កើនឡើងចំនួន ៨.៧៥២ (៤,២៨%) បើធៀបនឹងឆ្នាំមុន ។

| | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| ចំនួនអតិថិជនឥណទានជំនួញខ្នាតតូចបំផុត | ២០៨.០៨៩ | ២១៣.១៥៨ | ២០៤.៤០៦ | ២១០.៧១១ | ២០៨.៩២០ |
| ទំហំជាមធ្យមនៃឥណទានជំនួញខ្នាតតូចបំផុត (គិតជាដុល្លារអាមេរិក) | ១.២១៤ | ១.១០៦ | ៩៣២ | ៨៤៦ | ៧៩៨ |

- វិធានការយ៉ាងតឹងរ៉ឹង ត្រូវបានដាក់បញ្ចូលក្នុងគោលការណ៍ ដើម្បីហាមឃាត់ដល់ការលក់ ឬជំរុញឱ្យអតិថិជនយកឥណទានលើសពីសមត្ថភាព ឬជំរុញឱ្យគាត់ជាវផលិតផល ឬសេវាកម្មដែលមិនសមស្រប ។ តាមគោលការណ៍ ធនាគារអេស៊ីលីដាមិនតម្រូវឱ្យអតិថិជនដាក់ប្រាក់បញ្ញើកាតព្វកិច្ច ឡើយ ។
- តម្លាភាព និងភាពជឿជាក់ក្នុងការផ្សព្វផ្សាយ គឺបានប្រតិបត្តិយ៉ាងតឹងរ៉ឹងនៅពេលអភិវឌ្ឍ ផ្សព្វផ្សាយ និងលក់ផលិតផលនិងសេវាកម្មរបស់ ធនាគារ ហើយព័ត៌មានពេញលេញ និងលម្អិត បានផ្តល់ជូនអតិថិជនតាមរយៈខិត្តប័ណ្ណផ្សព្វផ្សាយ វេបសាយ និងសម្ភារផ្សព្វផ្សាយដទៃទៀត ។
- ធនាគារអេស៊ីលីដា អនុវត្តស្មើភាពគ្នាក្នុងការផ្តល់ប្រាក់កម្ចី ដោយមិនប្រកាន់ភេទ ឬពូជសាសន៍ ៖ អតិថិជនឥណទានចំនួន ៥០,២៨% ជាស្ត្រី ។
- ការរក្សាអាថ៌កំបាំងសម្រាប់អតិថិជន ត្រូវបានបណ្តុះជាគំនិតសម្រាប់បុគ្គលិកទាំងអស់នៅពេលហ្វឹកហ្វឺន ហើយរាល់ការបំពានត្រូវបានចាត់ទុកថាជាកំហុសធ្ងន់ ។
- ដោយយល់ពីការលំបាកនៃពិការភាពនៅក្នុងប្រទេសកម្ពុជា ធនាគារអេស៊ីលីដាកំពុងតែគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការសាងសង់ ការិយាល័យថ្មី ឬជួសជុលកែលម្អការិយាល័យចាស់ ដើម្បីរៀបចំឱ្យមានភាពងាយស្រួលជូនពួកគាត់ជាពិសេស ។
- ក្នុងនាមជាស្ថាប័នពាណិជ្ជកម្មស្វែងរកប្រាក់ចំណេញ ធនាគារអេស៊ីលីដាពុំបានទទួលជំនួយឧបត្ថម្ភអ្វីឡើយ ប៉ុន្តែនៅពេលវេលាណាមួយ ឬកន្លែងសមស្រប ធនាគារអាចទទួលជំនួយហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាកម្មមិនស្វែងរកប្រាក់ចំណេញ ដូចជាការរៀបចំសិក្ខាសាលាសម្រាប់សិក្ខាកាមនៅខាងក្រៅជាដើម ។
- ធនាគារអេស៊ីលីដា ពុំមានចំណងទាក់ទងទៅនឹងគណបក្សនយោបាយ ឬសាសនាណាមួយឡើយ ប៉ុន្តែស្វែងរកនូវសហប្រតិបត្តិការ និងអនុវត្តការងារប្រកបដោយភាពចុះសម្រុងជាមួយរដ្ឋាភិបាលដែលបានជាប់ឆ្នោត ។ ធនាគារចូលរួមយ៉ាងទៀងទាត់ក្នុងកិច្ចប្រជុំជាមួយមន្ត្រីជាន់ខ្ពស់ តាមរយៈសមាគមឧស្សាហកម្ម វេទិកាពាណិជ្ជកម្ម សភាពាណិជ្ជកម្ម និងសកម្មភាពជាក្រុមផ្សេងៗទៀត ។ ការជួបប្រជុំក្នុងលក្ខខណ្ឌជាឯកត្តបុគ្គលជាមួយមន្ត្រីនានា ត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព ហើយបញ្ហាសំខាន់ផ្សេងៗត្រូវបានរៀបចំជាកំណត់ហេតុទុក ។ ធនាគារអេស៊ីលីដាមានបញ្ញត្តិយ៉ាងតឹងរ៉ឹងសម្រាប់គ្រប់គ្រងលើ "ការកំសាន្តមិនសមស្រប" និងសកម្មភាពផ្សេងៗទៀត ដែលអាចបើកចំហរចំពោះរាល់ចម្ងល់លើមូលដ្ឋាននៃសុចរិតភាព ក្នុងនោះរួមមានបញ្ញត្តិលើសេវាកម្មធនាគារក្នុងអត្រាមិនមែន ពាណិជ្ជកម្ម (គោលនយោបាយផ្តល់ប្រាក់កម្ចី) ។
- ក្នុងឆ្នាំ២០១៦ ធនាគារអេស៊ីលីដាបានអនុញ្ញាតឱ្យនិស្សិតក្នុងស្រុកចំនួន ១.៤៣៣នាក់ និងនិស្សិតបរទេសចំនួន ១នាក់ មកពីចិន ចុះមកធ្វើកម្មសិក្សា ។

# របាយការណ៍ហិរញ្ញវត្ថុរួម និង
# របាយការណ៍ហិរញ្ញវត្ថុដោយឡែក

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួមដែលបានធ្វើសវនកម្មហើយ របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (ដែលតទៅនេះ ទាំងធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា "សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាយឡែករបស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។

## អំពីធនាគារ

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានទីស្នាក់ការ កណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន១៤ក្នុងព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារជាធនាគារពាណិជ្ជឯកជនសម្រាប់រយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០៣ ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើសាជាថ្មីម្តងទៀតទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ ។ ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអាចបង្កើតការិយាល័យសាខាបន្ថែមទាំង ក្នុងនិងក្រៅប្រទេស ព្រមទាំងអាចផ្លាស់ប្តូរទីតាំងការិយាល័យដែលបានចុះបញ្ជីរួចហើយ ដោយចុះបញ្ជីការផ្លាស់ប្តូរទាំងនោះ នៅក្រសួងពាណិជ្ជកម្ម និងត្រូវមានការអនុម័តយល់ព្រមពីធនាគារកណ្តាល ។

## សកម្មភាពចម្បងៗ

ធនាគារធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារកណ្តាល ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតសម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាអាជីវករធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងខាងលើនេះ ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលរួម និងរបាយការណ៍លទ្ធផលដោយឡែក នៅលើទំព័រទី៤៨ និងទំព័រទី៥២ ។

## ដើមទុន

ធនាគារបានបង្កើនដើមទុនពី ២៦៥.៧២៦.០៥០ដុល្លារអាមេរិក ទៅជា៣០៧.៧៦៣.៩១១ដុល្លារអាមេរិក តាមរយៈការផ្ទេរភាគលាភជាភាគហ៊ុនចំនួន៤២.០៣៧.៨៦១ដុល្លារអាមេរិក ក្នុងអំឡុងឆ្នាំ ។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជីនិងបានកត់ត្រាសំវិធានធនពេញលេញ សម្រាប់បុរេប្រទាននិងឥណទានអាក្រក់ និងសង្ស័យ ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនបុរេប្រទាន និងឥណទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនបុរេប្រទាន និងឥណទាន អាក្រក់និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបង្វិលមកវិញនៅក្នុងប្រតិបត្តិការ អាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានកត់ត្រាបន្ថយឲ្យនៅស្មើនឹងតម្លៃ ដែលគិតថានឹងអាច ទទួលស្គាល់បានជាក់ស្តែង ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឲ្យតម្លៃ ទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារពុំត្រឹមត្រូវជាសារវន្តទេ ។

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុល ដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជា សារវន្តនោះទេ ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់សម្ព័ន្ធធនាគារ និងធនាគារដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុល ផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធនាគារធម្មតានោះទេ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់សម្ព័ន្ធធនាគារ និងធនាគារ បានក្លាយជាការបង្ខំឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារនិងធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានដែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលអាចបណ្តាលឲ្យចំនួនទឹក ប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ដំណាច់ឆ្នាំនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្វង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍មិនមានខ្វង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងឆ្នាំ ដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូច ខាងក្រោម ៖

- លោក ឆាយ សឿន — ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលមិនប្រតិបត្តិ)
- បណ្ឌិត អ៊ិន ចាន់នី — សមាជិក (អភិបាលប្រតិបត្តិ)
- លោក វ័ត្ត យូម៉េង — សមាជិក (អភិបាលប្រតិបត្តិ)
- បណ្ឌិត Pieter Kooi — សមាជិក (អភិបាលឯករាជ)
- លោកស្រី Femke Bos — សមាជិក (អភិបាលមិនប្រតិបត្តិ)
- កញ្ញា Heng Su Yin — សមាជិក (អភិបាលមិនប្រតិបត្តិ) (បានតែងតាំងនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦)
- លោក Tetsuro Yoshino — សមាជិក (អភិបាលមិនប្រតិបត្តិ) (បានលាលែងនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦)
- លោក Cornelius Obert — សមាជិក (អភិបាលឯករាជ)
- លោក Ian Samuel Lydall — សមាជិក (អភិបាលឯករាជ)
- លោក Marc Yvon Robert — សមាជិក (អភិបាលមិនប្រតិបត្តិ)
- លោក Yoshiaki Matsuoka — សមាជិក (អភិបាលមិនប្រតិបត្តិ)

សមាជិកគណៈកម្មាធិការប្រតិបត្តិដែលនៅបម្រើការក្នុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម ៖

- បណ្ឌិត អ៊ិន ចាន់នី — ប្រធាននាយកប្រតិបត្តិ
- បណ្ឌិត សូ ផនណារី — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- លោកស្រី ម៉ារ អមរា — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក ចាន់ សេរី — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច (បានចូលនិវត្តន៍នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦)
- លោក វ័ត្ត យូម៉េង — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក ព្រំ វិសុទ្ធ — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
- លោក លី ថៃ — អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច (បានតែងតាំងនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦)

## ការទទួលខុសត្រូវរបស់ប្រធាននាយកប្រតិបត្តិលើរបាយការណ៍ហិរញ្ញវត្ថុ

ប្រធាននាយកប្រតិបត្តិ ដោយមានការផ្តល់ប្រឹក្សាពីគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ប្រធាននាយកប្រតិបត្តិដោយមានការផ្តល់ប្រឹក្សាពីគណៈកម្មាធិការប្រតិបត្តិត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឲ្យមានសង្គតភាព ។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ គណៈកម្មាធិការប្រតិបត្តិត្រូវប្រាកដថាការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាព នៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថាសម្ព័ន្ធធនាគារ និងធនាគារនឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
៥. គ្រប់គ្រងនិងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឲ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះ ឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបាន ឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ប្រធាននាយកប្រតិបត្តិ អះអាងថា សម្ព័ន្ធធនាគារ និងធនាគារបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។



លោកស្រី ម៉ារ អមរា
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ



បណ្ឌិត អ៊ិន ចាន់នី
ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលសូមធានាអះអាងថារបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារ គណនេយ្យកម្ពុជា ។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។*



លោក ឆាយ សឿន
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

# របាយការណ៍សវនករឯករាជ្យ

ជូនភាគទុនិកធនាគារ អេស៊ីលីដា ភីអិលស៊ី

មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពី ស្ថានភាពហិរញ្ញវត្ថុរួមរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ( ហៅកាត់ថា "ធនាគារ" ) និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ( ដែលតទៅនេះ ទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា "សម្ព័ន្ធធនាគារ" ) និងស្ថានភាពហិរញ្ញវត្ថុរបស់ ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ។

## របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុ រួមមាន៖

របាយការណ៍ហិរញ្ញវត្ថុរួម

- តារាងតុល្យការរួមគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦
- របាយការណ៍លទ្ធផលរួមសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនរួមសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់រួមសម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

របាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ

- តារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

## មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម") ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ។

## ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "វគសក") ។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និង "វគសក" ។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗរួមមាន ឧបសម្ព័ន្ធដែលជាតម្រូវការរបស់ធនាគារកណ្តាល ប៉ុន្តែឧបសម្ព័ន្ធទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍នោះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបន្តនិរន្តភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការបដិសេធនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃការត្រួតពិនិត្យប្រព័ន្ធផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារទេ ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធដែលគណៈគ្រប់គ្រងបានធ្វើឡើង ។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តភាពអាជីវកម្មរបស់ខ្លួនដែរឬទេ ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យសម្ព័ន្ធធនាគារ និងធនាគារឈប់បន្តនិរន្តភាពអាជីវកម្ម ។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗដែលយើងខ្ញុំបានរកឃើញ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd.

គុយ លីម

Partner



រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

# តារាងតុល្យការរួម

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ២៨៦.២១៦.៦២១ | ១.១៥៥.៤៥៦.៤៩៩ | ២៣៦.៥២១.២២៧ | ៩៥៧.៩១០.៩៦៩ |
| សមតុល្យនៅធនាគារកណ្តាល | ៥ | ១.២២៥.៥២៥.០១៦ | ៤.៩៤៧.៤៤៤.៤៩០ | ៨២៥.៥៣៩.៤៩០ | ៣.៣៤៣.៤៣៤.៩៣៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦ | ១០១.១៧៩.០៥៥ | ៤០៨.៤៥៩.៨៤៥ | ១២៦.៩៩៦.០១១ | ៥១៤.៣៣៣.៨៤៧ |
| ឥណទាននិងបុរេប្រទានអតិថិជន | ៧ | ២.៨៤១.៣៩០.៨៣០ | ១១.៤៧០.៦៩៤.៧៨១ | ២.៥០៧.៨៨៧.១៧៣ | ១០.១៥៦.៩៤៣.០៥១ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៥១.៩៨៧.៥២៥ | ២០៩.៨៧៣.៦៣៨ | ៤០.០៨៨.៣៤៨ | ១៦២.៣៥៧.៨១១ |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | ៩ | ៣០៧.១៥៩ | ១.២៤០.០០១ | ២៤៦.៩១៤ | ១.០០០.០០០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១២៥.៩៩០.៨៦១ | ៥០៨.៦២៥.១០៦ | ១២៥.៥៩៦.៦០១ | ៥០៨.៦៦៦.២៣៤ |
| ទ្រព្យសកម្មអរូបី | ១២ | ១១.៨៤១.៨២៥ | ៤៧.៨០៥.៤៤៨ | ១០.៨១៧.១៨៥ | ៤៣.៨០៩.៦០០ |
| ពន្ធពន្យារទ្រព្យសកម្ម | ១៣ | ២០.១៣៣.៤៥៩ | ៨១.២៧៨.៧៧៤ | ១១.៤៧០.៨៩៧ | ៤៦.៤៥៧.១៣៣ |
| ការវិនិយោគផ្សេងៗ | | ១៥៣.៥២៩ | ៦១៩.៧៩៧ | ១៥៣.៥២៩ | ៦២១.៧៩២ |
| **ទ្រព្យសកម្មសរុប** | | ៤.៦៦៤.៧២៥.៨៨០ | ១៨.៨៣១.៤៩៨.៣៧៩ | ៣.៨៨៥.៣១៧.៣៧៥ | ១៥.៧៣៥.៥៣៥.៣៧១ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១៤ | ៤០៣.២៥៣.១៥០ | ១.៦២៧.៩៣២.៩៦៧ | ៣១៥.៥៤០.១៤០ | ១.២៧៧.៩៣៧.៥៦៧ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៥ | ២.៧២២.៩១៨.៣៤៥ | ១០.៩៩២.៤២១.៣៥៩ | ២.៣៨០.១០០.១៥១ | ៩.៦៣៩.៤០៥.៦១២ |
| បំណុលផ្សេងៗ | ១៦ | ៨០.៦១៩.១៤៩ | ៣២៥.៤៥៩.៥០៥ | ៧៦.៩១០.៤៧០ | ៣១១.៤៨៧.៤០៤ |
| ប្រាក់កម្ចី | ១៧ | ៦១៦.០៦៤.១៤១ | ២.៤៨៧.០៥០.៩៣៧ | ៤២៤.១១៩.៥៦២ | ១.៧១៧.៦៨៤.២២៦ |
| បំណុលបន្ទាប់បន្សំ | ១៨ | ១០៩.៤០០.០០០ | ៤៤១.៦៤៧.៨០០ | ៩១.០០០.០០០ | ៣៦៨.៥៥០.០០០ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២៦ | ៣៥.៦៩៧.៥៤៥ | ១៤៤.១១០.៩៨៩ | ២៦.៤៤២.៨៥២ | ១០៧.០៩៣.៥៥១ |
| អត្ថប្រយោជន៍បុគ្គលិក | ១៩ | ៣៥.៩៨៣.៩០៩ | ១៤៥.២៦៧.០៤១ | ២៦.៧០៨.៩០១ | ១០៨.១៧១.០៤៩ |
| **បំណុលសរុប** | | ៤.០០៣.៩៣៦.២៣៩ | ១៦.១៦៣.៨៩០.៥៩៨ | ៣.៣៤០.៨២២.០៧៦ | ១៣.៥៣០.៣២៩.៤០៩ |
| **មូលធន** | | | | | |
| ដើមទុន | 21 | ៣០៧.៧៦៣.៩១១ | ១.២៤២.៤៤២.៩០៩ | ២៦៥.៧២៦.០៥០ | ១.០៧៦.១៩០.៥០៣ |
| ទុនបម្រុងទូទៅ | | ២៣៨.៧២២.៣៥៩ | ៩៦៣.៧២២.១៦៣ | ១៨៦.១៨៨.៦៣១ | ៧៥៤.០៦៣.៩៥៦ |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | | (២.០៨២.៤០៩) | (៨.៤០៦.៦៨៥) | (១.៦៨២.៣៨៨) | (៦.៨១៣.៦៧១) |
| ទុនបម្រុងផ្សេងៗ | 31 | (១៤.១៣២.០០៧) | (៥៧.០៥០.៩១២) | (១៤.១៣២.០០៧) | (៥៧.២៣៤.៦២៨) |
| ចំណេញរក្សាទុក | | ១២៦.៨៨៦.៩៦៩ | ៥១២.២៤២.៦៩៤ | ១០៥.០៦៧.៧៦៩ | ៤២៥.៥២៤.៤៦៤ |
| | | ៦៥៧.១៥៨.៨២៣ | ២.៦៥២.៩៥០.១៦៩ | ៥៤១.១៦៨.០៥៥ | ២.១៩១.៧៣០.៦២៤ |
| អប្បភាគភាគកម្ម | | ៣.៦៣០.៨១៨ | ១៤.៦៥៧.៦១២ | ៣.៣២៧.២៤៤ | ១៣.៤៧៥.៣៣៨ |
| **មូលធនសរុប** | | ៦៦០.៧៨៩.៦៤១ | ២.៦៦៧.៦០៧.៧៨១ | ៥៤៤.៤៩៥.២៩៩ | ២.២០៥.២០៥.៩៦២ |
| **បំណុលនិងមូលធនសរុប** | | ៤.៦៦៤.៧២៥.៨៨០ | ១៨.៨៣១.៤៩៨.៣៧៩ | ៣.៨៨៥.៣១៧.៣៧៥ | ១៥.៧៣៥.៥៣៥.៣៧១ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លទ្ធផលរួម

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណូលការប្រាក់ | ២១ | ៤១១.៩២៥.៨០៧ | ១.៦៦២.៩៤៤.៤៨៣ | ៣៥៤.៦៥៦.៨៥១ | ១.៤៣៦.៣៦០.២៤៧ |
| ចំណាយការប្រាក់ | ២១ | (១២៤.៧០២.៧៧២) | (៥០៣.៤២៥.០៩១) | (៩៧.៩៥៩.៦៤៨) | (៣៩៦.៧៣៦.៥៧៤) |
| ចំណូលការប្រាក់សុទ្ធ | | ២៨៧.២២៣.០៣៥ | ១.១៥៩.៥១៩.៣៩២ | ២៥៦.៦៩៧.២០៣ | ១.០៣៩.៦២៣.៦៧៣ |
| សំវិធានធនឥណទានបាត់បង់ | ៧ | (១៣.៦៥៥.០២៣) | (៥៥.១២៥.៣២៨) | (៩.៦២៧.៨៧៧) | (៣៨.៩៩២.៩០២) |
| ចំណូលការប្រាក់សុទ្ធបន្ទាប់ពីកាត់កង សំវិធានធនឥណទានបាត់បង់ | | ២៧៣.៥៦៨.០១២ | ១.១០៤.៣៩៤.០៦៤ | ២៤៧.០៦៩.៣២៦ | ១.០០០.៦៣០.៧៧១ |
| ចំណូលកម្រៃ និងជើងសា | ២២ | ៥២.៨៦៣.៤០៧ | ២១៣.៤០៩.៥៧៤ | ៤០.៨៩១.៣៦៧ | ១៦៥.៦១០.០៣៦ |
| ចំណាយកម្រៃ និងជើងសា | ២២ | (៤.៧៣៦.៥៧៥) | (១៩.១២១.៥៥៣) | (២.០៣១.៣១៤) | (៨.២២៦.៨២២) |
| ចំណូលកម្រៃ និងជើងសាសុទ្ធ | | ៤៨.១២៦.៨៣២ | ១៩៤.២៨៨.០២១ | ៣៨.៨៦០.០៥៣ | ១៥៧.៣៨៣.២១៤ |
| ចំណូលផ្សេងៗ | ២៣ | ១០.៨១៤.៩៧៥ | ៤៣.៦៦០.០៥៤ | ៨.០៩៦.៦៤១ | ៣២.៧៩១.៣៩៦ |
| ចំណាយបុគ្គលិក | ២៤ | (១០៥.៧៨៤.៣១២) | (៤២៧.០៥១.២៦៨) | (១០៤.៧៤១.១៥១) | (៤២៤.២០១.៦៦២) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៥ | (៤២.១៤២.២២៨) | (១៧០.១២៨.១៧៤) | (៣៧.៥១៥.៦៨២) | (១៥១.៩៣៨.៥១២) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (២២.៨៨៨.៩៨៧) | (៩២.៤០២.៨៤១) | (១៦.១៨៩.៥៤៥) | (៦៥.៥៦៧.៦៥៧) |
| ចំណាយរំលស់ទ្រព្យសកម្មអរូបី | ១២ | (៣.៣១១.០៧៩) | (១៣.៣៦៦.៨២៦) | (២.៩៨៨.៣៦២) | (១២.១០២.៨៦៦) |
| | | (១៦៣.៣១១.៦៣១) | (៦៥៩.២៨៩.០៥៥) | (១៥៣.៣៣៨.០៩៩) | (៦២១.០១៩.៣០១) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១៥៨.៣៨៣.២១៣ | ៦៣៩.៣៩៣.០៣០ | ១៣២.៥៩១.២៨០ | ៥៣៦.៩៩៤.៦៨៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៦ | (៣១.០១៤.៤៨៥) | (១២៥.២០៥.៤៧៦) | (២៧.១៣១.៤៧៧) | (១០៩.៨៨២.៤៨២) |
| ចំណេញក្នុងឆ្នាំ | | ១២៧.៣៦៨.៧២៨ | ៥១៤.១៨៧.៥៥៤ | ១០៥.៤៥៩.៨០៣ | ៤២៧.១១២.២០២ |
| ត្រូវបែងចែកជូន ៖ | | | | | |
| ម្ចាស់ភាគហ៊ុនរបស់ធនាគារ | | ១២៦.៨៨៦.៩៦៩ | ៥១២.២៤២.៦៩៤ | ១០៥.០៦៧.៧៦៩ | ៤២៥.៥២៤.៤៦៤ |
| អប្បភាគភាគកម្ម | | ៤៨១.៧៥៩ | ១.៩៤៤.៨៦១ | ៣៩២.០៣៤ | ១.៥៨៧.៧៣៨ |
| | | ១២៧.៣៦៨.៧២៨ | ៥១៤.១៨៧.៥៥៥ | ១០៥.៤៥៩.៨០៣ | ៤២៧.១១២.២០២ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ដើមទុន | ទុនបម្រុងទូទៅ | ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | ទុនបម្រុងផ្សេងៗ | ចំណេញរក្សាទុក | សរុប | អប្បភាគភាគកម្ម | មូលធនសរុប |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ២២៥.៥៣៥.៦០៥ | ១៤៦.០០៩.៨៤៨ | (៥១៦.០៤៤) | (១៤.១៣២.០០៧) | ៨០.៣៦៩.២២៨ | ៤៣៧.៣៦៦.៦៣០ | ៣.៧៨២.០២៦ | ៤៤១.១៤៨.៦៥៦ |
| ការផ្ទេរភាគលាភជាភាគហ៊ុនទៅជាដើមទុន | ៤០.១៩០.៤៤៥ | - | - | - | (៤០.១៩០.៤៤៥) | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | ៤០.១៧៨.៧៨៣ | - | - | (៤០.១៧៨.៧៨៣) | - | - | - |
| ចំណេញក្នុងឆ្នាំ | - | - | - | - | ១០៥.០៦៧.៧៦៩ | ១០៥.០៦៧.៧៦៩ | ៣៩២.០៣៤ | ១០៥.៤៥៩.៨០៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (១.២៦៦.៣៤៤) | - | - | (១.២៦៦.៣៤៤) | (៨៤៦.៨១៦) | (២.១១៣.១៦០) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | ២៦៥.៧២៦.០៥០ | ១៨៦.១៨៨.៦៣១ | (១.៦៨២.៣៨៨) | (១៤.១៣២.០០៧) | ១០៥.០៦៧.៧៦៩ | ៥៤១.១៦៨.០៥៥ | ៣.៣២៧.២៤៤ | ៥៤៤.៤៩៥.២៩៩ |
| **សមមូលនឹងពាន់រៀល** | ១.០៧៦.១៩០.៥០៣ | ៧៥៤.០៦៣.៩៥៦ | (៦.៨១៣.៦៧១) | (៥៧.២៣៤.៦២៨) | ៤២៥.៥២៤.៤៦៤ | ២.១៩១.៧៣០.៦២៤ | ១៣.៤៧៥.៣៣៨ | ២.២០៥.២០៥.៩៦២ |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ២៦៥.៧២៦.០៥០ | ១៨៦.១៨៨.៦៣១ | (១.៦៨២.៣៨៨) | (១៤.១៣២.០០៧) | ១០៥.០៦៧.៧៦៩ | ៥៤១.១៦៨.០៥៥ | ៣.៣២៧.២៤៤ | ៥៤៤.៤៩៥.២៩៩ |
| ការផ្ទេរភាគលាភជាភាគហ៊ុនទៅជាដើមទុន | ៤២.០៣៧.៨៦១ | - | - | - | (៤២.០៣៧.៨៦១) | - | - | - |
| ភាគលាភបានបង់ | - | - | - | - | (១០.៤៩៦.១៨០) | (១០.៤៩៦.១៨០) | - | (១០.៤៩៦.១៨០) |
| ការផ្ទេរទៅទុនបម្រុង | - | ៥២.៥៣៣.៧២៨ | - | - | (៥២.៥៣៣.៧២៨) | - | - | - |
| ចំណេញក្នុងឆ្នាំ | - | - | - | - | ១២៦.៨៨៦.៩៦៩ | ១២៦.៨៨៦.៩៦៩ | ៤៨១.៧៥៩ | ១២៧.៣៦៨.៧២៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (៤០០.០២១) | - | - | (៤០០.០២១) | (១៧៨.១៨៥) | (៥៧៨.២០៦) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៣០៧.៧៦៣.៩១១ | ២៣៨.៧២២.៣៥៩ | (២.០៨២.៤០៩) | (១៤.១៣២.០០៧) | ១២៦.៨៨៦.៩៦៩ | ៦៥៧.១៥៨.៨២៣ | ៣.៦៣០.៨១៨ | ៦៦០.៧៨៩.៦៤១ |
| **សមមូលនឹងពាន់រៀល** | ១.២៤២.៤៤២.៩០៩ | ៩៦៣.៧២២.១៦៣ | (៨.៤០៦.៦៨៥) | (៥៧.០៥០.៩១២) | ៥១២.២៤២.៦៩៤ | ២.៦៥២.៩៥០.១៦៩ | ១៤.៦៥៧.៦១២ | ២.៦៦៧.៦០៧.៧៨១ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លំហូរសាច់ប្រាក់រួម

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | ២៨ | ១៨៩.៧៤៤.១៩៥ | ៧៦៥.៩៩៧.៣១៥ | ៣០.៦៥៦.០៩៨ | ១២៤.១៥៧.១៩៧ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ធានាដើមទុននៅធនាគារកណ្តាល | | (៤.២០៣.៧៨៦) | (១៦.៩៧០.៦៨៤) | (៤.០១៩.០៤៤) | (១៦.២៧៧.១២៨) |
| ការវិនិយោគផ្សេងៗ | | - | - | ២០០.០០០ | ៨១០.០០០ |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (២៣.៣៨៤.៥២៥) | (៩៤.៤០៣.៣២៧) | (៤៦.២៣១.៥២៣) | (១៨៧.២៣៧.៦៦៨) |
| ការទិញទ្រព្យសកម្មអរូបី | ១២ | (៤.៣៨០.៨២១) | (១៧.៦៨៥.៣៧៤) | (៣.៥៩៦.១៤០) | (១៤.៥៦៤.៣៦៧) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ១១៦.៨៨០ | ៤៧១.៨៤៤ | ១៤៩.៥៣២ | ៦០៥.៦០៤ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៣១.៨៥២.២៥២) | (១២៨.៥៨៧.៥៤១) | (៥៣.៤៩៧.១៧៥) | (២១៦.៦៦៣.៥៥៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភបានបង់ | | (១០.៤៩៦.១៨០) | (៤២.៣៧៣.០៧៩) | - | - |
| ការសងប្រាក់កម្ចី | | (៦៥.៦៧៤.២៥៨) | (២៦៥.១២៦.៩៨០) | (៧៧.៦៥០.៤៦៥) | (៣១៤.៤៨៤.៣៨៣) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ២៥៨.១៥០.១១៨ | ១.០៤២.១៥២.០២៦ | ២៨៦.៦៣២.៨៧២ | ១.១៦០.៨៦៣.១៣២ |
| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | | ២៣.៤០០.០០០ | ៩៤.៤៦៥.៨០០ | - | - |
| ការសងបំណុលបន្ទាប់បន្សំ | | (៥.០០០.០០០) | (២០.១៨៥.០០០) | (២៧.៥០០.០០០) | (១១១.៣៧៥.០០០) |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | | (៥៧៨.២០៦) | (២.៣៣៤.២១៦) | (២.១១៣.១៦០) | (៨.៥៥៨.២៩៨) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ១៩៩.៨០១.៤៧៤ | ៨០៦.៥៩៨.៥៥១ | ១៧៩.៣៦៩.២៤៧ | ៧២៦.៤៤៥.៤៥១ |
| **កំណើនសុទ្ធនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល** | | ៣៥៧.៦៩៣.៤១៧ | ១.៤៤៤.០០៨.៣២៥ | ១៥៦.៥២៨.១៧០ | ៦៣៣.៩៣៩.០៨៩ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៨៣០.៥៣៧.១២១ | ៣.៣៦៣.៦៧៥.៣៤០ | ៦៧៤.០០៨.៩៥១ | ២.៧៤៦.៥៨៦.៤៧៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០.៧៩៦.៩៨៣) | - | (១៦.៨៥០.២២៣) |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២៧ | ១.១៨៨.២៣០.៥៣៨ | ៤.៧៩៦.៨៨៦.៦៨២ | ៨៣០.៥៣៧.១២១ | ៣.៣៦៣.៦៧៥.៣៤១ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# តារាងតុល្យការដោយឡែក

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ២៧៦.៤២៨.៧៦៧ | ១.១១៥.៩៤២.៩៣២ | ២២៥.១២៦.៨៧៥ | ៩១១.៧៦៣.៨៤៤ |
| សមតុល្យនៅធនាគារកណ្តាល | ៥ | ១.២២៥.៥២៥.០១៦ | ៤.៩៤៧.៤៤៤.៤៩០ | ៨២៥.៥៣៩.៤៩០ | ៣.៣៤៣.៤៣៤.៩៣៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦ | ៨២.០៧៤.១៩៧ | ៣៣១.៣៣៣.៥៣៣ | ១០៦.៨១៥.០៤៨ | ៤៣២.៦០០.៩៤៤ |
| ឥណទាននិងបុរេប្រទានអតិថិជន | ៧ | ២.៧១៣.៦៣៥.៣៣៩ | ១០.៩៥៤.៩៤៥.៨៦៣ | ២.៤០៥.៤៦៤.៧០៥ | ៩.៧៤២.១៣២.០៥៥ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៤៨.៧៧៣.៩២៧ | ១៩៦.៩០០.៣៤៣ | ៣៧.៧៨៧.៥៣០ | ១៥៣.០៣៩.៤៩៨ |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១០ | ៧៤.៩៦១.៩៦០ | ៣០២.៦២១.៤៣៣ | ៦៩.៩៦១.៩៦០ | ២៨៣.៣៤៥.៩៣៨ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១០៨.៥៣៤.៤៨៩ | ៤៣៨.១៥៣.៧៣២ | ១១០.០៨៥.៤០៩ | ៤៤៥.៨៤៥.៩០៦ |
| ទ្រព្យសកម្មអរូបី | ១២ | ១០.៩៥២.០១៨ | ៤៤.២១៣.២៩៧ | ១០.១៦១.៨០៨ | ៤១.១៥៥.៣២២ |
| ពន្ធពន្យារទ្រព្យសកម្ម | ១៣ | ១៩.៩៨៤.៥២៩ | ៨០.៦៧៧.៥៤៤ | ១១.៣៦៦.៥៣៩ | ៤៦.០៣៤.៤៨៤ |
| ការវិនិយោគផ្សេងៗ | | ១៥៣.៥២៩ | ៦១៩.៧៩៧ | ១៥៣.៥២៩ | ៦២១.៧៩២ |
| **ទ្រព្យសកម្មសរុប** | | ៤.៥៦១.០២៣.៧៧១ | ១៨.៤១២.៨៥២.៩៦៤ | ៣.៨០២.៤៦២.៨៩៣ | ១៥.៣៩៩.៩៧៤.៧១៧ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១៤ | ៣៩៥.៩២៥.៩១២ | ១.៥៩៨.៣៥២.៩០៧ | ៣១៨.០៨១.២៤៣ | ១.២៨៨.២២៩.០៣៤ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៥ | ២.៦៥៥.៧៤៩.៧៦៥ | ១០.៧២១.២៦១.៨០១ | ២.២៩៨.២៧៩.៧៧២ | ៩.៣០៨.០៣៣.០៧៧ |
| បំណុលផ្សេងៗ | ១៦ | ៧៦.៦៣២.៦៨៥ | ៣០៩.៣៦៦.១៤៩ | ៧២.៩៨៨.៥៨៧ | ២៩៥.៦០៣.៧៧៧ |
| ប្រាក់កម្ចី | ១៧ | ៥៨២.០៤៨.៤៩១ | ២.៣៤៩.៧២៩.៧៥៨ | ៤១១.០១៥.០៦៨ | ១.៦៦៤.៦១១.០២៥ |
| បំណុលបន្ទាប់បន្សំ | ១៨ | ១០៩.៤០០.០០០ | ៤៤១.៦៤៧.៨០០ | ៩១.០០០.០០០ | ៣៦៨.៥៥០.០០០ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២៦ | ៣៥.៣៤៩.២៦២ | ១៤២.៧០៤.៩៧១ | ២៦.១៧៣.៩៣៩ | ១០៦.០០៤.៤៥៣ |
| អត្ថប្រយោជន៍បុគ្គលិក | ១៩ | ៣៥.៥៤៣.៨៥២ | ១៤៣.៤៩០.៥៣១ | ២៦.៣៥៩.៧៦៨ | ១០៦.៧៥៧.០៦០ |
| **បំណុលសរុប** | | ៣.៨៩០.៦៤៩.៩៦៧ | ១៥.៧០៦.៥៥៣.៩១៧ | ៣.២៤៣.៨៩៨.៣៧៧ | ១៣.១៣៧.៧៨៨.៤២៦ |
| **មូលធន** | | | | | |
| ដើមទុន | ២០ | ៣០៧.៧៦៣.៩១១ | ១.២៤២.៤៤២.៩០៩ | ២៦៥.៧២៦.០៥០ | ១.០៧៦.១៩០.៥០៣ |
| ទុនបម្រុងទូទៅ | | ២៤០.៣០៤.៤២៥ | ៩៧០.១០៨.៩៦៤ | ១៨៦.៦៧៩.០២០ | ៧៥៦.០៥០.០៣១ |
| ចំណេញរក្សាទុក | | ១២២.៣០៥.៤៦៨ | ៤៩៣.៧៤៧.១៧៤ | ១០៦.១៥៩.៤៤៦ | ៤២៩.៩៤៥.៧៥៧ |
| **មូលធនសរុប** | | ៦៧០.៣៧៣.៨០៤ | ២.៧០៦.២៩៩.០៤៧ | ៥៥៨.៥៦៤.៥១៦ | ២.២៦២.១៨៦.២៩១ |
| **បំណុលនិងមូលធនសរុប** | | ៤.៥៦១.០២៣.៧៧១ | ១៨.៤១២.៨៥២.៩៦៤ | ៣.៨០២.៤៦២.៨៩៣ | ១៥.៣៩៩.៩៧៤.៧១៧ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លទ្ធផលដោយឡែក

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២១ | ៣៩២.៦៩៨.៥៨៤ | ១.៥៨៥.៣២៤.១៨៤ | ៣៣៧.២៥២.៧៦៧ | ១.៣៦៥.៨៧៣.៧០៦ |
| ចំណាយការប្រាក់ | ២១ | (១១៧.៦២០.០១៤) | (៤៧៤.៨៣១.៩៩៧) | (៩០.៩២១.៥៦១) | (៣៦៨.២៣២.៣២២) |
| ចំណូលការប្រាក់សុទ្ធ | | ២៧៥.០៧៨.៥៧០ | ១.១១០.៤៩២.១៨៧ | ២៤៦.៣៣១.២០៦ | ៩៩៧.៦៤១.៣៨៤ |
| សំវិធានធនឥណទានបាត់បង់ | ៧ | (១២.៥១៦.៩៤១) | (៥០.៥៣០.៨៩១) | (៧.៦២៦.៣៨២) | (៣០.៨៨៦.៨៤៧) |
| ចំណូលការប្រាក់សុទ្ធបន្ទាប់ពីកាត់កង សំវិធានធនឥណទានបាត់បង់ | | ២៦២.៥៦១.៦២៩ | ១.០៥៩.៩៦១.២៩៦ | ២៣៨.៧០៤.៨២៤ | ៩៦៦.៧៥៤.៥៣៧ |
| ចំណូលកម្រៃ និងជើងសា | ២២ | ៤៥.៧៨១.៧៧៩ | ១៨៤.៨២១.០៤២ | ៣៦.៥៤៧.២៣៦ | ១៤៨.០១៦.៣០៦ |
| ចំណាយកម្រៃ និងជើងសា | ២២ | (៤.២០០.៩៨៥) | (១៦.៩៥៩.៣៧៦) | (១.៧៣៥.២៨៧) | (៧.០២៧.៩១២) |
| ចំណូលកម្រៃ និងជើងសាសុទ្ធ | | ៤១.៥៨០.៧៩៤ | ១៦៧.៨៦១.៦៦៦ | ៣៤.៨១១.៩៤៩ | ១៤០.៩៨៨.៣៩៤ |
| ចំណូលផ្សេងៗ | ២៣ | ៧.២៥៩.៩៧៨ | ២៩.៣០៨.៥៣១ | ៦.២១៨.២៤០ | ២៥.១៨៣.៨៧២ |
| ចំណាយបុគ្គលិក | ២៤ | (៩៦.៦៧២.៤១០) | (៣៩០.២៦៦.៥១៩) | (៩៦.៦៨៥.១០២) | (៣៩១.៥៧៤.៦៦៣) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៥ | (៣៧.៣១១.៦៨៥) | (១៥០.៦២៧.២៧២) | (៣២.៨២១.៨២០) | (១៣២.៩២៨.៣៧១) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (២១.៥១៩.៨៣២) | (៨៦.៨៧៥.៥៦២) | (១៤.៥៣៦.៤៧១) | (៥៨.៨៧២.៧០៨) |
| ចំណាយរំលស់ទ្រព្យសកម្មអរូបី | ១២ | (៣.០៧៧.២២៨) | (១២.៤២២.៧៦៩) | (២.៧៥៨.២៦៧) | (១១.១៧០.៩៨១) |
| | | (១៥១.៣២១.១៧៧) | (៦១០.៨៨៣.៥៩១) | (១៤០.៥៨៣.៤២០) | (៥៦៩.៣៦២.៨៥១) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១៥២.៨២១.២៤៦ | ៦១៦.៩៣៩.៣៧១ | ១៣២.៩៣៣.៣៥៣ | ៥៣៨.៣៨០.០៨០ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៦ | (៣០.៥១៥.៧៧៨) | (១២៣.១៩២.១៩៦) | (២៦.៧៧៣.៩០៧) | (១០៨.៤៣៤.៣២៣) |
| ចំណេញក្នុងឆ្នាំ | | ១២២.៣០៥.៤៦៨ | ៤៩៣.៧៤៧.១៧៥ | ១០៦.១៥៩.៤៤៦ | ៤២៩.៩៤៥.៧៥៧ |

# របាយការណ៍បម្រែបម្រួលមូលធនដោយឡែក

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ដើមទុន | ទុនបម្រុងទូទៅ | ចំណេញរក្សាទុក | សរុប |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ២២៥.៥៣៥.៦០៥ | ១៤៤.៦៤៩.០៣៣ | ៨២.២២០.៤៣២ | ៤៥២.៤០៥.០៧០ |
| ការផ្ទេរភាគលាភជាភាគហ៊ុនទៅជាដើមទុន | ៤០.១៩០.៤៤៥ | - | (៤០.១៩០.៤៤៥) | - |
| ការផ្ទេរទៅទុនបម្រុង | - | ៤២.០២៩.៩៨៧ | (៤២.០២៩.៩៨៧) | - |
| ចំណេញក្នុងឆ្នាំ | - | - | ១០៦.១៥៩.៤៤៦ | ១០៦.១៥៩.៤៤៦ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ២៦៥.៧២៦.០៥០ | ១៨៦.៦៧៩.០២០ | ១០៦.១៥៩.៤៤៦ | ៥៥៨.៥៦៤.៥១៦ |
| សមមូលនឹងពាន់រៀល | ១.០៧៦.១៩០.៥០៣ | ៧៥៦.០៥០.០៣១ | ៤២៩.៩៤៥.៧៥៧ | ២.២៦២.១៨៦.២៩១ |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ២៦៥.៧២៦.០៥០ | ១៨៦.៦៧៩.០២០ | ១០៦.១៥៩.៤៤៦ | ៥៥៨.៥៦៤.៥១៦ |
| ការផ្ទេរភាគលាភជាភាគហ៊ុនទៅជាដើមទុន | ៤២.០៣៧.៨៦១ | - | (៤២.០៣៧.៨៦១) | - |
| ភាគលាភបានបង់ | - | - | (១០.៤៩៦.១៨០) | (១០.៤៩៦.១៨០) |
| ការផ្ទេរទៅទុនបម្រុង | - | ៥៣.៦២៥.៤០៥ | (៥៣.៦២៥.៤០៥) | - |
| ចំណេញក្នុងឆ្នាំ | - | - | ១២២.៣០៥.៤៦៨ | ១២២.៣០៥.៤៦៨ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៣០៧.៧៦៣.៩១១ | ២៤០.៣០៤.៤២៥ | ១២២.៣០៥.៤៦៨ | ៦៧០.៣៧៣.៨០៤ |
| សមមូលនឹងពាន់រៀល | ១.២៤២.៤៤២.៩០៩ | ៩៧០.១០៨.៩៦៤ | ៤៩៣.៧៤៧.១៧៥ | ២.៧០៦.២៩៩.០៤៨ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | ២៨ | ២១៧.៤២៤.២០០ | ៨៧៧.៧៤១.៤៩៥ | ២០.៤៦២.៩០០ | ៨២.៨៧៤.៧៤៥ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ធានាដើមទុននៅធនាគារកណ្តាល | | (៤.២០៣.៧៨៦) | (១៦.៩៧០.៦៨៤) | (៤.០១៩.០៤៤) | (១៦.២៧៧.១២៨) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (២០.០៤៩.៨២១) | (៨០.៩៤១.១២៧) | (៤៤.៤៥៤.២៥៩) | (១៨០.០៣៩.៧៤៩) |
| ការទិញទ្រព្យសកម្មអរូបី | ១២ | (៣.៩១១.៥៩៧) | (១៥.៧៩១.១១៧) | (៣.៣៥១.៧៥១) | (១៣.៥៧៤.៥៩២) |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | (៥.០០០.០០០) | (២០.១៨៥.០០០) | (៥.០០០) | (២០.២៥០) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ១០៥.៧២៣ | ៤២៦.៨០៣ | ១៤៨.៥១៤ | ៦០១.៤៨២ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៣៣.០៥៩.៤៨១) | (១៣៣.៤៦១.១២៥) | (៥១.៦៨១.៥៤០) | (២០៩.៣១០.២៣៧) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភបានបង់ | | (១០.៤៩៦.១៨០) | (៤២.៣៧៣.០៧៩) | - | - |
| ការសងប្រាក់កម្ចី | | (៧០.៩៣៤.៧១៩) | (២៨៦.៣៦៣.៤៦១) | (៥៤.៦៧៥.៥៤៧) | (២២១.៤៣៥.៩៦៥) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ២៤១.៩៦៨.១៤២ | ៩៧៦.៨២៥.៣៩០ | ២៧៨.៥១៥.៥៩៣ | ១.១២៧.៩៨៨.១៥២ |
| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | | ២៣.៤០០.០០០ | ៩៤.៤៦៥.៨០០ | - | - |
| ការសងបំណុលបន្ទាប់បន្សំ | | (៥.០០០.០០០) | (២០.១៨៥.០០០) | (២៧.៥០០.០០០) | (១១១.៣៧៥.០០០) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ១៧៨.៩៣៧.២៤៣ | ៧២២.៣៦៩.៦៥០ | ១៩៦.៣៤០.០៤៦ | ៧៩៥.១៧៧.១៨៧ |
| **កំណើនសុទ្ធនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល** | | ៣៦៣.៣០១.៩៦២ | ១.៤៦៦.៦៥០.០២០ | ១៦៥.១២១.៤០៦ | ៦៦៨.៧៤១.៦៩៥ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៨០០.១៧៦.០៩២ | ៣.២៤០.៧១៣.១៧៣ | ៦៣៥.០៥៤.៦៨៦ | ២.៥៨៧.៨៤៧.៨៤៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០.៤០២.២៨៩) | - | (១៥.៨៧៦.៣៦៧) |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២៧ | ១.១៦៣.៤៧៨.០៥៤ | ៤.៦៩៦.៩៦០.៩០៤ | ៨០០.១៧៦.០៩២ | ៣.២៤០.៧១៣.១៧៣ |

*"តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ ២.៥ (គ)" ។*

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៤ ដល់ទំព័រទី ១១៤ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

## ១. ព័ត៌មានទូទៅ

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារអេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា ("ធនាគារ") គឺជាធនាគារមហាជនទទួលខុសត្រូវមានកំណត់ ដែលបង្កើតឡើងក្រោមច្បាប់ព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជនសម្រាប់រយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ។ អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើជាថ្មីទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ធនាគារធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់ធនាគារកណ្តាល ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតសម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាអាជីវករធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងខាងលើនេះ ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ១០នៃរបាយការណ៍ហិរញ្ញវត្ថុ ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ធនាគារនិងក្រុមហ៊ុនបុត្រសម្ព័ន្ធមានបុគ្គលិកចំនួន ១៣.៦៣៣នាក់ (២០១៥៖១៣.២៥៨ នាក់) ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នេះនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។ ក្រុមប្រឹក្សាភិបាលមានសិទ្ធិក្នុងការកែប្រែ និងចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះឡើងវិញ ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម ។ គោលការណ៍គណនេយ្យទាំងនេះត្រូវបានអនុវត្តយ៉ាងមានសង្គតភាពគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម ហើយប្រសិនបើចំណុចណាមួយដែលមិនបានបង្ហាញតាមវិធីសាស្ត្រថ្លៃដើម វានឹងមានការលាតត្រដាងបន្ថែមទៀត និងបានរៀបចំអនុលោមទៅតាមគោលការណ៍ ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") និងស្តង់ដារគណនេយ្យកម្ពុជា(ហៅកាត់ថា"CAS") ។ ក្នុងការ អនុវត្ត CAS ធនាគារក៏បានប្រើការលាតត្រដាងព័ត៌មានទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា (ហៅកាត់ថា "CFRS") គឺ CFRS 4 ស្តីពី "កិច្ចសន្យាធានារ៉ាប់រង" និង CFRS7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ" ។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅ ពីព្រះរាជាណាចក្រកម្ពុជានោះទេ ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមទៅតាម CAS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់ និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាព ដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងកាលបរិច្ឆេទរាយការណ៍នេះ ។ វាក៏តម្រូវឲ្យគណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យរបស់ធនាគារផងដែរ ។ បើទោះជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រង ទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ ។

ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់៣ នៃរបាយការណ៍ហិរញ្ញវត្ថុ ។

### ២.២ ស្តង់ដាគណនេយ្យហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ ។ អង្គភាពដែលមាន ការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ។

យោងតាមសារាចរណែនាំលេខ ០៥៨ សហវ-កជគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ ។

ការផ្លាស់ប្តូរនេះមិនមានសុពលភាពទេរហូតដល់ឆ្នាំ២០១៩ ហើយនៅពេលនោះធនាគារ នឹងផ្តល់ភាពខុសគ្នាធំៗរវាងស្តង់ដារគណនេយ្យទាំងពីរនៅពេលមានផលប៉ះពាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក ។

### ២.៣ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

#### (ក) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម គឺរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ មកទល់នឹងដំណាច់ឆ្នាំនេះ ។ បុត្រសម្ព័ន្ធគឺជាក្រុមហ៊ុនទាំងឡាយណាដែលសម្ព័ន្ធធនាគារមានអំណាច

ក្នុងការគ្រប់គ្រងលើផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការរបស់ក្រុមហ៊ុននោះ ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់ក្រុមហ៊ុននោះ ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ត្រូវបានរួមបញ្ចូលគ្នា ដោយប្រើវិធីសាស្ត្រគណនេយ្យក្នុងការទិញ ។ យោងតាមវិធីសាស្ត្រគណនេយ្យក្នុងការទិញ លទ្ធផលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានទិញឬបានលក់ក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានរួមបញ្ចូលចាប់ពី កាលបរិច្ឆេទទិញ ឬរហូតដល់កាលបរិច្ឆេទលក់ ។ នាកាលបរិច្ឆេទទិញ តម្លៃសមស្របនៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកំណត់រួចជាស្រេច ហើយតម្លៃទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ។

ប្រតិបត្តិការអន្តរក្រុមហ៊ុន សមតុល្យនិងចំណេញឬខាតមិនទាន់ទទួលស្គាល់ ដែលកើតមកពីប្រតិបត្តិការអន្តរក្រុមហ៊ុនត្រូវ បានលុបចោល ហើយរបាយការណ៍ហិរញ្ញវត្ថុរួម ឆ្លុះបញ្ចាំងតែប្រតិបត្តិការជាមួយភាគីខាងក្រៅតែប៉ុណ្ណោះ ។ ការខាតបង់ដែលបណ្តាលមកពីប្រតិបត្តិការក្នុងសម្ព័ន្ធធនាគារ ដែលចង្អុលបង្ហាញនូវការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ នឹងត្រូវកត់ត្រានៅក្នុង របាយការណ៍ហិរញ្ញវត្ថុរួម ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំឡើងដោយប្រើប្រាស់គោលការណ៍គណនេយ្យរួម ចំពោះប្រតិបត្តិការដូចគ្នា និងព្រឹត្តិការណ៍ផ្សេងៗនៅក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា ។

ចំណេញឬខាតពីការលក់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាភាពលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងភាគហ៊ុនរបស់សម្ព័ន្ធធនាគារលើទ្រព្យសកម្មសុទ្ធរបស់ខ្លួននាកាលបរិច្ឆេទលក់នោះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលរួម ។

### (ខ) ការផ្លាស់ប្តូរអត្ថប្រយោជន៍ម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយមិនផ្លាស់ប្តូរការគ្រប់គ្រង

ប្រតិបត្តិការជាមួយអប្បភាគភាគកម្ម ដែលមិនធ្វើឲ្យមានការខាតបង់ដល់ការគ្រប់គ្រង ត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន ដូចជាប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនក្នុងលក្ខណៈជាម្ចាស់ក្រុមហ៊ុនដែរ ។ លម្អៀងរវាងតម្លៃសមស្របនៃទឹកប្រាក់ដែលបានបង់ និងភាគហ៊ុនពាក់ព័ន្ធដែលបានទិញតាមតម្លៃយោងនៃទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកត់ត្រាក្នុងមូលធន ។ ចំណេញឬខាតពីការលក់អប្បភាគភាគកម្ម ក៏ត្រូវបានកត់ត្រាក្នុងមូលធនដែរ ។

## ២.៤ ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានលុបចោលក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុរួម ហើយត្រូវបានរាយការណ៍តាមថ្លៃដើមនៅក្នុងរបាយការណ៍ដោយឡែករបស់ធនាគារ ។ នៅពេលលក់ការវិនិយោគនោះចេញវិញ តម្លៃលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងតម្លៃយោងរបស់វា ត្រូវបានកត់ត្រាជាចំណេញឬខាតក្នុងការលក់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

## ២.៥ ការប្តូររូបិយប័ណ្ណ

### (ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល") ។ ប្រាក់ដុល្លារអាមេរិកឆ្លុះបញ្ចាំងនូវធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍នានា និងកាលៈទេសៈដ៏មានសារសំខាន់របស់ធនាគារ ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ ។

### (ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ ។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្មនិងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរនាដំណាច់ ការិយបរិច្ឆេទ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

### (គ) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តម្រូវឲ្យមានការប្តូរទៅជាប្រាក់រៀលចំពោះតារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការ ដែលផ្សព្វផ្សាយដោយធនាគារកណ្តាលនាកាលបរិច្ឆេទរាយការណ៍ ដែល១ដុល្លារអាមេរិកស្មើនឹង ៤.០៣៧ រៀល (២០១៥ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៥០រៀល) ។ តួលេខដែលត្រូវបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ ។ តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិក តាមអត្រាដែលកំណត់ដោយធនាគារកណ្តាល ។

### (ឃ) ក្រុមហ៊ុនក្នុងសម្ព័ន្ធធនាគារ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងសម្ព័ន្ធធនាគារទាំងអស់ (ដែលក្នុងចំណោមក្រុមហ៊ុនទាំងនោះ មិនមានក្រុមហ៊ុនដែលមានសេដ្ឋកិច្ចអតិផរណាខ្ពស់) ដែលមានរូបិយប័ណ្ណគោលខុសពីរូបិយប័ណ្ណសម្រាប់បង្ហាញ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណសម្រាប់បង្ហាញ ដូចខាងក្រោម ៖

១) ទ្រព្យសកម្មនិងបំណុលក្នុងតារាងតុល្យការនីមួយៗដែលបានបង្ហាញ ត្រូវបានកត់ត្រាប្តូរតាមអត្រានាថ្ងៃបិទបញ្ជីនាកាលបរិច្ឆេទតារាងតុល្យការ ។

២) ដើមទុនក្នុងតារាងតុល្យការនីមួយៗដែលបានបង្ហាញ ត្រូវបានកត់ត្រាប្តូរតាមអត្រាថ្លៃដើម នាកាលបរិច្ឆេទទិញ ។

៣) ចំណូលនិងចំណាយក្នុងរបាយការណ៍លទ្ធផលនីមួយៗ ត្រូវបានកត់ត្រាប្តូរតាមអត្រាមធ្យមភាគ (លើកលែងតែអត្រាមធ្យមភាគនេះ មិនមែនជាអត្រាបង្គរប៉ាន់ប្រមាណដ៏សមហេតុផល នាកាលបរិច្ឆេទប្រតិបត្តិការ ដែលក្នុងករណីនេះចំណូល និងចំណាយត្រូវបានកត់ត្រាប្តូរតាមអត្រាកាលបរិច្ឆេទប្រតិបត្តិការវិញ ។

៤) រាល់លម្អៀងដែលបណ្តាលមកពីការប្តូរទាំងអស់ ត្រូវបានកត់ត្រាដាច់ដោយឡែកក្នុងគណនីមូលធន ។

## ២.៦ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសមតុល្យ ដែលមានកាលកំណត់តិចជាងឬស្មើបីខែ ក្នុងនោះរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានកម្រិតនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ។

## ២.៧ ឥណទាននិងបុរេប្រទានអតិថិជន

ឥណទាននិងបុរេប្រទានអតិថិជនទាំងអស់ ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការតាមចំនួនទឹកប្រាក់ដើមដកចំនួន ដែលបានជម្រះចេញពីបញ្ជីនិងសំវិធានធនឥណទានបាត់បង់ ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពជាក់ស្តែងអំពីលទ្ធភាពក្នុងការប្រមូលប្រាក់មកវិញ ។ ឥណទាននិងបុរេប្រទានដែលប្រមូលបានមកវិញ បន្ទាប់ពីបានជម្រះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសំវិធានធនដើម្បីកាត់បន្ថយចំនួនសំវិធានធនឥណទាន និងបុរេប្រទានបាត់បង់រួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ២.៨ សំវិធានធនឥណទានបាត់បង់

សម្ព័ន្ធធនាគារបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្តាល លេខធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី "ការធ្វើចំណាត់ថ្នាក់ឥណទាននិងសំវិធានធន សម្រាប់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុ" ។ ប្រកាសនេះត្រូវអនុវត្តចំពោះឥណទាន បុរេប្រទាន និងទ្រព្យសកម្មផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នា ។ កម្រិតចាំបាច់អប្បបរមានៃសំវិធានធនឥណទានបាត់បង់ត្រូវបានធ្វើអាស្រ័យតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមានព័ត៌មានផ្សេងទៀតដែលចង្អុលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ ។

តារាងខាងក្រោមនេះបង្ហាញពីចំណាត់ថ្នាក់ឥណទាន និងតម្រូវការសំវិធានធនអប្បបរមា៖

| | ចំនួនថ្ងៃលើសកំណត់ | អត្រាសំវិធានធន |
|---|---|---|
| សំវិធានធនទូទៅ៖ | | |
| ឥណទានធម្មតា | < ៣០ថ្ងៃ | ១% |
| សំវិធានធនជាក់លាក់៖ | | |
| ឥណទានឃ្លាំមើល | ≥ ៣០ថ្ងៃ - ៨៩ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ≥ ៩០ថ្ងៃ - ១៧៩ថ្ងៃ | ២០% |
| ឥណទានសង្ស័យ | ≥ ១៨០ថ្ងៃ - ៣៥៩ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | លើសពី ៣៦០ថ្ងៃឡើងទៅ | ១០០% |

ការធ្វើចំណាត់ថ្នាក់ឥណទាននិងសំវិធានធន ត្រូវផ្តោតការយកចិត្តទុកដាក់លើកត្តាពីរ គឺកត្តាហួសកាលកំណត់សង និងកត្តាគុណភាពឥណទាន ។

## ២.៩ កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

| សាច់ប្រាក់ក្នុងដៃ | ២៨៦.២១៦.៦២១ | ១.១៥៥.៤៥៦.៤៩៩ | ២៣៦.៥២១.២២៧ | ៩៥៧.៩១០.៩៦៩ | ២៧៦.៤២៨.៧៦៧ | ១.១១៥.៩៤២.៩៣២ | ២២៥.១២៦.៨៧៥ | ៩១១.៧៦៣.៨៤៤ |
| សមតុល្យនៅធនាគារកណ្តាល ៖ | | | | | | | | |
| គណនីចរន្ត | ៣២៣.៥៩៧.៨២៩ | ១.៣០៦.៣៦៤.៤៣៦ | ២៣៩.៧២១.៨២៣ | ៩៧០.៨៧៣.៣៨៣ | ៣២៣.៥៩៧.៨២៩ | ១.៣០៦.៣៦៤.៤៣៦ | ២៣៩.៧២១.៨២៣ | ៩៧០.៨៧៣.៣៨៣ |
| មូលបត្រ ប្រាក់បញ្ញើអាចជួញដូរបានដែលមានកាលកំណត់បីខែ ឬតិចជាងបីខែ | ៤៨១.៣៧៧.២៦១ | ១.៩៤៣.៣២០.០០៣ | ២២៩.០១២.៣៤៦ | ៩២៧.៥០០.០០១ | ៤៨១.៣៧៧.២៦១ | ១.៩៤៣.៣២០.០០៣ | ២២៩.០១២.៣៤៦ | ៩២៧.៥០០.០០២ |
| សមតុល្យនៅធនាគារផ្សេងៗ ៖ | | | | | | | | |
| គណនីចរន្ត | ៩៥.២០៩.០៩០ | ៣៨៤.៣៥៩.០៩៦ | ១១៩.៦៥២.៧៣៨ | ៤៨៤.៥៩៣.៥៩០ | ៨០.២៤៤.៤៦០ | ៣២៣.៩៤៦.៨៨៥ | ១០២.១៨៦.០៦១ | ៤១៣.៨៥៣.៥៤៧ |
| គណនីសន្សំ | ៨២៩.៧៣៧ | ៣.៣៤៩.៦៤៨ | ២.១៤១.៣៣៣ | ៨.៦៧២.៣៩៩ | ៨២៩.៧៣៧ | ៣.៣៤៩.៦៤៨ | ២.១៤១.៣៣៣ | ៨.៦៧២.៣៩៩ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលកំណត់បីខែ ឬតិចជាងបីខែ | ១.០០០.០០០ | ៤.០៣៧.០០០ | ៣.៤៨៧.៦៥៤ | ១៤.១២៤.៩៩៩ | ១.០០០.០០០ | ៤.០៣៧.០០០ | ១.៩៨៧.៦៥៤ | ៨.០៤៩.៩៩៨ |
| | ១.១៨៨.២៣០.៥៣៨ | ៤.៧៩៦.៨៨៦.៦៨២ | ៨៣០.៥៣៧.១២១ | ៣.៣៦៣.៦៧៥.៣៤១ | ១.១६៣.៤៧៨.០៥៤ | ៤.៦៩៦.៩៦០.៩០៤ | ៨០០.១៧៦.០៩២ | ៣.២៤០.៧១៣.១៧៣ |

## ២៨. លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ

| | | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|---|
| | កំណត់ | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១៥៨.៣៨៣.២១៣ | ៦៣៩.៣៩៣.០៣០ | ១៣២.៥៩១.២៨០ | ៥៣៦.៩៩៤.៦៨៤ | ១៥២.៨២១.២៤៦ | ៦១៦.៩៣៩.៣៧១ | ១៣២.៩៣៣.៣៥៣ | ៥៣៨.៣៨០.០៨០ |
| និយ័តកម្ម ៖ | | | | | | | | | |
| រំលស់ទ្រព្យសម្បត្តិនិងបរិក្ខារ | ១១ | ២២.៨៨៨.៩៨៧ | ៩២.៤០២.៨៤១ | ១៦.១៨៩.៥៤៥ | ៦៥.៥៦៧.៦៥៧ | ២១.៥១៩.៨៣២ | ៨៦.៨៧៥.៥៦២ | ១៤.៥៣៦.៤៧១ | ៥៨.៨៧២.៧០៨ |
| រំលស់ទ្រព្យសកម្មអរូបី | ១២ | ៣.៣១១.០៧៩ | ១៣.៣៦៦.៨២៦ | ២.៩៨៨.៣៦២ | ១២.១០២.៨៦៦ | ៣.០៧៧.២២៨ | ១២.៤២២.៧៦៩ | ២.៧៥៨.២៦៧ | ១១.១៧០.៩៨១ |
| និយ័តកម្មទ្រព្យសម្បត្តិនិងបរិក្ខារ | ១១ | ៨២.៥៥៩ | ៣៣៣.២៩១ | - | - | ៨២.៥៥៩ | ៣៣៣.២៩១ | - | - |
| និយ័តកម្មទ្រព្យសកម្មអរូបី | ១២ | ៤៨.៤៥២ | ១៩៥.៦០១ | - | - | ៤៨.៤៥២ | ១៩៥.៦០១ | - | - |
| ចំណាយមូលនិធិសោធននិវត្តន៍ (ការរួមចំណែករបស់សម្ព័ន្ធធនាគារ/ធនាគារ) | ១៩(ក) | ៦.០២៥.៥២៥ | ២៤.៣២៥.០៤៤ | ៥.៤៦៩.៩៥៩ | ២២.១៥៣.៣៣៤ | ៥.៧២១.៤៥៨ | ២៣.០៩៧.៥២៦ | ៥.១៧៥.៥៤៨ | ២០.៩៦០.៨៦៩ |
| សំវិធានធនឥណទានបាត់បង់ | ៧(ក) | ១៣.៦៥៥.០២៣ | ៥៥.១២៥.៣២៨ | ៩.៦២៧.៨៧៧ | ៣៨.៩៩២.៩០២ | ១២.៥១៦.៩៤១ | ៥០.៥៣០.៨៩១ | ៧.៦២៦.៣៨២ | ៣០.៨៨៦.៨៤៧ |
| ចំណូលការប្រាក់សុទ្ធ | ២១ | (២៨៧.២២៣.០៣៥) | (១.១៥៩.៥១៩.៣៩២) | (២៥៦.៦៩៧.២០៣) | (១.០៣៩.៦២៣.៦៧៣) | (២៧៥.០៧៨.៥៧០) | (១.១១០.៤៩២.១៨៧) | (២៤៦.៣៣១.២០៦) | (៩៩៧.៦៤១.៣៨៤) |
| ចំណេញពីការលក់ទ្រព្យសម្បត្តិនិងបរិក្ខារ | | (៧៥.៥៥៨) | (៣០៥.០២៨) | (២២.០៨៧) | (៨៩.៤៥២) | (៩៦.៥៤៣) | (៣៨៩.៧៤៤) | (៣៧.៤៧៦) | (១៥១.៧៧៨) |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់បានទទួលស្គាល់ | | (៥១៩.៩០៨) | (២.៣០០.៧១៩) | ៣៩.២៣៣ | ១៥៨.៨៩២ | (២៣.១៩១) | (៩៣.៦២៤) | (៣៤.៦៩១) | (១៤០.៥០០) |
| | | (៨៣.៤៧៣.៦៦៣) | (៣៣៦.៩៨៣.១៧៨) | (៨៩.៨១៣.០៣៤) | (៣៦៣.៧៤២.៧៩០) | (៧៩.៤១០.៥៨៨) | (៣២០.៥៨០.៥៤៤) | (៨៣.៣៧៣.៣៥២) | (៣៣៧.៦៦២.០៧៧) |
| **បម្រែបម្រួលដើមទុនបង្វិល** | | | | | | | | | |
| ឥណទាននិងបុរេប្រទានអតិថិជន | | (៣៤៧.១៥៨.៦៨០) | (១.៤០១.៤៧៩.៥៩១) | (៤៧៣.៨២៧.១៣១) | (១.៩១៨.៩៩៩.៨៨១) | (៣២០.៦៨៧.៥៣៥) | (១.២៩៤.៦១៥.៧៤០) | (៤៥៨.០០៨.១០៦) | (១.៨៥៤.៩៣២.៨២៩) |
| សមតុល្យនៅធនាគារកណ្តាល | | (២.១៧៧.៥២៦) | (៨.៧៩០.៦៧២) | ៨.៤៣៩.៣៥២ | ៣៤.១៨០.៩៩៦ | (២.១៧៧.៥២៦) | (៨.៧៩០.៦៧២) | ៨.៤៣៩.៣៥២ | ៣៤.១៨០.៩៩៦ |
| ទុនបម្រុងកាតព្វកិច្ចនៅធនាគារកណ្តាល | | (៥៧.៣៦៣.២៩៣) | (២៣១.៥៧៥.៦១៤) | (៩៨.៨៤៨.២៨៧) | (៤០០.៣៣៥.៥៦២) | (៥៧.៣៦៣.២៩៣) | (២៣១.៥៧៥.៦១៤) | (៩៨.៨៤៨.២៨៧) | (៤០០.៣៣៥.៥៦២) |
| សមតុល្យនៅធនាគារផ្សេងៗ | | (២.៤៨៦.១៨៧) | (១០.០៣៦.៧៣៧) | ១១.០៤៧.៥២៦ | ៤៤.៧៤២.៤៨០ | ៥០០.០០០ | ២.០១៨.៥០០ | ១.០០០.០០០ | ៤.០៥០.០០០ |
| ទ្រព្យសកម្មផ្សេងៗ | | (៩.២២២.៦៧៦) | (៣៧.២៣១.៩៤៣) | (៥.៤០០.៩៧៦) | (២១.៨៧៣.៩៥៣) | (៨.៧៧៩.៧២៧) | (៣៥.៤៤៣.៧៥៨) | (៥.៩១៦.១២៦) | (២៣.៩៦០.៣១១) |
| ប្រាក់បញ្ញើរបស់អតិថិជន | | ៣៤២.៨១៨.១៩៤ | ១.៣៨៣.៩៥៧.០៤៩ | ៣៧៦.៧២៧.២៤០ | ១.៥២៥.៧៤៥.៣២២ | ៣៥៧.៤៦៩.៩៩៣ | ១.៤៤៣.១០៦.៣៦២ | ៣៧០.២៣១.៣៣៦ | ១.៤៩៩.៤៣៦.៩១១ |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | | ៨៧.៧១៣.០១០ | ៣៥៤.០៩៧.៤២១ | ៤៩.០២២.៥២០ | ១៩៨.៥៤១.២០៦ | ៧៧.៨៤៤.៦៦៩ | ៣១៤.២៥៨.៩២៩ | ៤៣.៧៤៥.៤៦០ | ១៧៧.១៦៩.១១៣ |
| មូលនិធិសោធននិវត្តន៍ | | ៣.១៨៥.០០៣ | ១២.៨៥៧.៨៥៧ | ៣.៥៨០.៣៣៥ | ១៤.៥០០.៣៥៧ | ៣.១៣៤.៣៤៣ | ១២.៦៥៣.៣៤៣ | ៣.៥៣៧.៤៨៣ | ១៤.៣២៦.៨០៦ |
| អត្ថប្រយោជន៍ពេលចូលនិវត្ត | | ១.៧៥២.៩៥៦ | ៧.០៧៦.៦៨៣ | ៨២១.៦៤៧ | ៣.៣២៧.៦៧០ | ១.៦៦១.៦០៤ | ៦.៧០៧.៨៩៥ | ៧៧៨.៧២០ | ៣.១៥៣.៨១៦ |
| បំណុលផ្សេងៗ | | (៣.៤៥៤.២៩៣) | (១៣.៩៤៤.៩៨០) | ១៣.៤៦៨.៣៦៩ | ៥៤.៥៤៦.៨៩៧ | (៣.៦១៩.០៤០) | (១៤.៦១០.០៦៥) | ១២.៩២៨.៣៤៩ | ៥២.៣៥៩.៨១៤ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងប្រតិបត្តិការ | | (៦៩.៨៦៧.១៥៥) | (២៨២.០៥៣.៧០៥) | (២០៤.៧៨២.០៣៩) | (៨២៩.៣៦៧.២៥៨) | (៣១.៤២៧.១៤០) | (១២៦.៨៧១.៣៦៤) | (២០៥.៤៨៤.៧៧១) | (៨៣២.២១៣.៣២៣) |
| ចំណូលការប្រាក់បានទទួល | | ៤០៩.២៤៩.៣០៦ | ១.៦៥២.១៣៩.៤៤៨ | ៣៥០.៨២៤.៥៥២ | ១.៤២០.៨៣៩.៤៣៦ | ៣៩០.៤៩១.៩១៤ | ១.៥៧៦.៤១៥.៨៥៥ | ៣៣៣.៦៤៦.៦៥៣ | ១.៣៥១.២៦៨.៩៤៦ |
| ចំណាយការប្រាក់បានបង់ | ២៦(ក) | (១១៧.៥៣៩.៨០០) | (៤៧៤.៥០៨.១៧៣) | (៨៩.៤០២.០១៣) | (៣៦២.០៧៨.១៥៣) | (១១០.៣៥៦.៨៧៦) | (៤៤៥.៥១០.៧០៨) | (៨២.៥៩៨.៤៧០) | (៣៣៤.៥២៣.៨០៤) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៩(ក) | (៣០.៤២២.៣៥៤) | (១២២.៨១៥.០៤៣) | (២៤.៩២៣.៩៥០) | (១០០.៩៤១.៩៩៨) | (២៩.៩៥៨.៤៤៥) | (១២០.៩៤២.២៤២) | (២៤.៣៤៦.៤៩០) | (៩៨.៦០៣.២៨៥) |
| មូលនិធិសោធននិវត្តន៍បានបង់ | ១៩(ខ) | (១.៥២៧.៧៦៧) | (៦.១៦៧.៥៩៥) | (៩១២.៣០៨) | (៣.៦៩៤.៨៤៧) | (១.១៧៧.២១៨) | (៤.៧៥២.៤២៩) | (៦០៥.៨៧៨) | (២.៤៥៣.៨០៦) |
| អត្ថប្រយោជន៍ពេលចូលនិវត្តបានបង់ | | (១៤៨.០៣៥) | (៥៩៧.៦១៧) | (១៤៨.១៤៤) | (៥៩៩.៩៨៣) | (១៤៨.០៣៥) | (៥៩៧.៦១៧) | (១៤៨.១៤៤) | (៥៩៩.៩៨៣) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | | ១៨៩.៧៤៤.១៩៥ | ៧៦៥.៩៩៧.៣១៥ | ៣០.៦៥៦.០៩៨ | ១២៤.១៥៧.១៩៧ | ២១៧.៤២៤.២០០ | ៨៧៧.៧៤១.៤៩៥ | ២០.៤៦២.៩០០ | ៨២.៨៧៤.៧៤៥ |

## ២៩. កិច្ចសន្យា និង យថាភាព

សម្ព័ន្ធធនាគារនិងធនាគារមានចំនួនទឹកប្រាក់ក្នុងកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការរបស់សម្ព័ន្ធធនាគារនិងធនាគារដែលត្រូវពន្យារឥណទានជូនអតិថិជន លិខិតធានាធនាគារ និងកញ្ចប់ឥណទានផ្សេងៗដូចខាងក្រោម ៖

### (ក) កិច្ចសន្យាឥណទាន លិខិតធានាធនាគារ និងបំណុលហិរញ្ញវត្ថុផ្សេងៗ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ៩៦.៣៦៥.៥៤០ | ៣៨៩.០២៧.៦៨៥ | ៨៣.៨៤៧.០៩០ | ៣៣៩.៥៨០.៧១៥ | ៩៦.៣៦៥.៥៤០ | ៣៨៩.០២៧.៦៨៥ | ៨៣.៨៤៧.០៩០ | ៣៣៩.៥៨០.៧១៥ |
| លិខិតធានាធនាគារ | ៤២.៣៤៨.៣៩៤ | ១៧០.៩៦០.៤៦៧ | ៣៤.២២៨.០៦៦ | ១៣៨.៦២៣.៦៦៧ | ៤២.៣៣៤.៣៣៥ | ១៧០.៩០៣.៧១០ | ៣៤.២២៣.២៦៣ | ១៣៨.៦០៤.២១៥ |
| លិខិតឥណទាន | ១៥.៨៥៥.៤០១ | ៦៤.០០៨.២៥៤ | ១៨.០៨៥.០៤០ | ៧៣.២៤៤.៤១២ | ១៥.៨៥៥.៤០១ | ៦៤.០០៨.២៥៤ | ១៨.០៨៥.០៤០ | ៧៣.២៤៤.៤១២ |
| | ១៥៤.៥៦៩.៣៣៥ | ៦២៣.៩៩៦.៤០៦ | ១៣៦.១៦០.១៩៦ | ៥៥១.៤៤៨.៧៩៤ | ១៥៤.៥៥៥.២៧៦ | ៦២៣.៩៣៩.៦៤៩ | ១៣៦.១៥៥.៣៩៣ | ៥៥១.៤២៩.៣៤២ |

មិនមានការខាតបង់ជាសារវន្តបណ្តាលមកពីព្រឹត្តិការណ៍ទាំងនេះទេ ។

### (ខ) កិច្ចសន្យាភតិសន្យាប្រតិបត្តិ - សម្ព័ន្ធធនាគារ និងធនាគារជាភាគីជួល

សម្ព័ន្ធធនាគារនិងធនាគារមានកិច្ចសន្យាភតិសន្យាប្រតិបត្តិសម្រាប់ការជួលអគារការិយាល័យរបស់ខ្លួននិងការិយាល័យសាខាជាមួយភាគីដទៃទៀត ដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនលើស១ឆ្នាំ | ៩.៧២៣.០៥១ | ៣៩.២៥១.៩៥៧ | ៨.៩១០.៦៩១ | ៣៦.០៨៨.២៩៩ | ៨.៩៨៩.៨៩៦ | ៣៦.២៩២.២១០ | ៨.២០៨.៥៣០ | ៣៣.២៤៤.៥៤៧ |
| លើស១ឆ្នាំប៉ុន្តែមិនលើស៥ឆ្នាំ | ២៣.០៤៣.៦៦៤ | ៩៣.០២៧.២៧២ | ២៣.១១១.៩២៨ | ៩៣.៦០៣.៣០៨ | ២០.៨៩៣.៧១១ | ៨៤.៣៤៧.៩១១ | ២០.៦៧១.០៤១ | ៨៣.៧១៧.៧១៦ |
| លើស៥ឆ្នាំ | ១១.១៩៥.៩៦៣ | ៤៥.១៩៨.១០៣ | ១១.០៣០.៧៩០ | ៤៤.៦៧៤.៧០០ | ៧.៤១៥.២៨១ | ២៩.៩៣៥.៤៨៩ | ៦.៧៤៧.៥២៧ | ២៧.៣២៧.៤៨៤ |
| | ៤៣.៩៦២.៦៧៨ | ១៧៧.៤៧៧.៣៣២ | ៤៣.០៥៣.៤០៩ | ១៧៤.៣៦៦.៣០៧ | ៣៧.២៩៨.៨៨៨ | ១៥០.៥៧៥.៦១០ | ៣៥.៦២៧.០៩៨ | ១៤៤.២៨៩.៧៤៧ |

### (គ) កិច្ចសន្យាទាក់ទងនឹងទ្រព្យសម្បត្តិនិងបរិក្ខារ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនលើស១ឆ្នាំ | ២២.៧៩៨.៣៩៧ | ៩២.០៣៧.១២៩ | ៣.៧២៤.៥៨៩ | ១៥.០៨៤.៥៨៥ | ១០.៦៨៦.៦៤៧ | ៤៣.១៤១.៩៩៤ | ៣.៦៦៧.៦៤០ | ១៤.៨៥៣.៩៤២ |
| លើស១ឆ្នាំប៉ុន្តែមិនលើស៥ឆ្នាំ | ៦.១៦៤.៧០៩ | ២៤.៨៨៦.៩៣០ | ៤.៦៥១.៤០៥ | ១៨.៨៣៨.១៩០ | - | - | ៤.៦៥១.៤០៥ | ១៨.៨៣៨.១៩០ |
| | ២៨.៩៦៣.១០៦ | ១១៦.៩២៤.០៥៩ | ៨.៣៧៥.៩៩៤ | ៣៣.៩២២.៧៧៥ | ១០.៦៨៦.៦៤៧ | ៤៣.១៤១.៩៩៤ | ៨.៣១៩.០៤៥ | ៣៣.៦៩២.១៣២ |

សមតុល្យធំៗជាសារវន្តចំពោះកិច្ចសន្យាទាំងនេះ គឺពាក់ព័ន្ធទៅនឹងកិច្ចសន្យាសាងសង់អគារ disaster recovery site និងការទិញបរិក្ខារផ្សេងៗ ។

### (ឃ) កិច្ចសន្យាផ្សេងៗ

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ ធនាគារបានធានាលើកិច្ចព្រមព្រៀងឥណទានរបស់ វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាមួយនឹង International Finance Corporation ("IFC") ដែលមានទឹកប្រាក់ចំនួន ១៣.០០០.០០០ដុល្លារអាមេរិក ដែលនឹងត្រូវផុតកំណត់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ។ ឥណទាននេះត្រូវបានដកចំនួន ៥.០០០.០០០ ដុល្លារអាមេរិក នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ ។

## ៣០. ប្រតិបត្តិការភាគីពាក់ព័ន្ធ

### (ក) ភាគីពាក់ព័ន្ធ និងទំនាក់ទំនង

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង |
|---|---|
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ក្រុមហ៊ុនមេ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដូចបានលាតត្រដាងនៅក្នុងកំណត់សម្គាល់១០ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| គណៈគ្រប់គ្រងសំខាន់ៗ | បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗគឺជាបុគ្គលទាំងឡាយណាដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលក្នុងការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពនានារបស់សម្ព័ន្ធធនាគារ និងធនាគារ ។ បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗរបស់សម្ព័ន្ធធនាគារ និងធនាគារ រួមមានក្រុមប្រឹក្សាភិបាលទាំងអស់របស់ធនាគារ និងសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ។ |

## (ខ) សមតុល្យភាគីពាក់ព័ន្ធ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **១) ឥណទាននិងបុរេប្រទាន** | | | | | | | | |
| គណៈគ្រប់គ្រងសំខាន់ៗ | ១១.៩៤៧.២២៩ | ៤៨.២៣០.៩៦៣ | ១១.២៦៣.៣៧៥ | ៤៥.៦១៦.៦៦៩ | ១១.០០៩.៥៥៦ | ៤៤.៤៤៥.៧៣៩ | ១០.៤១៤.២០២ | ៤២.១៧៧.៥១៨ |
| **២) សមតុល្យជាមួយភាគីពាក់ព័ន្ធ** | | | | | | | | |
| SMBC | ២៥៤.៤២៤ | ១.០២៧.១១០ | ២២២.០៧២ | ៨៩៩.៣៩២ | ២៥៤.៤២៤ | ១.០២៧.១១០ | ២២២.០៧២ | ៨៩៩.៣៩២ |
| **៣) គណនីត្រូវទទួល/គណនីត្រូវសង ជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ** | | | | | | | | |
| ធនាគារ អេស៊ីលីដា ឡាវ | | | | | | | | |
| គណនីត្រូវទទួលផ្សេងៗ | - | - | - | - | ១៧.១៩១ | ៦៩.៣៦០ | ១២.៨៨៨ | ៥២.១៩៦ |
| គណនីត្រូវសងផ្សេងៗ | - | - | - | - | - | - | ៤.១១០ | ១៦.៦៤៦ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី | | | | | | | | |
| គណនីត្រូវទទួលផ្សេងៗ | - | - | - | - | - | - | ១០ | ៤១ |
| គណនីត្រូវសងផ្សេងៗ | - | - | - | - | ៤២.៥១២ | ១៧១.៦២១ | ៤២.០០៨ | ១៧០.១៣២ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | | | | | | | | |
| គណនីត្រូវទទួលផ្សេងៗ | - | - | - | - | - | - | ៩៦.៧១៥ | ៣៩១.៦៩៦ |
| គណនីត្រូវសងផ្សេងៗ | - | - | - | - | ៩២.៥៥០ | ៣៧៣.៦២៤ | ១២៣.១១៣ | ៤៩៨.៦០៧ |
| ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា | | | | | | | | |
| គណនីត្រូវទទួលផ្សេងៗ | - | - | - | - | ៩៧.៨៥០ | ៣៩៥.០២០ | ១៤៣.៧៧៧ | ៥៨២.២៩៧ |
| គណនីត្រូវសងផ្សេងៗ | - | - | - | - | - | - | - | - |
| | - | - | - | - | ២៥០.០៩៣ | ១.០០៩.៦២៥ | ៤២២.៦២១ | ១.៧១១.៦១៥ |
| **៤) ប្រាក់បញ្ញើរបស់ភាគីពាក់ព័ន្ធ** | | | | | | | | |
| គណៈគ្រប់គ្រងសំខាន់ៗ | ៣.២៥៦.១៦៥ | ១៣.១៩៥.១៣៨ | ២.៣០៤.១៣៦ | ៩.៣៣១.៧៥១ | ៣.០៤២.៤៩២ | ១២.២៨២.៥៤០ | ២.០៧៨.២១២ | ៨.៤១៦.៧៥៨ |
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ២.៥៣២.១២៤ | ១០.២២២.១៨៥ | ១១០.១៩៧ | ៤៤៦.០៩៥ | ២.៥៣២.១២៤ | ១០.២២២.១៨៥ | ១១០.១៩៧ | ៤៤៦.០៩៥ |
| ASA Plc. | ១០៧.៨៨៣ | ៤៣៥.៥២៤ | ១៤០.៩៧២ | ៥៧០.៩៣៧ | ១០៧.៨៨៣ | ៤៣៥.៥២៤ | ១៤០.៩៧២ | ៥៧០.៩៣៧ |
| ធនាគារ អេស៊ីលីដា ឡាវ | | | | | | | | |
| គណនីចរន្ត | - | - | - | - | ៦៣០.៥៨៥ | ២.៥៤៥.៦៧២ | ១.០៨២.៦៤៣ | ៤.៣៨៤.៧០៤ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | - | - | - | - | - | - | ១.៥០០.០០០ | ៦.០៧៥.០០០ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី | | | | | | | | |
| គណនីចរន្ត | - | - | - | - | - | - | ១.៣៩៩ | ៥.៦៦៦ |
| គណនីសន្សំ | - | - | - | - | ១១៥.៨៣៩ | ៤៦៧.៦៤២ | ៦៩.៧០៩ | ២៨២.៣២១ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | - | - | - | - | ១.៧៤០.០០០ | ៧.០២៤.៣៨០ | ១.៧៣០.០០០ | ៧.០០៦.៥០០ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | | | | | | | | |
| គណនីចរន្ត | - | - | - | - | ១០៩.០៨០ | ៤៤០.៣៥៦ | ៨៨.១៩២ | ៣៥៧.១៧៨ |
| គណនីសន្សំ | - | - | - | - | ៣.២៩១ | ១៣.២៨៦ | ១៥០ | ៦០៨ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | - | - | - | - | ១០.០៥០.០០០ | ៤០.៥៧១.៨៥០ | ២.៧៣៥.៥៤០ | ១១.០៧៨.៩៣៧ |
| ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា | | | | | | | | |
| គណនីចរន្ត | - | - | - | - | - | - | - | - |
| ក្រុមហ៊ុន អេស៊ីលីដា ប្រូភើធី អិលធីឌី | | | | | | | | |
| គណនីសន្សំ | - | - | - | - | ៣.២២៥ | ១៣.០១៩ | ៤.០៩៩ | ១៦.៦០១ |
| | ៥.៨៩៦.១៧២ | ២៣.៨០២.៨៤៧ | ២.៥៥៥.២៥៥ | ១០.៣៤៨.៧៨៣ | ១៨.៣៣៤.៥១៩ | ៧៤.០១៦.៤៥៤ | ៩.៥៤១.០៦៣ | ៣៨.៦៤១.៣០៥ |

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **៥) ប្រាក់កម្ចីពីភាគីពាក់ព័ន្ធ** | | | | | | | | |
| ភាគទុនិក (កំណត់សម្គាល់១៧) | ៧៧.៨២២ | ៣១៤.១៦៧ | ១.៦៣៦.៧៤៦ | ៦.៦២៨.៨២១ | ៧៧.៨២២ | ៣១៤.១៦៧ | ១.៦៣៦.៧៤៦ | ៦.៦២៨.៨២១ |

## (គ) ប្រតិបត្តិការភាគីពាក់ព័ន្ធ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **១) ចំណូលការប្រាក់ពីភាគីពាក់ព័ន្ធ** | | | | | | | | |
| គណៈគ្រប់គ្រងសំខាន់ៗ-ឥណទាននិងបុរេប្រទាន | ៨០៧.៨៦៣ | ៣.២៦១.៣៤៣ | ១.៣០៣.២១០ | ៥.២៧៨.០០១ | ៧១៦.២៥៧ | ២.៨៩១.៥៣០ | ១.២៥៩.៥០៣ | ៥.១០០.៩៨៧ |
| **២) ចំណូលកម្រៃនិងជើងសារពីភាគីពាក់ព័ន្ធ** | | | | | | | | |
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ២៤.០០០ | ៩៦.៨៨៨ | ២០.០០០ | ៨១.០០០ | ២៤.០០០ | ៩៦.៨៨៨ | ២០.០០០ | ៨១.០០០ |
| ASA Plc. | ៥០០ | ២.០១៩ | ៥០០ | ២.០២៥ | ៥០០ | ២.០១៩ | ៥០០ | ២.០២៥ |
| ក្រុមហ៊ុន អេស៊ីលីដា ប្រូភើធី អិលធីឌី | - | - | - | - | ២៤០ | ៩៦៩ | - | - |
| ធនាគារ អេស៊ីលីដា ឡាវ | - | - | - | - | ៦.៣៣១ | ២៥.៥៥៨ | ១០.៤៥៩ | ៤២.៣៥៩ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | - | - | - | - | ៤៨.៩៣៧ | ១៩៧.៥២០ | ៧៧.៦៩៨ | ៣១៤.៦៧៧ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | - | - | - | - | ៤១៧ | ១.៦៨៣ | ៣៤១ | ១.៣៨១ |
| | ២៤.៥០០ | ៩៨.៩០៧ | ២០.៥០០ | ៨៣.០២៥ | ៨០.៤៦៥ | ៣២៤.៨៣៧ | ១០៨.៩៩៨ | ៤៤១.៤៤២ |
| **៣) ចំណាយការប្រាក់ឲ្យភាគីពាក់ព័ន្ធ** | | | | | | | | |
| គណៈគ្រប់គ្រងសំខាន់ៗ-ប្រាក់បញ្ញើ | ១៥៥.១៧៦ | ៦២៦.៤៤៦ | ២២.២៤១ | ៩០.០៧៦ | ១៣១.៣៥៥ | ៥៣០.២៨០ | ៨.៧៣៦ | ៣៥.៣៨១ |
| ភាគទុនិក-ប្រាក់កម្ចីនិងបំណុលបន្ទាប់បន្សំ | ៨៣.៧០២ | ៣៣៧.៩០៥ | ៣៩៧.៣២៧ | ១.៦០៩.១៧៤ | ៨៣.៧០២ | ៣៣៧.៩០៥ | ៣៩៧.៣២៧ | ១.៦០៩.១៧៤ |
| ធនាគារ អេស៊ីលីដា ឡាវ-ប្រាក់បញ្ញើ | - | - | - | - | ៨.៥៣១ | ៣៤.៤៤០ | ៣៧.៧៤០ | ១៥២.៨៤៧ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី-ប្រាក់បញ្ញើ | - | - | - | - | ១២៣.៨៨៧ | ៥០០.១៣២ | ១១២.៤៨១ | ៤៥៥.៥៤៨ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា-ប្រាក់បញ្ញើ | - | - | - | - | ១៣៦.០៥៦ | ៥៤៩.២៥៨ | ២០៤.១៥៨ | ៨២៦.៨៤០ |
| | ២៣៨.៨៧៨ | ៩៦៤.៣៥១ | ៤១៩.៥៦៨ | ១.៦៩៩.២៥០ | ៤៨៣.៥៣១ | ១.៩៥២.០១៥ | ៧៦០.៤៤២ | ៣.០៧៩.៧៩០ |
| **៤) ចំណាយកម្រៃនិងជើងសារឲ្យភាគីពាក់ព័ន្ធ** | | | | | | | | |
| ក្រុមប្រឹក្សាភិបាល | ៥៣៦.៥៤១ | ២.១៦៦.០១៦ | ៤៩៤.២៩៩ | ២.០០១.៩១១ | ៤៣០.៣០៣ | ១.៧៣៧.១៣៣ | ៤១០.៧៩៩ | ១.៦៦៣.៧៣៦ |
| គណៈគ្រប់គ្រងសំខាន់ៗ | ៩.៨០៩.៨៥៥ | ៣៩.៦០២.៣៨៥ | ៩.៥២៨.២១៨ | ៣៨.៥៨៩.២៨៣ | ៧.១៣១.២៥១ | ២៨.៧៨៨.៨៦០ | ៦.៩២៧.៩៩៩ | ២៨.០៥៨.៣៩៦ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | - | - | - | - | ១.៥១៨.៩៣៤ | ៦.១៣១.៩៣៧ | ១.៧០១.៦១៩ | ៦.៨៩១.៥៥៧ |
| | ១០.៣៤៦.៣៩៦ | ៤១.៧៦៨.៤០១ | ១០.០២២.៥១៧ | ៤០.៥៩១.១៩៤ | ៩.០៨០.៤៨៨ | ៣៦.៦៥៧.៩៣០ | ៩.០៤០.៤១៧ | ៣៦.៦១៣.៦៨៩ |

# ៣១. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

## (ក) សេចក្តីផ្តើម និងទស្សនៈទូទៅ

ស្ថិតនៅក្នុងគោលបំណងនៃគោលការណ៍នៃការគ្រប់គ្រងហានិភ័យ ហានិភ័យត្រូវបានឲ្យនិយមន័យថាជាលទ្ធភាពនៃ សកម្មភាពមួយ ឬព្រឹត្តិការណ៍មួយអាចប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្ម ឬដើមទុនរបស់ធនាគារ ។

វិធីសាស្ត្ររបស់ធនាគារក្នុងការកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យ និងការត្រួតពិនិត្យចម្បង ដែលត្រូវបានធ្វើ ឡើង ដោយគ្រប់ផ្នែកនៃអាជីវកម្មទាំងអស់របស់ធនាគារ ។ ដំណើរការគ្រប់គ្រងហានិភ័យនេះ គឺអនុវត្តស្របទៅតាមគោលការណ៍ស្តីពី គម្រោងការរួមបញ្ចូលគ្នាក្នុងការគ្រប់គ្រងហានិភ័យសហគ្រាស (Enterprise Risk Management Intergrated Framework) ដែលចេញដោយ Committee of Sponsoring Organisations of the Tread way Commission (COSO) ។ COSO បានកំណត់ការគ្រប់គ្រងហានិភ័យសហគ្រាសថា ជាដំណើរការមួយដែលបានត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលសហគ្រាស គណៈគ្រប់គ្រង និងបុគ្គលិកផ្សេងៗទៀត ដែលអនុវត្តក្នុងការកំណត់យុទ្ធសាស្ត្រនៅទូទាំងសហគ្រាស ហើយវិធីសាស្ត្រនេះត្រូវបានធ្វើឡើង ដើម្បីកំណត់ព្រឹត្តិការណ៍សក្តានុពលដែលអាចប៉ះពាល់ដល់ក្រុមហ៊ុន ហើយក៏ដើម្បីគ្រប់គ្រងហានិភ័យធ្វើយ៉ាងណាឱ្យស្ថិតនៅក្នុងរង្វង់កម្រិតហានិភ័យទទួលយកបាន (Risk Appetite) ដែលផ្តល់នូវការធានាសមស្រប យោងទៅលើការសម្រេចបាននូវគោលដៅ ។ នៅក្នុងគោលការណ៍នេះ កម្រិតហានិភ័យទទួលយកត្រូវបានកំណត់ថា ជាចំនួនហានិភ័យក្នុងកម្រិតទាំងមូលដែលក្រុមហ៊ុនមានបំណងនឹងទទួលយក ដើម្បីរក្សាបានតម្លៃភាគទុនិករយៈពេលវែង ។

ការប្រែប្រួលក្នុងអថេរម៉ាក្រូសេដ្ឋកិច្ច ឆ្លុះបង្ហាញពីភាពតានតឹងនៃបរិយាកាសជុំវិញដែលអាចលាតត្រដាងពីឥណទានជាលក្ខណៈប្រព័ន្ធភាពងាយនឹងបង្កហានិភ័យទីផ្សារ និងការរីករាលដាលនៃហានិភ័យ ។ ស្ត្រេសតេស្ត (Stress Test) ទាំងនេះធ្វើការ រួមបញ្ចូលសេណារីយ៉ូនូវករណីធ្ងន់ធ្ងរបំផុត ដើម្បីសាកល្បងហានិភ័យដែលអាច (រួមគ្នា) បំផ្លាញដល់ធនាគារ និងដើម្បីសាកល្បងនូវ អ្វីដែលបានបញ្ចូលជាសំណុំព្រឹត្តិការណ៍នានា ដែលត្រូវការចាំបាច់ក្នុងការបំផ្លាញដល់ធនាគារបាន (Reverse Stress Test) ។

## (ខ) គោលបំណង និងគោលការណ៍

គោលបំណងនៃគោលការណ៍គ្រប់គ្រងហានិភ័យ គឺដើម្បីកំណត់ជាបទដ្ឋានសម្រាប់ការគ្រប់គ្រងហានិភ័យសហគ្រាសទាំងមូលរបស់ធនាគារ និងក្នុងគោលបំណងធ្វើឲ្យមានតុល្យភាពកាន់តែប្រសើរ លើការចាត់ចែងហានិភ័យ ក្នុងខណៈបន្ថែមតម្លៃដល់ ធនាគារ ។ ម្យ៉ាងទៀតគោលការណ៍នេះ គឺអាចអនុវត្តបាននៅគ្រប់កម្រិតទាំងអស់នៃធនាគារ ។

គោលការណ៍គ្រប់គ្រងហានិភ័យ បែកចែកប្រភេទហានិភ័យខុសៗគ្នា ស្របទៅតាមប្រភេទនានាដែលកំណត់ដោយ Basel Accord ចេញដោយគណៈកម្មការ Basel លើការគ្រប់គ្រងធនាគារ ។ គោលការណ៍នេះបានបង្កើតជាកម្រិតដែនកំណត់ (Position Limit) ទៅតាមប្រភេទហានិភ័យនីមួយៗ ។ កម្រិតដែនកំណត់ (Position Limit) ត្រូវបានធ្វើឲ្យមានសុពលភាពដោយការប៉ាន់ ប្រមាណភាពងាយប្រឈម របស់ធនាគារទៅនឹងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងព្រឹត្តិការណ៍ខាងក្នុងដោយប្រើប្រាស់ស្ត្រេសតេស្ត និង ការវិភាគបែបសេណារីយ៉ូ ។ សម្រាប់គោលបំណងនៃគោលការណ៍នេះ ក្រុមប្រឹក្សាភិបាលបានបង្កើតជាគោលការណ៍ជាក់លាក់ និងកម្រិតដែនកំណត់សម្រាប់ប្រភេទហានិភ័យធំៗដូចខាងក្រោម ។

នៅគ្រប់ពេលទាំងអស់ ធនាគារត្រូវប្រកាន់ខ្ជាប់នូវអនុបាតប្រុងប្រយ័ត្ន និងតម្រូវការនានាដែលបានចែងដោយគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ។

នៅគ្រប់ពេលទាំងអស់ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ ធនាគារត្រូវប្រកាន់ខ្ជាប់នូវកម្រិតដែនកំណត់ (Position Limit) ដែលបានបង្កើតដោយក្រុមប្រឹក្សាភិបាលនៅក្នុងគោលការណ៍នេះ ដើម្បីកំណត់នូវការខាតបង់ជាសក្តានុពល ។

សកម្មភាពអាជីវកម្មរបស់សម្ព័ន្ធធនាគារប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ) និងហានិភ័យសន្ទនីយភាព ។ ការទទួល យកហានិភ័យ គឺជាស្នូលចំពោះអាជីវកម្មហិរញ្ញវត្ថុ ហើយហានិភ័យប្រតិបត្តិការគឺជាផលវិបាកមួយដែលមិនអាចជៀសវាងបានក្នុងដំណើរការអាជីវកម្ម ។

សម្ព័ន្ធធនាគារប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ (foreign Exchange contract) និងការផ្តោះប្តូរអត្រាការប្រាក់ (interest rate swaps) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួន ។

សម្ព័ន្ធធនាគារនិងធនាគារកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ២៨៦.២១៦.៦២១ | ១.១៥៥.៤៥៦.៤៩៩ | ២៣៦.៥២១.២២៧ | ៩៥៧.៩១០.៩៦៩ | ២៧៦.៤២៨.៧៦៧ | ១.១១៥.៩៤២.៩៣២ | ២២៥.១២៦.៨៧៥ | ៩១១.៧៦៣.៨៤៤ |
| សមតុល្យនៅធនាគារកណ្តាល ( * ) | ៨១៣.៧០៤.៤៦៨ | ៣.២៨៤.៩២៤.៩៣៨ | ៤៧៥.២៨៦.០២១ | ១.៩២៤.៩០៨.៣៨៥ | ៨១៣.៧០៤.៤៦៨ | ៣.២៨៤.៩២៤.៩៣៨ | ៤៧៥.២៨៦.០២១ | ១.៩២៤.៩០៨.៣៨៥ |
| សមតុល្យនៅធនាគារផ្សេងៗ ( * * ) | ៩៨.៧២៦.៨៧៧ | ៣៩៨.៥៦០.៤០២ | ១២៤.២៨១.៧២៥ | ៥០៣.៣៤០.៩៨៨ | ៨២.០៧៤.១៩៧ | ៣៣១.៣៣៣.៥៣៣ | ១០៦.៨១៥.០៤៨ | ៤៣២.៦០០.៩៤៤ |
| ឥណទាននិងបុរេប្រទានអតិថិជន ( * * * ) | ២.៩០៣.៩៨៨.៥០៥ | ១១.៧២៣.៤០១.៥៩៩ | ២.៥៦០.៥០៤.៩៩៧ | ១០.៣៧០.០៤៥.២៣៨ | ២.៧៧១.០៩៥.៩១៤ | ១១.១៨៦.៩១៤.២០៥ | ២.៤៥៣.៩១៩.៥៨៦ | ៩.៩៣៨.៣៧៤.៣២៤ |
| ទ្រព្យសកម្មផ្សេងៗ | ៣៤.៥៦៧.៨៩២ | ១៣៩.៥៥០.៥៨០ | ២៥.០៥២.៤៨៣ | ១០១.៤៦២.៥៥៦ | ៣៣.៤៨៣.៦១០ | ១៣៥.១៧៣.៣៣៤ | ២៤.៣៣២.០៣៥ | ៩៨.៥៤៤.៧៤២ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ៤.១៣៧.២០៤.៣៦៣ | ១៦.៧០១.៨៩៤.០១៤ | ៣.៤២១.៦៤៦.៤៥៣ | ១៣.៨៥៧.៦៦៨.១៣៦ | ៣.៩៧៦.៧៨៦.៩៥៦ | ១៦.០៥៤.២៨៨.៩៤២ | ៣.២៨៥.៤៧៩.៥៦៥ | ១៣.៣០៦.១៩២.២៣៩ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ៤០៣.២៥៣.១៥០ | ១.៦២៧.៩៣២.៩៦៧ | ៣១៥.៥៤០.១៤០ | ១.២៧៧.៩៣៧.៥៦៧ | ៣៩៥.៩២៥.៩១២ | ១.៥៩៨.៣៥២.៩០៧ | ៣១៨.០៨១.២៤៣ | ១.២៨៨.២២៩.០៣៤ |
| ប្រាក់បញ្ញើរបស់អតិថិជន | ២.៧២២.៩១៨.៣៤៥ | ១០.៩៩២.៤២១.៣៥៩ | ២.៣៨០.១០០.១៥១ | ៩.៦៣៩.៤០៥.៦១២ | ២.៦៥៥.៧៤៩.៧៦៥ | ១០.៧២១.២៦១.៨០១ | ២.២៩៨.២៧៩.៧៧២ | ៩.៣០៨.០៣៣.០៧៧ |
| បំណុលផ្សេងៗ | ៥៩.៦៩២.១១៥ | ២៤០.៩៧៧.០៦៨ | ៦១.៩៩៣.៦៥៥ | ២៥១.០៧៤.៣០៣ | ៥៦.៨១៦.៧៧២ | ២២៩.៣៦៩.៣០៩ | ៥៩.២១០.៩០៥ | ២៣៩.៨០៤.១៦៥ |
| ប្រាក់កម្ចី | ៦១៦.០៦៤.១៤១ | ២.៤៨៧.០៥០.៩៣៧ | ៤២៤.១១៩.៥៦២ | ១.៧១៧.៦៨៤.២២៦ | ៥៨២.០៤៨.៤៩១ | ២.៣៤៩.៧២៩.៧៥៨ | ៤១១.០១៥.០៦៨ | ១.៦៦៤.៦១១.០២៥ |
| បំណុលបន្ទាប់បន្សំ | ១០៩.៤០០.០០០ | ៤៤១.៦៤៧.៨០០ | ៩១.០០០.០០០ | ៣៦៨.៥៥០.០០០ | ១០៩.៤០០.០០០ | ៤៤១.៦៤៧.៨០០ | ៩១.០០០.០០០ | ៣៦៨.៥៥០.០០០ |
| **បំណុលហិរញ្ញវត្ថុសរុប** | ៣.៩១១.៣២៧.៧៥១ | ១៥.៧៩០.០៣០.១៣១ | ៣.២៧២.៧៥៣.៥០៨ | ១៣.២៥៤.៦៥១.៧០៨ | ៣.៧៩៩.៩៤០.៩៤០ | ១៥.៣៤០.៣៦១.៥៧៥ | ៣.១៧៧.៥៨៦.៩៨៨ | ១២.៨៦៩.២២៧.៣០១ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | ២២៥.៨៧៦.៦១២ | ៩១១.៨៦៣.៨៨៣ | ១៤៨.៨៩២.៩៤៥ | ៦០៣.០១៦.៤២៨ | ១៧៦.៨៤៦.០១៦ | ៧១៣.៩២៧.៣៦៧ | ១០៧.៨៩២.៥៧៧ | ៤៣៦.៩៦៤.៩៣៨ |

( * ) សមតុល្យនៅធនាគារកណ្តាល មិនរួមបញ្ចូលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ច ។
( * * ) សមតុល្យនៅធនាគារផ្សេងៗ មិនរួមបញ្ចូលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ចនៅធនាគារជាតិឡាវ ។
( * * * ) សមតុល្យឥណទាននិងបុរេប្រទានអតិថិជននេះ មិនរាប់បញ្ចូលសំវិធានធនឥណទានបាត់បង់ ។

## ៣១.១ ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការរងការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលភាគីម្ខាងទៀតនៃកិច្ចសន្យា ឬអតិថិជនរបស់ ធនាគារខកខាន ក្នុងការបំពេញកាតព្វកិច្ចនៃកិច្ចសន្យាចំពោះធនាគារ ដែលកើតឡើងពីសកម្មភាពនៃការផ្តល់បាក្រ់កម្ចី របស់ធនាគារ ការដាក់ប្រាក់បញ្ញើរ និងការទូទាត់ប្រតិបត្តិការ ។

### *គោលការណ៍ហានិភ័យឥណទាន*

- ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថា ការកត់ត្រាឥណទាន គឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណេញរបស់ធនាគារ តែផ្ទុយទៅវិញ ការកត់ត្រាឥណទាននេះ ក៏បង្កបង្កើតនូវហានិភ័យនៃការខាតបង់ដ៏ធ្ងន់ធ្ងរផងដែរ ។
- ក្រុមប្រឹក្សាភិបាលធ្វើការពិចារណាក្នុងការផ្តល់ឥណទានទៅកាន់ចំណែកទីផ្សារតូចៗ ដូចជាការផ្តល់កម្ចី ឥណទានទៅកាន់អាជីវកម្មខ្នាតតូចបំផុត និងខ្នាតតូច (ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍ដែលមានស្រាប់) ដូចដែលអ្នកធ្លាប់បានដឹង យើងនឹងទទួលរងនូវហានិភ័យឥណទាន ក្នុងកម្រិតទាបបំផុត ពេលដែលផ្តល់កម្ចីទៅកាន់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច ជៀសវាងងការផ្តល់កម្ចីទៅកាន់ ឥណទានដែលមានទំហំធំៗ ។
- ក្រុមប្រឹក្សាភិបាលធ្វើការពិចារណាដ៏សមស្រប ក្នុងការប្រៀបធៀបពីហានិភ័យ និងចំណូលដែលទទួលបានពីការផ្តល់ឥណទានកាន់ចំណែកទីផ្សារតូចៗនេះ ហើយក៏បានពិចារណាថាឥណទានខ្នាតតូចបំផុត និងខ្នាតតូច ជាផលិតផលស្នូលរបស់ធនាគារផងដែរ ។
- ក្រុមប្រឹក្សាភិបាលធ្វើការពិចារណាថា អ្នកគ្រប់គ្រងមានសិទ្ធិគ្រប់គ្រាន់ក្នុងការកែតម្រូវ ផ្លាស់ប្តូរតាមស្ថានភាពជាក់ស្តែង ឬអភិវឌ្ឍផលិតផលដែលមានស្រាប់ ហើយនឹងខ្សែសង្វាក់ផលិតផល ប៉ុន្តែតម្រូវឲ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។
- ការទទួលខុសត្រូវប្រចាំថ្ងៃសម្រាប់ហានិភ័យឥណទាន គឺជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់នៃនាយកដ្ឋានឥណទាន ជាមួយអ្នកគ្រប់គ្រងសាខា និងជាមួយភ្នាក់ងារឥណទានសាខា ។
- ហានិភ័យឥណទានគឺត្រូវបានវាស់វែងជាប្រចាំ ដោយគណនាការខាតបង់ដែលបានរំពឹងទុក ដែលអាចកើតមានឡើងចំពោះអតិថិជនដែលខកខានសងត្រឡប់ ហានិភ័យក្នុងព្រឹត្តិការណ៍នៃការខកខានសង និងភាពខ្លាំង នៃការខាតបង់ដែលបានមកពីការខកខានសងរបស់អតិថិជនដោយផ្អែកទៅលើពិន្ទុឥណទានសម្រាប់ការអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលយល់ឃើញថាហានិភ័យឥណទានគឺអាចរីករាលដាលដល់វិស័យផ្សេងៗទៀត ដូចជា (វិស័យពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ...) ហើយផលិតផលផ្សេងទៀត ដើម្បីជៀសវាងភាពមិនត្រឹមត្រូវទៅលើហានិភ័យ វិស័យ ឬឧស្សាហកម្មជាក់លាក់មួយ ។
- ហានិភ័យជាប្រព័ន្ធ គឺជាការខូចខាតប្រព័ន្ធទាំងមូលនៃវិស័យហិរញ្ញវត្ថុ ។ ក្រុមប្រឹក្សាភិបាលតម្រូវថា ហានិភ័យឥណទាន ទៅលើដៃគូភាគីស្ថាប័នហិរញ្ញវត្ថុទាំងឡាយ គួរតែជាកម្មវត្ថុនៃការវាយតម្លៃដ៏ប្រុងប្រយ័ត្ន និងត្រួតពិនិត្យ ដូចទៅនឹងទម្រង់នៃការផ្តល់កម្ចីឥណទានដទៃទៀត ហើយកម្រិតកំណត់ស្ថានភាពប្រុងប្រយ័ត្ន គួរតែត្រូវបានកំណត់ដើម្បីការពារធនាគារឲ្យបានគ្រប់គ្រាន់ សម្រាប់ហានិភ័យជាប្រព័ន្ធ ។

### *កម្រិតកំណត់ស្ថានភាពនៃហានិភ័យឥណទាន*

កម្រិតកំណត់ស្ថានភាពលើផលិតផលឥណទាន គួរតែបង្កើតឡើងដោយគណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល និងមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ។ កម្រិតកំណត់ស្ថានភាពគួរតែស្របទៅតាមកម្រិត

ហានិភ័យទទួលយក និងត្រូវបានគេកត់ត្រានៅក្នុងគោលការណ៍ឥណទានរបស់ធនាគារ ។

នាយកដ្ឋានគ្រប់គ្រងហានិភ័យត្រូវត្រួតពិនិត្យជាប្រចាំ ទៅលើរាល់កម្រិតកំណត់ស្ថានភាពដូចដែលបានកំណត់ ហើយអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់អនុសាសន៍ទៅលើការផ្លាស់ប្តូរផ្សេងៗដែលចាត់ទុកថាសមរម្យ ។

- ទំហំហានិភ័យបើកចំហ (Open Exposure)៖ ទំហំហានិភ័យបើកចំហត្រូវបានកំណត់ដូចជាសម្គាល់ឥណទាន ដែលមានហានិភ័យសរុប ចែកជាមួយ មូលនិធិទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ តែត្រូវតិចជាង ២៥% ។ ក្នុងករណីដែលកម្រិតថេរនេះ (២៥%) ត្រូវបានគេរំពឹងថាហួសកម្រិតកំណត់ គណៈគ្រប់គ្រងត្រូវជូនដំណឹងភ្លាមទៅ គណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល ដើម្បីចាត់វិធានការឲ្យបានសមស្រប និងទាន់ពេលវេលា ។
- កម្រិតកំណត់ការផ្តល់ឥណទាន (Ceilings) ទៅកាន់វិស័យផ្សេងៗ និងដោយផលិតផលត្រូវដាក់ដែនកំណត់ទៅលើហានិភ័យប្រមូលផ្តុំ ។
- ទំហំហានិភ័យធំបំផុត (Maximum Exposure) សម្រាប់អតិថិជនម្នាក់ ឬក្រុមនៃអតិថិជន គឺអាចមានទំហំរហូតដល់ ៥% នៃមូលនិធិទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ ។
- ដៃគូភាគីស្ថាប័នហិរញ្ញវត្ថុនានា ។

## (ក) ការគ្រប់គ្រងកម្រិតហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាលបានបែងចែកការទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យទៅលើហានិភ័យឥណទាន ទៅគណៈកម្មាធិការឥណទាន ។ នាយកដ្ឋានឥណទានដាច់ដោយឡែកមួយ ដែលទទួលខុសត្រូវគ្រប់គ្រងហានិភ័យឥណទាន ត្រូវរាយការណ៍ទៅគណៈកម្មាធិការឥណទាន ដូចដែលមានចែងខាងក្រោម ៖

- ការបែងចែកតួនាទីដាច់ដោយឡែករវាងអ្នកដែលពាក់ព័ន្ធ ក្នុងការប្រាស្រ័យជាមួយអតិថិជន ដែលដាក់ពាក្យសុំខ្ចីឥណទាន និងអ្នកដែលពាក់ព័ន្ធក្នុងការអនុម័តឥណទាន ។
- ការបែងចែកតួនាទីដាច់ដោយឡែក រវាងអ្នកដែលពាក់ព័ន្ធក្នុងការប្រាស្រ័យជាមួយអតិថិជន ដោយផ្ទាល់ និងអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងឥណទាន ។
- គោលការណ៍នៃការអនុម័តពីរលំដាប់ថ្នាក់ ដើម្បីធានាឲ្យមានតុល្យភាពនៃផលប្រយោជន៍របស់អតិថិជន និងគោលដៅនៃដំណើរការវាយតម្លៃហានិភ័យ ។
- ការរៀបចំឯកសារព្រមព្រៀងឲ្យទាន់ពេលវេលា និងពេញលេញជាមួយអតិថិជន រួមជាមួយព័ត៌មានដែលត្រូវការទាំងអស់ ដែលទាក់ទងនឹងការវាយតម្លៃ និងដំណើរការគ្រប់គ្រងឥណទាន ។
- ប្រព័ន្ធត្រួតពិនិត្យឥណទានត្រូវមានការប្រយ័ត្នប្រយែង គួបផ្សំនឹងការពិនិត្យសមាយិកភាពដែលអាចកំណត់សម្គាល់សញ្ញាណទាន់ពេលស្តីពីព័ត៌មាននៃការគ្រប់គ្រងហានិភ័យ ។
- ការត្រួតពិនិត្យដោយឯករាជ្យ ដើម្បីធានាឲ្យមាននូវអនុលោមភាពទៅតាមនីតិវិធី និងនិយ័តកម្ម ក្នុងដំណើរការឥណទាន និងការតាមដានគុណភាពទាក់ទងនឹងហានិភ័យ និងការត្រួតពិនិត្យឥណទានឲ្យបានទាន់ពេលវេលា ។
- ធនាគារនឹងរក្សាឲ្យបានល្អនូវសមតុល្យឥណទានតាមវិស័យផ្សេងៗ ដូចជាវិស័យឧស្សាហកម្ម តំបន់ភូមិសាស្ត្រ រូបិយប័ណ្ណ និងទំហំឥណទាន ។
- ការវិភាគឥណទានធ្វើឡើងដោយផ្តោតសំខាន់លើសមត្ថភាព និងឆន្ទៈរបស់អតិថិជនក្នុងការសងឥណទាន តាមរយៈការវាយតម្លៃពីអត្តចរិតលំហូរសាច់ប្រាក់ និងការអនុវត្តតាម green-lining methodology ។
- សំពៀតឥណទានសរុបរបស់ធនាគារ ដែលផ្តល់ឲ្យអតិថិជនម្នាក់ ឬអតិថិជនក្រុម (គោលការណ៍អ្នកខ្ចីតែមួយ) មិនត្រូវលើស ៥% នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ ។ "សំពៀតឥណទាន" (Exposure) គឺរួមមានបរិមាណសរុបនៃ (i) ចំនួនទឹកប្រាក់នៃទ្រព្យរបស់អ្នកខ្ចី ដែលអ្នកខ្ចីនោះជាកូនបំណុល (ii) ប្រាក់ដែលអ្នកខ្ចីជំពាក់ (ឥណទេយ្យ) តាមរយៈការផ្តល់ហិរញ្ញប្បទាន ឬឥណទានទៅឲ្យ ឬជំនួសឲ្យ បុគ្គលនោះ ដែលរួមមានដូចជា ការធានាបំណុល លិខិតឥណទាន និស្សន្ទវត្ថុ (derivatives) ។

## (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

សម្ព័ន្ធធនាគារ និងធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាននិងបុរេប្រទានជូនអតិថិជនជាឯកត្តជន ឬសហគ្រាសនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។ សម្ព័ន្ធធនាគារ និងធនាគារគ្រប់គ្រងកម្រិតហានិភ័យ និងផ្តោតការយកចិត្តទុកដាក់លើហានិភ័យឥណទាន នៅពេលដែលហានិភ័យត្រូវបានរកឃើញ ។ ហានិភ័យឥណទានធំត្រូវបានកំណត់និយមន័យថា ជាហានិភ័យឥណទានទូទៅជាមួយនឹងអត្តតាហកឯកត្តជននីមួយៗ ដែលមានចំនួនលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធ ។

យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារកណ្តាល តម្រូវឲ្យធនាគាររក្សាឲ្យបានគ្រប់ពេលវេលានូវអនុបាតអតិបរមាចំនួន ២០% រវាងហានិភ័យសរុបដែលចេញពីប្រតិបត្តិការជាមួយនឹងអត្តតាហកជាឯកត្តជននីមួយៗ និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ហើយត្រូវរក្សាហានិភ័យឥណទានធំៗសរុប មិនត្រូវឲ្យលើស ៣០០% នៃមូលនិធិផ្ទាល់សុទ្ធឡើយ ។

សម្ព័ន្ធធនាគារបានប្រើប្រាស់គោលការណ៍និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន ។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំលើឥណទាននិងបុរេប្រទានអតិថិជន ដែលជាការអនុវត្តទូទៅ ។ សម្ព័ន្ធធនាគារអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកនូវចំណាត់ថ្នាក់ជាក់លាក់ នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន ។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗដើម្បីធានាឥណទាននិងបុរេប្រទានអតិថិជនមានដូចជា ៖

- វត្ថុបញ្ចាំជាទ្រព្យសម្បត្តិក្នុងលក្ខណៈជាលំនៅដ្ឋាន (មានដីធ្លី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)
- កម្រៃផ្សេងៗលើទ្រព្យសកម្មក្នុងអាជីវកម្ម ដូចជាដីធ្លី អគារ
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានកម្រិត ។

## (គ) គោលការណ៍សំវិធានធននិងការថយចុះតម្លៃ

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាថយចុះតម្លៃ ប្រសិនបើមានភស្តុតាងច្បាស់លាស់ណាមួយ បញ្ជាក់អំពីការថយចុះតម្លៃនោះ ហើយជាលទ្ធផលបណ្តាលមកពីព្រឹត្តិការណ៍មួយ ឬច្រើនដែលកើតមានឡើងបន្ទាប់ពីការទទួលស្គាល់លើកដំបូង នៃទ្រព្យសកម្មនោះ (ការកើតមានឡើងនូវការខាតបង់) ហើយការខាតបង់នោះ (ឬការខាតបង់ដទៃទៀតនោះ) ធ្វើឲ្យប៉ះពាល់ដល់ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាជាការប៉ាន់ស្មានគួរឲ្យជឿជាក់បាន ។

## (ឃ) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានដូចជាហានិភ័យឥណទានគឺ ស្មើនឹងតម្លៃយោងសុទ្ធឯលិខិតធានាហិរញ្ញវត្ថុ និងកិច្ចសន្យាទទួល គឺជាទំហំអតិបរមាដែលសម្ព័ន្ធធនាគារនិងធនាគារ នឹងទូទាត់ ប្រសិនបើលិខិតធានាទាំងនោះត្រូវបានហៅត្រលប់មកវិញ ។ ចំណែកឯឥណទានដែលទាក់ទងនឹងកិច្ចសន្យា និងយថាភាព ដែលមិន អាចបដិសេធបានពេញអាយុកាលនៃកិច្ចសន្យានោះ ជាទូទៅគឺស្មើនឹងតម្លៃទាំងស្រុងដែលមានក្នុងកិច្ចសន្យា ។

### (iii) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហានិភ័យឥណទានទាក់ទិននឹងទ្រព្យសកម្មក្នុងតារាងតុល្យការ ៖ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ ( * ) | ៩៨.៧២៦.៨៧៧ | ៣៩៨.៥៦០.៤០២ | ១២៤.២៨១.៧២៥ | ៥០៣.៣៤០.៩៨៨ | ៨២.០៧៤.១៩៧ | ៣៣១.៣៣៣.៥៣៣ | ១០៦.៨១៥.០៤៨ | ៤៣២.៦០០.៩៤៤ |
| ឥណទាននិងបុរេប្រទានអតិថិជន ( ** ) | ២.៩០៣.៩៨៨.៥០៥ | ១១.៧២៣.៤០១.៥៩៥ | ២.៥៦០.៥០៤.៩៩៧ | ១០.៣៧០.០៤៥.២៣៨ | ២.៧៧១.០៩៥.៩១៤ | ១១.១៨៦.៩១៤.២០៥ | ២.៤៥៣.៩១៩.៥៨៦ | ៩.៩៣៨.៣៧៤.៣២៤ |
| ទ្រព្យសកម្មផ្សេងៗ | ៣៤.៥៦៧.៨៩២ | ១៣៩.៥៥០.៥៨០ | ២៥.០៥២.៤៨៣ | ១០១.៤៦២.៥៥៦ | ៣៣.៤៨៣.៦១០ | ១៣៥.១៧៣.៣៣៤ | ២៤.៣៣២.០៣៥ | ៩៨.៥៤៤.៧៤២ |
| | ៣.០៣៧.២៨៣.២៧៤ | ១២.២៦១.៥១២.៥៧៧ | ២.៧០៩.៨៣៩.២០៥ | ១០.៩៧៤.៨៤៨.៧៨២ | ២.៨៨៦.៦៥៣.៧២១ | ១១.៦៥៣.៤២១.០៧២ | ២.៥៨៥.០៦៦.៦៦៩ | ១០.៤៦៩.៥២០.០១០ |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ៩៦.៣៦៥.៥៤០ | ៣៨៩.០២៧.៦៨៥ | ៨៣.៨៤៧.០៩០ | ៣៣៩.៥៨០.៧១៥ | ៩៦.៣៦៥.៥៤០ | ៣៨៩.០២៧.៦៨៥ | ៨៣.៨៤៧.០៩០ | ៣៣៩.៥៨០.៧១៥ |
| លិខិតធានារបស់ធនាគារ | ៤២.៣៤៨.៣៩៤ | ១៧០.៩៦០.៤៦៧ | ៣៤.២២៨.០៦៦ | ១៣៨.៦២៣.៦៦៧ | ៤២.៣៣៤.៣៣៥ | ១៧០.៩០៣.៧១០ | ៣៤.២២៣.២៦៣ | ១៣៨.៦០៤.២១៥ |
| លិខិតឥណទាន | ១៥.៨៥៥.៤០១ | ៦៤.០០៨.២៥៤ | ១៨.០៨៥.០៤០ | ៧៣.២៤៤.៤១២ | ១៥.៨៥៥.៤០១ | ៦៤.០០៨.២៥៤ | ១៨.០៨៥.០៤០ | ៧៣.២៤៤.៤១២ |
| | ១៥៤.៥៦៩.៣៣៥ | ៦២៣.៩៩៦.៤០៦ | ១៣៦.១៦០.១៩៦ | ៥៥១.៤៤៨.៧៩៤ | ១៥៤.៥៥៥.២៧៦ | ៦២៣.៩៣៩.៦៤៩ | ១៣៦.១៥៥.៣៩៣ | ៥៥១.៤២៩.៣៤២ |
| ហានិភ័យឥណទានអតិបរមាសរុប | ៣.១៩១.៨៥២.៦០៩ | ១២.៨៨៥.៥០៨.៩៨៣ | ២.៨៤៥.៩៩៩.៤០១ | ១១.៥២៦.២៩៧.៥៧៦ | ៣.០៤១.២០៨.៩៩៧ | ១២.២៧៧.៣៦០.៧២១ | ២.៧២១.២២២.០៦២ | ១១.០២០.៩៤៩.៣៥២ |

## (ឃ) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន

តារាងខាងលើនេះបង្ហាញពីស្ថានភាពអាក្រក់បំផុតនៃហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដោយមិនគិតដល់វត្ថុបញ្ចាំឬការបង្កើនឥណទានផ្សេងទៀតទេ ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យដែលបានបង្ហាញខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ ។

ដូចបានបង្ហាញខាងលើ ៩០,៩៨% នៃហានិភ័យអតិបរមាសរុបចំពោះសម្ព័ន្ធធនាគារ និង ៩១,១២% នៃហានិភ័យអតិបរមាសរុបចំពោះធនាគារ គឺកើតមកពីឥណទាននិងបុរេប្រទានអតិថិជន (២០១៥៖ ៨៩,៩៧% ចំពោះសម្ព័ន្ធធនាគារ និង ៩០,១៨% ចំពោះធនាគារ) ។

គណៈគ្រប់គ្រងមានជំនឿថា ខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រងនិងទ្រទ្រង់ហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ ដែលបណ្តាលមកពីឥណទាននិងបុរេប្រទាន ឲ្យស្ថិតក្នុងកម្រិតអប្បបរមាតាមវិធីដូចខាងក្រោម ៖

ប្រមាណ ៩៨,០៤% នៃឥណទាននិងបុរេប្រទានរបស់ធនាគារ ត្រូវបានធានាដោយវត្ថុបញ្ចាំ ។ ឥណទាននិងបុរេប្រទានដែលធនាគារបានផ្តល់ជូនអតិថិជន គឺមានតម្លៃប្រហែល ៧០% ទៅ ៨០% នៃតម្លៃវត្ថុបញ្ចាំ ។

## (ង) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងហានិភ័យឥណទាន

### (i) វិភាគតាមទីតាំងភូមិសាស្ត្រ

តារាងខាងក្រោមនេះលម្អិតអំពីហានិភ័យឥណទានសំខាន់ៗរបស់សម្ព័ន្ធធនាគារនិងធនាគារ តាមតម្លៃយោងរបស់វា ដោយចាត់ថ្នាក់តាមភូមិសាស្ត្រ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ។ ក្នុងតារាងនេះសម្ព័ន្ធធនាគារនិងធនាគារបានបែងចែកហានិភ័យទៅតាមប្រទេសនីមួយៗ ដោយផ្អែកតាមប្រទេសជាភាគីដៃគូ ។

| | សម្ព័ន្ធធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា | បារាំង | អាឡឺម៉ង់ | ឡាវ | សឹង្ហបុរី | សហរដ្ឋអាមេរិក | មីយ៉ាន់ម៉ា | ប្រទេសផ្សេងៗ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ ( * ) | ២.៤៣៩.៥៣៨ | ១.២២៣.២៥៣ | ១២៩.៧០៨ | ១៣.៩៤៩.៩៥០ | ៧៤៨.៩៦៩ | ៧៤.១៧៩.៥០៦ | ២២០.៦០១ | ៥.៨៣៥.៣៥២ | ៩៨.៧២៦.៨៧៧ |
| ឥណទាននិងបុរេប្រទានអតិថិជន ( ** ) | ២.៧៧១.០៩៥.៩១៤ | - | - | ១១៩.៣៩៣.៤៣៦ | - | - | ១៣.៤៩៩.១៥៥ | - | ២.៩០៣.៩៨៨.៥០៥ |
| ទ្រព្យសកម្មផ្សេងៗ | ៣៣.៤៩៦.៣៦៧ | - | - | ៩៥០.៤៦១ | - | - | ១២១.០៦៤ | - | ៣៤.៥៦៧.៨៩២ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ២.៨០៧.០៣១.៨១៩ | ១.២២៣.២៥៣ | ១២៩.៧០៨ | ១៣៤.២៩៣.៨៤៧ | ៧៤៨.៩៦៩ | ៧៤.១៧៩.៥០៦ | ១៣.៨៤០.៨២០ | ៥.៨៣៥.៣៥២ | ៣.០៣៧.២៨៣.២៧៤ |
| សមមូលនឹងពាន់រៀល | ១១.៣៣១.៩៨៧.៤៥៣ | ៤.៩៣៨.២៧២ | ៥២៣.៦៣១ | ៥៤២.១៤៤.២៦០ | ៣.០២៣.៥៨៨ | ២៩៩.៤៦២.៦៦៦ | ៥៥.៨៧៥.៣៩០ | ២៣.៥៥៧.៣១៧ | ១២.២៦១.៥១២.៥៧៧ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ ( * ) | ៣.២៣៨.៩៦៩ | ៣០៩.៩៦០ | ២៦២.៦៤៨ | ១៦.៦១១.៧៤៩ | ៨៤៩.៧៣៧ | ៩៣.៦១៨.៩៨៨ | ១.៣១៣ | ៩.៣៨៨.៣៦១ | ១២៤.២៨១.៧២៥ |
| ឥណទាននិងបុរេប្រទានអតិថិជន ( ** ) | ២.៤៥៣.៩១៩.៥៨៦ | - | - | ៩៨.៧១៩.៨៣៩ | - | - | ៧.៨៦៥.៥៧២ | - | ២.៥៦០.៥០៤.៩៩៧ |
| ទ្រព្យសកម្មផ្សេងៗ | ២៤.០៨០.៩០១ | - | - | ៨៤២.០០៣ | - | - | ១២៨.៩០៨ | ៦៧១ | ២៥.០៥២.៤៨៣ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ២.៤៨១.២៣៩.៤៥៦ | ៣០៩.៩៦០ | ២៦២.៦៤៨ | ១១៦.១៧៣.៥៩១ | ៨៤៩.៧៣៧ | ៩៣.៦១៨.៩៨៨ | ៧.៩៩៥.៧៩៣ | ៩.៣៨៩.០៣២ | ២.៧០៩.៨៣៩.២០៥ |
| សមមូលនឹងពាន់រៀល | ១០.០៤៩.០១៩.៧៩៨ | ១.២៥៥.៣៣៨ | ១.០៦៣.៧២៤ | ៤៧០.៥០៣.០៤៤ | ៣.៤៤១.៤៣៥ | ៣៧៩.១៥៦.៩០១ | ៣២.៣៨២.៩៦២ | ៣៨.០២៥.៥៨០ | ១០.៩៧៤.៨៤៨.៧៨២ |

( * ) សមតុល្យនៅធនាគារផ្សេងៗ មិនរួមបញ្ចូលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ចនៅធនាគារជាតិឡាវ ។

( ** ) សមតុល្យឥណទាននិងបុរេប្រទានអតិថិជន មិនរាប់បញ្ចូលសំវិធានធនឥណទានបាត់បង់ ។

| | ធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា | បារាំង | អាឡឺម៉ង់ | ឡាវ | សិង្ហបុរី | សហរដ្ឋអាមេរិក | មីយ៉ាន់ម៉ា | ប្រទេសផ្សេងៗ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ១.៨០៨.៩៥៣ | ១.២២៣.២៥៣ | ១២៩.៧០៨ | - | ៧៤៨.៩៦៩ | ៧៤.១៧៩.៥០៦ | ៤៨.៥៨៣ | ៣.៩៣៥.២២៥ | ៨២.០៧៤.១៩៧ |
| ឥណទាននិងបុរេប្រទានអតិថិជន ( * ) | ២.៧៧១.០៩៥.៩១៤ | - | - | - | - | - | - | - | ២.៧៧១.០៩៥.៩១៤ |
| ទ្រព្យសកម្មផ្សេងៗ | ៣៣.៤៨៣.៦១០ | - | - | - | - | - | - | - | ៣៣.៤៨៣.៦១០ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ២.៨០៦.៣៨៨.៤៧៧ | ១.២២៣.២៥៣ | ១២៩.៧០៨ | - | ៧៤៨.៩៦៩ | ៧៤.១៧៩.៥០៦ | ៤៨.៥៨៣ | ៣.៩៣៥.២២៥ | ២.៨៨៦.៦៥៣.៧២១ |
| សមមូលនឹងពាន់រៀល | ១១.៣២៩.៣៩០.២៨២ | ៤.៩៣៨.២៧២ | ៥២៣.៦៣១ | - | ៣.០២៣.៥៨៨ | ២៩៩.៤៦២.៦៦៦ | ១៩៦.១៣០ | ១៥.៨៨៦.៥០៣ | ១១.៦៥៣.៤២១.០៧២ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ៣.២៣៨.៧០២ | ៣០៩.៩៦០ | ២៦២.៦៤៨ | - | ៨៤៩.៧៣៧ | ៩៣.៦១៨.៩៨៨ | - | ៨.៥៣៥.០១៣ | ១០៦.៨១៥.០៤៨ |
| ឥណទាននិងបុរេប្រទានអតិថិជន ( * ) | ២.៤៥៣.៩១៩.៥៨៦ | - | - | - | - | - | - | - | ២.៤៥៣.៩១៩.៥៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ២៤.១៧០.២៥១ | - | - | ១៧.០៤៧ | - | - | ១៤៤.៧៣៧ | - | ២៤.៣៣២.០៣៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ២.៤៨១.៣២៨.៥៣៩ | ៣០៩.៩៦០ | ២៦២.៦៤៨ | ១៧.០៤៧ | ៨៤៩.៧៣៧ | ៩៣.៦១៨.៩៨៨ | ១៤៤.៧៣៧ | ៨.៥៣៥.០១៣ | ២.៥៨៥.០៦៦.៦៦៩ |
| សមមូលនឹងពាន់រៀល | ១០.០៤៩.៣៨០.៥៨៤ | ១.២៥៥.៣៣៨ | ១.០៦៣.៧២៤ | ៦៩.០៤០ | ៣.៤៤១.៤៣៥ | ៣៧៩.១៥៦.៩០១ | ៥៨៦.១៨៥ | ៣៤.៥៦៦.៨០៣ | ១០.៤៦៩.៥២០.០១០ |

( * ) សមតុល្យឥណទាននិងបុរេប្រទានអតិថិជន មិនរាប់បញ្ចូលសំវិធានធនឥណទានបាត់បង់ ។

## (ii) វិភាគតាមប្រភេទអាជីវកម្ម

តារាងខាងក្រោមនេះលម្អិតអំពីហានិភ័យឥណទានសំខាន់ៗតាមតម្លៃយោងរបស់វា ដោយចាត់ថ្នាក់តាមប្រភេទអាជីវកម្មនៃភាគីដៃគូ ។

| | សម្ព័ន្ធធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ្រឹះស្ថានហិរញ្ញវត្ថុ | ការលក់ដុំ និងលក់រាយ | សេវាកម្ម | គេហដ្ឋាន | ផលិតកម្ម | កសិកម្ម | អាជីវកម្មផ្សេងៗ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015** | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ ( * ) | 124,281,725 | - | - | - | - | - | - | 124,281,725 |
| ឥណទាននិងបុរេប្រទាន ( ** ) | 4,577,531 | 997,134,575 | 506,262,742 | 177,961,906 | 111,968,191 | 523,181,508 | 77,816,441 | 2,560,504,997 |
| ទ្រព្យសកម្មផ្សេងៗ | 2,225,260 | 8,160,097 | 4,241,026 | 1,213,424 | 800,713 | 5,794,043 | 187,476 | 25,693,877 |
| | 131,084,516 | 1,005,294,672 | 510,503,768 | 179,175,330 | 112,768,904 | 528,975,551 | 78,003,917 | 2,710,480,599 |
| ពាន់រៀល ( កំណត់សម្គាល់4 ) | 530,892,290 | 4,071,443,422 | 2,067,540,260 | 725,660,087 | 456,714,061 | 2,142,350,982 | 315,915,864 | 10,977,446,428 |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2014** | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ ( * ) | 129,373,671 | - | - | - | - | - | - | 129,373,671 |
| ឥណទាននិងបុរេប្រទាន ( ** ) | 6,047,975 | 833,705,571 | 423,840,646 | 134,923,783 | 95,209,222 | 398,003,634 | 66,507,924 | 2,086,297,586 |
| ទ្រព្យសកម្មផ្សេងៗ | 1,872,071 | 6,923,638 | 3,670,323 | 989,000 | 698,186 | 4,529,820 | 143,321 | 21,285,978 |
| ការវិនិយោគផ្សេងៗ | 200,000 | - | - | - | - | - | - | 200,000 |
| | 137,493,717 | 840,629,209 | 427,510,969 | 135,912,783 | 95,907,408 | 402,533,454 | 66,651,245 | 2,237,157,235 |
| ពាន់រៀល ( កំណត់សម្គាល់4 ) | 560,286,897 | 3,425,564,027 | 1,742,107,199 | 553,844,591 | 390,822,688 | 1,640,323,825 | 271,603,823 | 9,116,415,734 |

( * ) សមតុល្យនៅធនាគារផ្សេងៗ មិនរួមបញ្ចូលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ចនៅធនាគារជាតិឡាវ ។
( * * ) សមតុល្យឥណទាននិងបុរេប្រទានអតិថិជន មិនរាប់បញ្ចូលសំវិធានធនឥណទានបាត់បង់ ។

| | ធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ្រឹះស្ថានហិរញ្ញវត្ថុ | ការលក់ដុំ និងលក់រាយ | សេវាកម្ម | គេហដ្ឋាន | ផលិតកម្ម | កសិកម្ម | អាជីវកម្មផ្សេងៗ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ៨២.០៧៤.១៩៧ | - | - | - | - | - | - | ៨២.០៧៤.១៩៧ |
| ឥណទាននិងបុរេប្រទានអតិថិជន ( * ) | ៣.១១០.០០០ | ១.០៩១.៦១៤.៣០៩ | ៥៩៣.៣២៩.០៣៣ | ២១១.៣៦៩.៦២៩ | ១០៣.៨៤៣.៥៤៣ | ៥៤៩.៥៣២.៦៤០ | ២១៨.២៩៦.៧៥០ | ២.៧៧១.០៩៥.៩១៤ |
| ទ្រព្យសកម្មផ្សេងៗ | ៨.០១៦.៣២៥ | ៨.៥៧៤.៦៣៣ | ៤.៦១២.៩៧១ | ១.៤០៩.០៧០ | ៦១៤.៥៣៧ | ៥.៨៥៩.៩៦៥ | ៤.៣៩៦.១០៩ | ៣៣.៤៨៣.៦១០ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៩៣.២០០.៥២២ | ១.១០០.១៨៨.៩៤២ | ៥៩៧.៩៤២.០០៤ | ២១២.៧៧៨.៦៩៩ | ១០៤.៤៥៨.០៨០ | ៥៥៥.៣៩២.៦០៥ | ២២២.៦៩២.៨៥៩ | ២.៨៨៦.៦៥៣.៧២១ |
| សមមូលនឹងពាន់រៀល | ៣៧៦.២៥០.៥០៧ | ៤.៤៤១.៤៦២.៧៥៩ | ២.៤១៣.៨៩១.៨៧០ | ៨៥៨.៩៨៧.៦០៨ | ៤២១.៦៩៧.៣០៩ | ២.២៤២.១១៩.៩៤៦ | ៨៩៩.០១១.០៧៣ | ១១.៦៥៣.៤២១.០៧២ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ១០៦.៨១៥.០៤៨ | - | - | - | - | - | - | ១០៦.៨១៥.០៤៨ |
| ឥណទាននិងបុរេប្រទានអតិថិជន ( * ) | ៤.៥៧៧.៥៣១ | ៩៩២.៤៧០.៣៣៦ | ៤៨០.៦០៤.៦៩២ | ១៧៧.៨៦៧.១៥៨ | ១០៦.១០១.១៨៤ | ៥១០.៦៩៤.១១៣ | ១៨១.៦០៤.៥៧២ | ២.៤៥៣.៩១៩.៥៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ២.២១០.៧១៩ | ៨.០៨៥.០៥០ | ៣.៩៨៨.៣២៧ | ១.២១២.៥៣៤ | ៧៤៣.២១៣ | ៥.៦៦៨.១៤៧ | ២.៤២៤.០៤៥ | ២៤.៣៣២.០៣៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ១១៣.៦០៣.២៩៨ | ១.០០០.៥៥៥.៣៨៦ | ៤៨៤.៥៩៣.០១៩ | ១៧៩.០៧៩.៦៩២ | ១០៦.៨៤៤.៣៩៧ | ៥១៦.៣៦២.២៦០ | ១៨៤.០២៨.៦១៧ | ២.៥៨៥.០៦៦.៦៦៩ |
| សមមូលនឹងពាន់រៀល | ៤៦០.០៩៣.៣៥៧ | ៤.០៥២.២៤៩.៣១៣ | ១.៩៦២.៦០១.៧២៧ | ៧២៥.២៧២.៧៥៣ | ៤៣២.៧១៩.៨០៨ | ២.០៩១.២៦៧.១៥៣ | ៧៤៥.៣១៥.៨៩៩ | ១០.៤៦៩.៥២០.០១០ |

( * ) សមតុល្យឥណទាននិងបុរេប្រទានអតិថិជន មិនរាប់បញ្ចូលសំវិធានធនឥណទានបាត់បង់ ។

## ( ច ) ឥណទាននិងបុរេប្រទានដែលបានរៀបចំឡើងវិញ

សកម្មភាពក្នុងការរៀបចំឥណទានឡើងវិញរួមមានការរៀបចំក្នុងការពន្យារពេលសងប្រាក់ ការកែប្រែ និងការផ្អាកការសងប្រាក់ជាដើម ។ យោងតាមការរៀបចំឡើងវិញនេះ ឥណទានត្រូវបានរក្សាទុកក្នុងចំណាត់ថ្នាក់ដដែល លុះត្រាតែមានភស្តុតាងជាក់ស្តែងបញ្ជាក់ពីភាពប្រសើរឡើងនៃលក្ខខណ្ឌហិរញ្ញវត្ថុរបស់អតិថិជន ។

ក្នុងអំឡុងការិយបរិច្ឆេទនេះ សម្ព័ន្ធធនាគារ និងធនាគារបានរៀបចំឥណទាននិងបុរេប្រទានឡើងវិញ ដែលមានទឹកប្រាក់ចំនួន ៣៩៧.៤៨៦ដុល្លារអាមេរិក ក្នុងនោះទឹកប្រាក់ចំនួន ២៩៧.៤៨៦ដុល្លារអាមេរិក ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានឃ្លាំមើល និងទឹកប្រាក់ចំនួន ១០០.០០០ដុល្លារអាមេរិកទៀត ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានធម្មតា (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សម្ព័ន្ធធនាគារបានរៀបចំឥណទាននិងបុរេប្រទានឡើងវិញ ដែលមានទឹកប្រាក់ចំនួន ៦៨៨.១៣១ដុល្លារអាមេរិក ដែលក្នុងនោះទឹកប្រាក់ចំនួន ២៦៧.៥០៩ដុល្លារអាមេរិក ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានធម្មតា ហើយទឹកប្រាក់ចំនួន ៤២០.៦២២ដុល្លារអាមេរិកទៀត ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានមិនដំណើរការ) ។

## ( ឆ ) ការរឹបអូសវត្ថុបញ្ចាំ

ទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវលក់ចេញក្នុងរយៈពេលមួយឆ្នាំ តាមការកំណត់របស់ធនាគារកណ្តាល ។ ទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវបានចាត់ថ្នាក់ជា "ទ្រព្យសម្បត្តិរឹបអូស" ក្នុងតារាងតុល្យការ ប្រសិនបើមាន ។

ក្នុងអំឡុងការិយបរិច្ឆេទពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ សម្ព័ន្ធធនាគារមិនបានរឹបអូសទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំទេ (ឆ្នាំ២០១៥៖គ្មាន) ។

(ជ) គុណភាពឥណទាននៃឥណទាន និងបុរេប្រទាន

គិតត្រឹមកាលបរិច្ឆេទនៃតារាងតុល្យការ ហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារនិងធនាគារ ដែលកើតពីឥណទាននិងបុរេប្រទានអតិថិជន (ដោយមិនគិតវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងៗ និងមិនគិតដល់សំវិធានធនឥណទានបាត់បង់) មានដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន៖ | ២.៨៣៤.៦៩៧.៥៨៦ | ១១.៦០៥.១៥៤.១៥៥ | ២.៥៤៦.២៦៤.១៤១ | ១០.៣១២.៣៦៩.៧៧១ | ២.៧៤៣.៨៣៨.៤៧៥ | ១១.០៧៦.៨៣៥.៩២៤ | ២.៤៤២.៤១៩.៨៨៦ | ៩.៨៩១.៨០០.៥៣៨ |
| មិនហួសកាលកំណត់និងមិនថយចុះតម្លៃ | ៩.៥៨០.៩៨៥ | ៣៨.៦៧៨.៤៣៦ | ៤.២០៥.២៨០ | ១៧.០៣១.៤២៥ | ៨.៥១៦.២៥០ | ៣៤.៣៨០.១០១ | ២.៨៦៦.៧០០ | ១១.៦១០.១៣៥ |
| ហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃ | ១៩.៧០៩.៩៣៤ | ៧៩.៥៦៩.០០៤ | ១០.០៣៥.៥៦៦ | ៤០.៦៤៤.០៤២ | ១៨.៧៤១.១៨៩ | ៧៥.៦៥៨.១៨០ | ៨.៦៣៣.០០០ | ៣៤.៩៦៣.៦៥១ |
| ថយចុះតម្លៃ | ២.៩០៣.៩៨៨.៥០៥ | ១១.៧២៣.៤០១.៥៩៥ | ២.៥៦០.៥០៤.៩៨៧ | ១០.៣៧០.០៤៥.២៣៨ | ២.៧៧១.០៩៥.៩១៤ | ១១.១៨៦.៩១៤.២០៥ | ២.៤៥៣.៩១៩.៥៨៦ | ៩.៩៣៨.៣៧៤.៣២៤ |
| ឥណទាននិងបុរេប្រទានដុល | | | | | | | | |
| ដក៖ សំវិធានធនឥណទានបាត់បង់ | (៣៩.៥៤៣.០៣២) | (១៥៩.៦៣៥.២២០) | (៣១.៦៤២.៣៦១) | (១២៨.១៥១.៥៦២) | (៣៧.៨៤៣.៩៥១) | (១៥២.៧៧៦.០៣១) | (៣០.០៦៧.៨៥៨) | (១២១.៧៧៤.៨២៥) |
| កម្រៃពីដំណើរការឥណទាននៅសល់ | (២៣.០៥៤.៦៤៣) | (៩៣.០៧១.៥៩៤) | (២០.៩៧៥.៤៦៣) | (៨៤.៩៥០.៦២៥) | (១៩.៦១៦.៦២៤) | (៧៩.១៩២.៣១១) | (១៨.៣៨៧.០២៣) | (៧៤.៤៦៧.៤៤៤) |
| ឥណទាននិងបុរេប្រទានសុទ្ធ | ២.៨៤១.៣៩០.៨៣០ | ១១.៤៧០.៦៩៤.៧៨១ | ២.៥០៧.៨៨៧.១៧៣ | ១០.១៥៦.៩៤៣.០៥១ | ២.៧១៣.៦៣៥.៣៣៩ | ១០.៩៥៤.៩៤៥.៨៦៣ | ២.៤០៥.៤៦៤.៧០៥ | ៩.៧៤២.១៣២.០៥៥ |

*(i) ឥណទាននិងបុរេប្រទានដែលមិនហួសកាលកំណត់សងនិងមិនថយចុះតម្លៃ*

ឥណទាននិងបុរេប្រទានដែលមិនហួសកាលកំណត់សងមិនត្រូវបានចាត់ទុកថាថយចុះតម្លៃនោះទេ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ ។

*(ii) ឥណទាននិងបុរេប្រទានដែលហួសកាលកំណត់សងប៉ុន្តែមិនថយចុះតម្លៃ*

ឥណទាននិងបុរេប្រទានដែលហួសកាលកំណត់សងតិចជាង៩០ថ្ងៃ មិនត្រូវបានចាត់ទុកថាថយចុះតម្លៃនោះទេ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ ។ ចំនួនឥណទាននិងបុរេប្រទានអតិថិជនដុល ដែលបានហួសកាលកំណត់សងប៉ុន្តែមិនថយចុះតម្លៃត្រូវបានចាត់តាមថ្នាក់មានដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហួសកាលកំណត់ រហូតដល់២៩ថ្ងៃ | ៣.២០៨.២៨០ | ១២.៩៥១.៨២៦ | ២.១៨៥.៩៩៧ | ៨.៨៥៣.២៨៨ | ២.៦៨១.៦២១ | ១០.៨២៥.៧០៤ | ១.៣៤៥.៨៦៦ | ៥.៤៥០.៧៥៧ |
| ហួសកាលកំណត់ ៣០-៥៩ថ្ងៃ | ៤.១៣៧.២៨២ | ១៦.៧០២.២០៧ | ១.៣៣២.៨៦៧ | ៥.៣៩៨.១១២ | ៣.៨៣៩.៦៨២ | ១៥.៥០០.៧៨៦ | ៩៨២.៧០៣ | ៣.៩៧៩.៨៤៧ |
| ហួសកាលកំណត់ ៦០-៨៩ថ្ងៃ | ២.២៣៥.៤២៣ | ៩.០២៤.៤០៣ | ៦៨៦.៤២៦ | ២.៧៨០.០២៥ | ១.៩៩៤.៩៤៧ | ៨.០៥៣.៦០១ | ៥៣៨.១៣១ | ២.១៧៩.៤៣១ |
| | ៩.៥៨០.៩៨៥ | ៣៨.៦៧៨.៤៣៦ | ៤.២០៥.២៨០ | ១៧.០៣១.៤២៥ | ៨.៥១៦.២៥០ | ៣៤.៣៨០.១០១ | ២.៨៦៦.៧០០ | ១១.៦១០.១៣៥ |

*(iii) ឥណទាននិងបុរេប្រទានដែលថយចុះតម្លៃ*

អនុលោមតាមប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការធ្វើចំណាត់ថ្នាក់និងសំវិធានធនឥណទានបាត់បង់ រាល់ឥណទាន និងបុរេប្រទានដែលហួសកាលកំណត់សង៩០ថ្ងៃឬលើសពីនេះ ត្រូវបានចាត់ទុកថាថយចុះតម្លៃ ហើយកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់សម្រាប់ការថយចុះតម្លៃ ត្រូវបានកត់ត្រាអាស្រ័យទៅតាមចំណាត់ថ្នាក់ពាក់ព័ន្ធ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ ។

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | ២០១៦ | | ២០១៥ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហួសកាលកំណត់ ៩០-១៧៩ថ្ងៃ | ៤.៦៦៦.៨០៥ | ១៨.៨៣៩.៨៩២ | ២.៦២១.៨២៩ | ១០.៦១៨.៤០៨ | ៤.២៨២.៥០៣ | ១៧.២៨៨.៤៦៥ | ១.៩៩២.៨៨៥ | ៨.០៧១.១៨៥ |
| ហួសកាលកំណត់ ១៨០-៣៥៩ថ្ងៃ | ១០.៨០៧.៣៩៦ | ៤៣.៦២៩.៤៥៨ | ៣.៦៨១.៦៤៦ | ១៤.៩១០.៦៦៦ | ១០.២២២.៩៥៣ | ៤១.២៧០.០៦១ | ២.៩០៨.២៣៥ | ១១.៧៧៨.៣៥២ |
| ហួសកាលកំណត់ ៣៦០ឡើងទៅ | ៤.២៣៥.៧៣៣ | ១៧.០៩៩.៦៥៤ | ៣.៧៣២.០៩១ | ១៥.១១៤.៩៦៨ | ៤.២៣៥.៧៣៣ | ១៧.០៩៩.៦៥៤ | ៣.៧៣១.៨៨០ | ១៥.១១៤.១១៤ |
| | ១៩.៧០៩.៩៣៤ | ៧៩.៥៦៩.០០៤ | ១០.០៣៥.៥៦៦ | ៤០.៦៤៤.០៤២ | ១៨.៧៤១.១៨៩ | ៧៥.៦៥៨.១៨០ | ៨.៦៣៣.០០០ | ៣៤.៩៦៣.៦៥១ |

## ៣១.២ ហានិភ័យទីផ្សារ

សម្ព័ន្ធធនាគារនិងធនាគារធ្វើការដោះស្រាយបញ្ហាទៅលើភាពរងប៉ះពាល់លើហានិភ័យទីផ្សារដែលជាហានិភ័យនៃការផ្លាស់ប្តូរនៃកម្រិតឬភាពឡើងចុះនៃអត្រាទីផ្សារឬតម្លៃទីផ្សារមានដូចជាអត្រាការប្រាក់គម្លាតឥណទានអត្រាប្តូររូបិយប័ណ្ណបរទេស តម្លៃវត្ថុធាតុដើម និងតម្លៃទ្រព្យម្ចាស់ ដែលអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើចំណូលអនាគត ដើមទុន ឬសមត្ថភាពក្នុងការសម្រេចគោលដៅអាជីវកម្មរបស់សម្ព័ន្ធធនាគារនិងធនាគារ ។

ប្រភេទចម្បងនៃហានិភ័យទីផ្សាររបស់សម្ព័ន្ធធនាគារ និងធនាគារមានដូចជា ៖

(i) ហានិភ័យអត្រាការប្រាក់ ៖ អាចនាំមកនូវភាពខាតបង់ នៅពេលមានភាពអសមតុល្យរវាងទ្រព្យសកម្ម និងបំណុល ហើយអត្រាការប្រាក់លើទ្រព្យទាំងនោះផ្លាស់ប្តូរជាទៀងទាត់ ឬនៅចន្លោះពេលដែលខុសគ្នា ។

(ii) ហានិភ័យអត្រាប្តូររូបិយប័ណ្ណបរទេស ៖ អាចនាំមកនូវភាពខាតបង់ នៅពេលមានអសមតុល្យរវាងទ្រព្យសកម្ម និងបំណុល របស់រូបិយប័ណ្ណជាក់លាក់ណាមួយ ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (BRMC) ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលដើម្បីជួយក្រុមប្រឹក្សាភិបាលក្នុងការចាកចេញពីទំនួលខុសត្រូវលើការគ្រប់គ្រងហានិភ័យរបស់ខ្លួនឲ្យមានប្រសិទ្ធភាព និងត្រួតពិនិត្យជាទៀងទាត់លើសមត្ថភាពរបស់ អ្នកគ្រប់គ្រងក្នុងការវាយតម្លៃ និងគ្រប់គ្រងហានិភ័យរបស់ធនាគារ ។ ហានិភ័យទីផ្សារត្រូវបានគ្រប់គ្រងផ្អែកទៅលើគោលការណ៍ និងកម្រិតកំណត់ស្ថានភាពដូចខាងក្រោម ៖

*គោលការណ៍នៃហានិភ័យទីផ្សារ*

- ស្របទៅតាមគោលនយោបាយធនាគាររឹងមាំ សម្ព័ន្ធធនាគារនិងធនាគារនឹងគ្រប់គ្រងយ៉ាងសកម្មលើស្ថានភាពរូបិយប័ណ្ណ និងស្ថានភាពហានិភ័យអត្រាការប្រាក់ ក្នុងការទប់បង្ការស្ថានភាព ដោយផ្គូផ្គងទ្រព្យសកម្ម និងបំណុល ។
- សម្ព័ន្ធធនាគារនិងធនាគារមិនត្រូវពាក់ព័ន្ធនឹងសកម្មភាពដោយទទួលចំណូលបានមកពីការជួញដូរផ្តាច់មុខ ឬការទស្សន៍ទាយលើបម្រែបម្រួលនៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ ឬ តម្លៃនៃមូលធនបត្រ ។
- កម្រិតកំណត់ស្ថានភាពដូចដែលបានកំណត់ដោយធនាគារកណ្តាល គឺមានអត្ថន័យកម្រិតផលប៉ះពាល់អវិជ្ជមាននៃហានិភ័យទីផ្សារ និងមិនមានអត្ថន័យសម្រាប់បង្កើតឱកាសសម្រាប់ការជួញដូរផ្តាច់មុខទេ ។

- ទំនួលខុសត្រូវពីមួយថ្ងៃទៅមួយថ្ងៃសម្រាប់ហានិភ័យទីផ្សារ គឺស្ថិតនៅលើគណៈគ្រប់គ្រងជាន់ខ្ពស់នៃការិយាល័យរតនាភិបាល ។

*កម្រិតកំណត់ស្ថានភាពនៃហានិភ័យទីផ្សារ*

- កម្រិតកំណត់ដែលជាបញ្ញត្តិលើភាពមិនផ្គូរផ្គងគ្នានៃការប្តូររូបិយប័ណ្ណបរទេសក្នុងមួយរូបិយប័ណ្ណ និងការបង្គរ គួរត្រូវបានអង្កេតគ្រប់ពេលទាំងអស់ ។
- គ្រប់ពេលទាំងអស់ ធនាគារត្រូវមានកម្រិតកំណត់ស្ថានភាពខាងក្នុងដែលខ្ពស់ជាងកម្រិតកំណត់របស់បញ្ញត្តិ ដើម្បីឲ្យមានដែនសុវត្ថិភាពក្នុងការធានាការអនុលោមទាំងស្រុងជាអចិន្ត្រៃយ៍ ទៅតាមកម្រិតកំណត់បញ្ញត្តិ ។
- ការកំណត់កម្រិតនៃកម្រិតស្ថានភាពខាងក្នុង គឺស្ថិតនៅក្រោមការសម្រេចចិត្តរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល (MALCO) និងចាំបាច់ត្រូវតែ ១) ចែង និងលើកទឹកចិត្តនៅក្នុងកំណត់ហេតុ MALCO និង ២) ត្រូវបានអនុម័តជាផ្លូវការដោយប្រធាននាយកប្រតិបត្តិ ។
- នាយកដ្ឋាននិងការិយាល័យដែលពាក់ព័ន្ធគួរវាយតម្លៃជាទៀងទាត់ និងត្រួតពិនិត្យលើហានិភ័យនៃការមិនអនុលោមតាមកម្រិតកំណត់ដែលបានដឹង ។ ការបំពានកម្រិតកំណត់ស្ថានភាពខាងក្នុងគួរត្រូវបានរាយការណ៍ទៅកាន់ MALCO និងប្រធាននាយកប្រតិបត្តិ ។
- ការផ្លាស់ប្តូរទៅលើកម្រិតកំណត់ស្ថានភាពខាងក្នុង និងត្រូវរាយការណ៍ដោយអ៊ីម៉ែល ទៅកាន់ប្រធាន BALCO និង BRMC នៅក្នុងថ្ងៃតែមួយនៃការផ្លាស់ប្តូរ ។
- គ្រប់ពេលទាំងអស់ ធនាគារត្រូវមានផែនការគ្រាអាសន្នសម្រាប់អនុវត្ត នៅពេលដែលប្រធាននាយកប្រតិបត្តិយល់ឃើញថាកម្រិតសុវត្ថិភាពអាចនឹងមិនគ្រប់គ្រាន់ និងមានហានិភ័យលើការល្មើសលើកម្រិតកំណត់បញ្ញត្តិ លើភាពមិនផ្គូរផ្គងគ្នានៃការប្តូររូបិយប័ណ្ណបរទេស ។ ផែនការគ្រាអាសន្ននេះគួរតែគ្រប់គ្រាន់ដើម្បីធានាថាកម្រិតកំណត់បញ្ញត្តិភាពលើភាពមិនផ្គូរផ្គងការប្តូររូបិយប័ណ្ណបរទេស នឹងមិនត្រូវបានល្មើស ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សម្ព័ន្ធធនាគារមិនមានឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃសមស្របទេ ។ សម្ព័ន្ធធនាគារប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្តោះប្តូរអត្រាការប្រាក់ ដើម្បីគ្រប់គ្រងហានិភ័យរបស់ខ្លួន ។

## (ក) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ គឺជាហានិភ័យដែលធ្វើឲ្យមានការប្រែប្រួលលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ ហានិភ័យអត្រាការប្រាក់នៃតម្លៃសមស្រប គឺជាហានិភ័យដែលធ្វើឲ្យមានការប្រែប្រួលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ កម្រិតនៃការប្រាក់អាចកើនឡើងដោយសារលទ្ធផលនៃការប្រែប្រួល ប៉ុន្តែអាចកាត់បន្ថយការខាតបង់នៅក្នុងករណីដែលបម្រែបម្រួលឥតរំពឹងទុកកើតឡើង ។

គណៈគ្រប់គ្រងរបស់សម្ព័ន្ធធនាគារនិងធនាគារ ក្នុងខណៈនេះមិនមានចែងជាគោលការណ៍ ដើម្បីកំណត់កម្រិតនៃភាពលម្អៀងនៃការប្រែប្រួលថ្លៃរបស់អត្រាការប្រាក់ដើម្បីអនុវត្តនោះទេ ប៉ុន្តែគណៈគ្រប់គ្រងក៏បានធ្វើការត្រួតពិនិត្យជាប្រចាំនូវបម្រែបម្រួលនោះដែរ ។

ហានិភ័យអត្រាការប្រាក់របស់សម្ព័ន្ធធនាគារនិងធនាគារកើតពីប្រាក់កម្ចី ។ ប្រាក់កម្ចីដែលបានផ្តល់ក្នុងអត្រាការប្រាក់អថេរ ធ្វើឲ្យសម្ព័ន្ធធនាគារនិងធនាគារប្រឈមនឹងហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ ។ សម្ព័ន្ធធនាគារនិងធនាគារគ្រប់គ្រងហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ ដោយប្រើការផ្តោះប្តូរអត្រាការប្រាក់អថេរទៅអត្រាថេរ (floating-to-fixed interest rate swaps) ។ ការផ្តោះប្តូរអត្រាការប្រាក់បែបនេះ មានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចលើការបង្វិលប្រាក់កម្ចីពីអត្រាអថេរទៅអត្រាថេរ និងប៉ះពាល់ដល់ការកត់ត្រាចំណាយការប្រាក់ដែលផ្អែកទៅតាមអត្រាថេរ ។ សម្ព័ន្ធធនាគារនិងធនាគារទទួលប្រាក់កម្ចីតាមអត្រាអថេរ និងប្តូរវាទៅជាអត្រាថេរដែលទាបជាងអត្រាដែលមានប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ បានខ្ចីតាមអត្រាថេរដោយផ្ទាល់ ។ តាមការផ្តោះប្តូរអត្រាការប្រាក់ សម្ព័ន្ធធនាគារនិងធនាគារព្រមព្រៀងជាមួយភាគីផ្សេងៗដើម្បីផ្តោះប្តូរតាមចន្លោះពេលវេលាជាក់លាក់ (ជាចម្បងតាមមូលដ្ឋានប្រចាំឆមាស) ភាពលម្អៀងរវាងអត្រាថេរក្នុងកិច្ចសន្យា និងចំនួនការប្រាក់ដែលមានអត្រាអថេរ ត្រូវបានគណនាដោយយោងទៅតាមចំនួនដែលបានព្រមព្រៀងគ្នា ។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់សម្ព័ន្ធធនាគារនិងធនាគារ ។ នៅក្នុងតារាងនេះក៏រួមបញ្ចូលនូវឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោងដោយបានចាត់ថ្នាក់តាមតម្លៃក្នុងកិច្ចសន្យាដើមគ្រា ឬតាមកាលផុតកំណត់សង ។

| | សម្ព័ន្ធធនាគារ | | | | | | |
|---|---|---|---|---|---|---|---|
